**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីតក្កកម្ម

# តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ សមណនិស្សិត **ខេង វ៉ាឃិត**

លោក **ហេង ដាវីដ**

ណែនាំដោយ

បណ្ឌិត **យឹម គិរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា អាត្មាភាពព្រះនាម **ខេង វ៉ាឃិត** និង លោក **ហេង ដាវីដ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី០៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២៣ បានសរសេរសារណាក្នុងគោលបំណងដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី **នីតិវិធីនៃការចុះបញ្ជីតក្កកម្ម តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។**

ជាបឋមយើងខ្ញុំ សូមគោរពលំអោនកាយ វាចាចិត្ត ថ្លែងអំណរគុណ និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងនូវគុណូបការៈចំពោះលោកឪពុក អ្នកម្តាយ ទាំងទ្វេយ៉ាងជ្រាលជ្រៅ ដែលបានលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត ចិញ្ចឹមបីបាច់ អប់រំទូន្មានព្រមទាំងផ្តល់ការផ្គត់ផ្គង់ការសិក្សារៀនសូត្រចំពោះកូនៗ រហូតមកដល់ថ្ងៃបញ្ចប់ថ្នាក់បរិញ្ញាបត្រ៖ លោកឪពុក **គឹង យស់** អ្នកម្តាយ **ជាត នាង** និង លោកឪពុក **ហេង ខុន** អ្នកម្តាយ **ទេព មូរី** ដែលលោកបានលះបង់គ្រប់បែបយ៉ាងដើម្បីកូនៗ។ លើសពីនេះលោកទាំងទ្វេបានផ្តល់នូវការស្រឡាញ់ឥតដែនកំណត់ ការថ្នាក់ថ្នម យ៉ាងកក់ក្តៅ និងការរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងមហាកិត្តយសមកដល់កូនៗ ដែលកូនមិនអាចបំភ្លេចបានក្នុងជីវិត។

សូមគោរពថ្លែងអំណរគុណ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក/លោកស្រីសាស្ត្រាចារ្យ គ្រប់រូបនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន និងស្វះស្វែងសិក្សាស្រាវជ្រាវរិះរកបកគំហើញថ្មីៗបន្ថែម ដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ល្អៗដល់និស្សិតគ្រប់ៗរូបឲ្យមានសមត្ថភាពពេញលេញដែលសង្គមជាតិត្រូវការ។

លោកបណ្ឌិត **ឃឹម គិរី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ បង្ហាត់បង្ហាញ ផ្តល់គន្លឹះទ្រឹស្តី ពន្យល់កែតម្រូវ ព្រមទាំងបានបង្កើតលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ រហូតឈានដល់ការសរសេរបញ្ចប់នូវសមិទ្ធផលសារណាមួយនេះដោយជោគជ័យ។

ដោយសារតែការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត ស្មារតី ព្រមទាំងបានផ្តល់នូវក្តីស្រឡាញ់មួយនេះ ដើម្បីជាការតបស្នងនូវគុណូបការៈដ៏ធំធេង ចំពោះលោកអ្នកមានគុណទាំងអស់ នៅក្នុងឱកាសនេះយើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ចូរកើតមានដល់ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងព្រមទាំងមិត្តរួមជំនាន់គ្រប់ៗរូប** សូមឲ្យមានសុខភាពល្អ ជោគជ័យក្នុងការប្រកបសព្វកិច្ចការ ជាពិសេសសូមឲ្យសមប្រកបជួបតែ ពុទ្ធពរទាំងឡាយ បួនប្រការគឺ អាយុ វណ្ណៈ សុខ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

ត្រូវនឹងថ្ងៃចន្ទ ១១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

# អារម្ភកថា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចគឺ ជាសាកលវិទ្យាល័យមួយដែលមានភាពល្បីល្បាញនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានចូលរួមអភិវឌ្ឍធនធានមនុស្សជាច្រើន ជាពិសេសថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ។ ក្រោយពីបានឆ្លងកាត់ការសិក្សាអស់រយៈពេល៤ឆ្នាំនៃជំនាញនីតិសាស្ត្រ រូបខ្ញុំទាំងពីរបានទទួលនូវចំណេះដឹង និងដំបូន្មានល្អៗអំពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ និងដោយស្របតាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ។

នៅក្នុងកំឡុងពេលសិក្សា យើងខ្ញុំមានការចាប់អារម្មណ៍ និងចូលចិត្តសិក្សាយ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិកម្មសិទ្ធបញ្ញា រហូតធ្វើឲ្យយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទ **នីតិវិធីនៃការចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម** ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ សារណារបស់យើងខ្ញុំ នឹងធ្វើការពិពណ៌នាអំពីទិដ្ឋភាពគតិយុត្ត និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាលក្ខណៈអន្តរជាតិ ជាពិសេសចំពោះប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលត្រូវផ្តល់នូវការការពារចំពោះស្នាដៃឱ្យគ្នាទៅវិញទៅមក។

ជាក់ស្តែងអ្វីដែលធ្វើឲ្យរូបយើងខ្ញុំទាំងពីរកាន់តែចាប់អារម្មណ៍ខ្លាំងនោះគឺ កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម ហើយកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង អង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (EPO) ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការទទួលស្គាល់នូវសុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា និងអនុស្សារណៈយោគយល់គ្នាលើកិច្ចប្រតិបត្តិការទ្វេភាគី។ ការចូលជាសមាជិករបស់កម្ពុជា គឺជាជំហានថ្មីមួយទៀត ដើម្បីទទួលបានទំនុកចិត្ត និងភាពទាក់ទាញដល់អ្នកវិនិយោគពីសមាគមន៍អឺរ៉ុបឱ្យមកធ្វើការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ដែលនឹងជួយបង្កើតទីផ្សារពលកម្មលើកស្ទួយជីវភាពរបស់ប្រជាពល និងជួយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។យើងខ្ញុំសង្ឃឹមថាសមិទ្ធផលនៃការស្រាវជ្រាវដើម្បីសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទស្តីពី នីតិវិធីក្នុងការចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម អាចក្លាយជាឯកសារជំនួយស្មាតីនៅក្នុងការសិក្សារបស់អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិតជំនាន់ក្រោយគ្រប់ៗរូប ដែលនឹងធ្វើការសិក្សាស្រាវជ្រាវបន្តទាក់ទងទៅនឹងប្រធានបទនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ សូមធ្វើខន្តីអភ័យទោសនូវរាល់ចន្លោះខ្វះខាតទាំងឡាយ ដោយសារការសិក្សាស្រាវជ្រាវពុំបានសព្វជ្រុងជ្រោយនៃផ្នែកណាមួយក្នុងសារណាបញ្ចប់ការសិក្សានេះ ហើយយើងខ្ញុំទាំងពីរ

សូមទទួលយកនូវមតិយោបល់ ការរិះគន់កែលម្អក្នុងន័យស្ថាបនាអំពី សំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងមិត្តអ្នកអាន សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវគ្រប់រូប។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**

**១.១ គោលបំណង និងកម្មវត្ថុ** ........ ៣

**១.២ អង្គការចាត់តាំង** ........ ៤

១.២.១ សន្និបាត ........ ៤

១.២.២ គណៈកម្មការប្រតិបត្តិ ........ ៥

១.២.៣ ការិយាល័យអន្តរជាតិ ........ ៦

១.២.៤ គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស ........ ៦

**ជំពូកទី២**

**នីតិវិធីចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**

**២.១ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ** ........ ៩

២.១.១ សំណុំលិខិតស្នើសុំអន្តរជាតិ ........ ៩

២.១.២ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ........ ១១

**២.២ ការស្រាវជ្រាវអន្តរជាតិ និង របាយការណ៍ស្រាវជ្រាវអន្តរជាតិ** ........ ១៥

២.២.១ ការស្រាវជ្រាវអន្តរជាតិ ........ ១៦

២.២.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិ ........ ១៨

២.២.៣ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ........ ១៨

**២.៣ ការចុះផ្សាយអន្តរជាតិ** ........ ២០

២.៣.១ អានុភាពនៃការចុះផ្សាយអន្តរជាតិ ........ ២០

២.៣.២ ភាសានៃការចុះផ្សាយអន្តរជាតិ ........ ២១

**២.៤ ការស្រាវជ្រាវអន្តរជាតិបន្ថែម និងរបាយការណ៍ស្រាវជ្រាវ** ........

**អន្តរជាតិបន្ថែម** ........ ២១
២.៤.១ នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម ........ ២២
២.៤.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម ........ ២៣
**២.៥ ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិ និងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ** ........ ២៣
២.៥.១ នីតិវិធីនៃការពិនិត្យជំហានដំបូងអន្តរជាតិ ........ ២៤
២.៥.២ របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ........ ២៧
**២.៦ ការពិនិត្យកម្រិតជាតិ** ........ ២៨
២.៦.១ ឯកសារតម្រូវជាមូលដ្ឋាន ........ ២៩
២.៦.២ ការពិចារណា ........ ២៩
២.៦.៣ ការកែសម្រួលនៅដំណាក់កាលនីតិវិធីកម្រិតជាតិ ........ ៣០
**សេចក្តីសន្និដ្ឋាន** ........ ៣១
**អនុសាសន៍** ........ ៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- PCT : (Patent Cooperation Treaty) សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម
- WIPO : ( World Intellectual Property Organization) អង្គការកម្មសិទ្ធិបញ្ញាពិភពលោក
- ARIPO: (African Regional Intellectual Property Organization) អង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក
- OAPI : (African Intellectual Property Organization) អង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក
- IPEA : (International Preliminary Examination Authority) អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ
- EPO : (European Patent Office) ការិយាល័យតក្កកម្មអឺរ៉ុប

# បញ្ជីរូបភាព


រូបភាពទី១៖ សង្ខេបអំពីនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញា PCT……………………….៨

រូបភាពទី២៖ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ……………………………………………………......៩

រូបភាពទី៣៖ ការស្រាវជ្រាវអន្តរជាតិ…………………………………………………………….........១៥

រូបភាពទី៤៖ ការចុះផ្សាយអន្តរជាតិ………………………………………………………………...២០

រូបភាពទី៥៖ ការស្រាវជ្រាវអន្តរជាតិបន្ថែម……………………………………………………….២១

រូបភាពទី៦៖ ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិ..........................................................................២៣

រូបភាពទី៧៖ របាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ……………………………………………….២៧

រូបភាពទី៨៖ ការពិនិត្យកម្រិតជាតិ…………………………………………………………………....២៨

# សេចក្តីផ្តើម

តក្កកម្ម គឺជាស្នាដៃរបស់តក្កករដែលបានប្រើប្រាស់បញ្ញារបស់ខ្លួនក្នុងការស្វែងរកនឹងបង្កើតនូវសមិទ្ធផលថ្មីមួយដែលមិនធ្លាប់មានពីមុនមកហើយត្រូវតែថ្មី ហើយដែលអាចផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិ និងវិស័យឧស្សាហកម្ម។ ដើម្បីទទួលបានការការពារ តក្កករដែលបានរកឃើញនូវតក្កកម្មត្រូវស្វះស្វែងរកនូវការការពារតាមផ្លូវច្បាប់នៅក្នុងប្រទេសរបស់ខ្លួន។ ដោយឡែកប្រសិនបើ តក្កករចង់ទទួលបាននូវការការពារដែលមានវិសាលភាពលើសពីប្រទេសរបស់ខ្លួន តក្កករត្រូវធ្វើការចុះបញ្ជីនូវតក្កកម្មរបស់ខ្លួននៅទីកន្លែងដែលគាត់ចង់ឱ្យមានការការពារ ឬតក្កករអាចជ្រើសរើសនូវប្រព័ន្ធចុះបញ្ជីដែលមានលក្ខណៈជាអន្តរជាតិ គឺត្រូវធ្វើការចុះបញ្ជីតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មគឺជាប្រព័ន្ធនៃការចុះបញ្ជីមួយ ដែលមានគោលបំណងជួយសម្រួល និងផ្តល់ភាពងាយស្រួលដល់តក្កករ ឬ អ្នកដាក់ពាក្យសុំដើម្បីទទួលបានការការពារចំពោះតក្កកម្មរបស់ខ្លួននៅច្រើនប្រទេស ជាពិសេសប្រទេសជាសមាជិកភាពនៃសន្ធិសញ្ញា។

ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី១៥១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មជាផ្លូវការនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រត្តកកម្ម នៅតែជាប្រធានបទថ្មីដែលមិនទាន់បានជ្រួតជ្រាបចូលទៅក្នុងសង្គម និងគ្រឹះស្ថានអប់រំព្រមទាំងតក្កករនៅកម្ពុជានៅឡើយ។

គោលគំនិតចម្បងនៃការសិក្សាស្រាវជ្រាវនូវប្រធានបទនេះគឺ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ផ្សព្វផ្សាយ និងអនុវត្តនូវច្បាប់កម្មសិទ្ធបញ្ញាជាមួយរាជរដ្ឋាភិបាល ដោយផ្តោតទៅលើនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាអន្តរជាតិតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដល់តក្កករនៅកម្ពុជាឲ្យទទួលបាននូវចំណេះដឹងកាន់តែទូលំទូលាយជាងមុន ស្របពេលដែលបច្ចុប្បន្ន ប្រទេសកម្ពុជាបាននឹងកំពុងតែមានការរីកចម្រើនស្ទើរគ្រប់វិស័យ ទាំងវិស័យសេដ្ឋកិច្ចឧស្សាហកម្ម បច្ចេកវិទ្យា និងបច្ចេកវិទ្យាឌីជីថល ដែលផ្សារភ្ជាប់ជាមួយកម្មសិទ្ធបញ្ញា ហើយដែលអាចទទួលបានការការពារនៅកម្ពុជា និងជាអន្តរជាតិផងដែរ។

ដោយយល់ឃើញពីសារៈសំខាន់នៃប្រធានបទខាងលើ ហេតុដូច្នេះយើងខ្ញុំបានកំណត់នូវវិសាលភាពនៃការស្រាវជ្រាវក្នុងការសរសេរសារណា ត្រឹមសិក្សាដោយផ្តោតសំខាន់ទៅលើតែនីតិវិធីនៃការចុះបញ្ជីតក្កកម្មអន្តរជាតិ តាមសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្មតែប៉ុណ្ណោះ។

- នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សា យើងខ្ញុំបានធ្វើការបែងចែកជាពីរជំពូក ដែលយើងនឹងចាប់ផ្តើមពីការបកស្រាយសញ្ញាណទូទៅនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនៅក្នុងជំពូកទីមួយ។ ដោយនៅក្នុងជំពូកទី១ យើង

នឹងធ្វើការបកស្រាយពីគោលបំណង កម្មវត្ថុ និងអង្គការចាត់តាំងរបស់សន្ធិសញ្ញា។ នៅក្នុងជំពូកទី២ គឺជាជំពូកដែលនឹងធ្វើការបង្ហាញអំពីនីតិវិធីទាំងឡាយដែលទាក់ទងទៅនឹងការចុះបញ្ជីជាអន្តរជាតិនៃតក្កកម្ម ដោយស្របទៅតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Patent Cooperation Treaty ដែលហៅកាត់ថា សន្ធិសញ្ញា PCT ) គឺជាលិខិតូបករណ៍អន្តរជាតិមួយ ដែលបានចុះហត្ថលេខាដោយពហុភាគីក្នុងសន្និសីទការទូត ត្រូវបានធ្វើឡើងនៅទីក្រុងវ៉ាស៊ីនតោន នៅថ្ងៃទី២៥ ខែឧសភា ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ ដោយមានរដ្ឋហត្ថលេខីចំនួន ១៨ប្រទេសហើយបានចូលជាធរមាននៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ។ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមការគ្រប់គ្រងដោយការិយាល័យអន្តរកម្មនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវ ប្រទេសស្វីសហើយពាក្យស្នើសុំអន្តរជាតិដំបូងគេ ត្រូវបានដាក់នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៨។ សន្ធិសញ្ញា PCT ត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ក្នុងឆ្នាំ១៩៧៩ ហើយបានកែប្រែនៅឆ្នាំ១៩៨៤ និង ២០០១។ គិតត្រឹមឆ្នាំ២០២៣ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មានសមាជិកចំនួន ១៥៧ ប្រទេសដែលជារដ្ឋហត្ថលេខី ដែលកំពុងផ្តល់ការចុះបញ្ជីលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាលក្ខណៈអន្តរជាតិ។

ដើម្បីសិក្សាស្វែងយល់ អំពីសញ្ញាណទូទៅនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ចំណុចខាងក្រោមនឹងផ្តោតទៅលើគោលបំណង និងកម្មវត្ថុ (១.១) និងអង្គការចាត់តាំងរបស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (១.២)។

## ១.១ គោលបំណង និងកម្មវត្ថុ

គោលបំណងនៃសន្ធិសញ្ញា PCT នេះមានគោលបំណងចូលរួមចំណែកធ្វើឲ្យរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមរយៈ៖

- កែលម្អ និងសម្រួលនីតិវិធីដើម្បីទទួលបានការការពារតក្កកម្មតាមផ្លូវច្បាប់ដ៏សុក្រឹត
- ធ្វើឲ្យមានភាពងាយស្រួល និងធ្វើឲ្យសន្សំសំចៃចំពោះការទទួលបាននូវការការពារនូវ តក្កកម្មក្នុងបណ្តាប្រទេសជាច្រើន
- ជួយសម្រួល និងពន្លឿនដំណើរការនៃអាជ្ញាធរសាធារណៈ ចំពោះឯកសារសេចក្តីអធិប្បាយបច្ចេកទេសនៃតក្កកម្ម
- ជំរុញ និងពន្លឿនការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការអនុម័តនូវវិធានដែលចងក្រងឡើងដើម្បីបង្កើនប្រសិទ្ធិភាព នៃប្រព័ន្ធច្បាប់សម្រាប់ការការពារផ្តល់ភាពងាយស្រួល និង រកដំណោះស្រាយបច្ចេកទេសពាក់ព័ន្ធតក្កកម្ម

ផ្អែកលើគោលបំណងនេះ សន្ធិសញ្ញា PCT មានកម្មវត្ថុចម្បងបង្កើតឲ្យមានវិធាននៃប្រព័ន្ធចុះបញ្ជីលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មតែមួង នៅការិយាល័យទទួល ដើម្បីទទួលបានការការពារតក្កកម្មនៅបណ្តាប្រទេសជាច្រើន។ វិធានទាំងនោះតម្រូវឲ្យរដ្ឋហត្ថលេខី រួមគ្នាជាសហព័ន្ធមួយដើម្បីធ្វើសហប្រតិបត្តិការក្នុងការដាក់សំណុំលិខិតស្នើសុំ ការស្រាវជ្រាវសំណុំលិខិតស្នើសុំ និងពិនិត្យសំណុំលិខិតស្នើសុំសម្រាប់ការការពារតក្កកម្ម និងសម្រាប់ផ្តល់សេវាកម្មបច្ចេកទេសពិសេស។[1]

## ១.២ អង្គការចាត់តាំង

សន្ធិសញ្ញា PCT មានសន្និបាត (១.២.១) ដែលចាត់ទុកជារចនាសម្ព័ន្ធកំពូលរបស់សន្ធិសញ្ញារាល់កិច្ចការធំៗពាក់ព័ន្ធនឹងសន្ធិសញ្ញាត្រូវសម្រេចដោយសន្និបាត។ បន្ទាប់ពីសន្និបាត គឺគណៈកម្មការប្រតិបត្តិ (១.២.២) ដែលចាត់ទុកជាអង្គភាពប្រតិបត្តិការងារជំនួសឲ្យសន្និបាតនៅចន្លោះសម័យប្រជុំ ហើយការិយាល័យអន្តរជាតិ (១.២.៣) គឺជាអង្គភាពរដ្ឋបាល ដែលចាត់ចែងនឹងដឹកនាំការងារប្រចាំថ្ងៃ និងដឹកនាំដោយអគ្គនាយកមួយរូប។ ចុងក្រោយគឺ គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស (១.២.៤) ដែលត្រូវចាត់ទុកជាអង្គភាពប្រឹក្សាយោបល់ផ្នែកបច្ចេកទេស។

### ១.២.១ សន្និបាត

រដ្ឋាភិបាលនៃរដ្ឋហត្ថលេខីនីមួយៗ ត្រូវតែតំណាងដោយប្រតិភូម្នាក់ និងត្រូវមានជំនួយការអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញការមួយចំនួន។ សន្និបាតត្រូវជួបជុំជារៀងរាល់តាមប្រតិទិនប្រចាំឆ្នាំលើកទីពីរនៅក្នុងសម័យប្រជុំពេញអង្គតាមការកោះអញ្ជើញរបស់អគ្គនាយកតាមសំណើររបស់គណៈកម្មការប្រតិបត្តិ ឬតាមសំណើររបស់រដ្ឋហត្ថលេខីចំនួន ១/៤។ ចំនួន ៥០បូកមួយនៃចំនួនរដ្ឋហត្ថលេខី ត្រូវចាត់ជាចំនួនចាំបាច់សម្រាប់បើកអង្គប្រជុំ។

សន្និបាតរបស់សន្ធិសញ្ញា PCT មានតួនាទីត្រូវ៖

- ដោះស្រាយរាល់បញ្ហា និងចាត់ចែងគ្រប់គ្រងសកម្មភាពពាក់ព័ន្ធទៅនឹងការថែរក្សា និងការពារការអភិវឌ្ឍន៍សហព័ន្ធ ជាពិសេសដំណើរនៃការអនុវត្តរបស់សន្ធិសញ្ញានេះ
- អនុវត្តការងារស្នូលដែលបានកំណត់ដោយ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនោះ
- ចង្អុលបង្ហាញ ឬផ្តល់បទបញ្ជាចំពោះការិយាល័យអន្តរជាតិ ពាក់ព័ន្ធទៅនឹងការរៀបចំសន្និសីទដើម្បីពិនិត្យការងារឡើងវិញ

[1] សន្ធិសញ្ញា PCT មាត្រា ១

- ត្រួតពិនិត្យនឹងអនុម័តទៅលើរបាយការណ៍ និងសកម្មភាពរបស់គណៈកម្មការប្រតិបត្តិនឹងផ្តល់ការណែនាំទៅកាន់គណៈកម្មការនោះ
- ត្រួតពិនិត្យ និងអនុម័តទៅលើរបាយការណ៍ និងសកម្មភាពរបស់ប្រធានក្រុមប្រឹក្សាភិបាលរបស់ស្ថាប័ន និងផ្តល់ការណែនាំពាក់ព័ន្ធទៅនឹងបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័ន
- កំណត់កម្មវិធី និងជ្រើសរើសយកគម្រោងចំណាយ របស់ស្ថាប័នសម្រាប់រយៈពេល ៣ឆ្នាំម្តង មាត្រា៥៣ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ចុះនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០) និងផ្តល់ការអនុម័តយល់ព្រមលើបញ្ជីគណនីចុងក្រោយ
- ជ្រើសរើស និងអនុម័តយកបទប្បញ្ញត្តិហិរញ្ញវត្ថុ របស់ស្ថាប័ន
- បង្កើតគណៈកម្មការ និងក្រុមការងារតាមដែរសន្និបាតគិតថា ជាការសមស្របដើម្បីឱ្យកម្មវត្ថុរបស់ស្ថាប័ន ឬសហព័ន្ធសម្រេចបានជោគជ័យ។
- កំណត់ពីរដ្ឋដែលមិនមែនជារដ្ឋហត្ថលេខី របស់សន្ធិសញ្ញា និងស្ថាប័នរាជរដ្ឋាភិបាលព្រមទាំងស្ថាប័នអន្តរជាតិ មិនមែនរាជរដ្ឋាភិបាលដើម្បី អនុញ្ញាតឲ្យចូលរួមនៅក្នុងកិច្ចប្រជុំក្នុងឋានៈជាអ្នកអង្កេតការណ៍
- ទទួលយកសកម្មភាពសម្របសម្រួលណាមួយដែលធ្វើឡើង ព្រមទាំងជម្រុញទៅដល់កម្មវត្ថុរបស់ស្ថាប័ន និងដំណើរការមុខងារផ្សេងៗ ឲ្យស្របទៅតាមសន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្មនេះ។[2]

### ១.២.២ គណៈកម្មការប្រតិបត្តិ

គណៈកម្មការប្រតិបត្តិត្រូវបានបង្កើតឡើងដោយរដ្ឋដែលជ្រើសតាំងដោយសន្និបាត ពីចំណោមរដ្ឋសមាជិកនៃសន្និបាត។ រដ្ឋាភិបាលនៃរដ្ឋសមាជិកនីមួយៗ នៃគណៈកម្មការប្រតិបត្តិត្រូវតែតំណាងដោយប្រតិភូម្នាក់ និងជំនួយការអម ទីប្រឹក្សា និងអ្នកជំនាញការមួយចំនួន។ ចំនួនរដ្ឋដែលជាសមាជិកនៃគណៈកម្មការ ត្រូវឲ្យស្របទៅនឹងចំនួន ១/៤ នៃចំនួនរដ្ឋ ដែលជាសមាជិកនៃសន្និបាត និងត្រូវគិតគូរទៅដល់ការបែងចែកដ៏មានសមធម៌ តាមលក្ខណៈភូមិសាស្ត្រ។

គណៈកម្មការប្រតិបត្តិត្រូវៈ

- រៀបចំសេចក្តីព្រៀងរបៀបវារៈរបស់សន្និបាត

[2] សន្ធិសញ្ញា PCT មាត្រា ៥៣

- ដាក់សំណើជូនសន្និបាតដែលពាក់ព័ន្ធទៅនឹងសេចក្តីព្រាងកម្មវិធី និងថវិកាប្រចាំបីឆ្នាំរបស់សហព័ន្ធដែលរៀបចំដោយអគ្គនាយក
- ដាក់ជូនសន្និបាតនូវរបាយការណ៍ជាដំណាក់កាលរបស់អគ្គនាយក និងរបាយការណ៍សវនកម្មប្រចាំឆ្នាំអំពីបញ្ជីគណនេយ្យជាមួយសេចក្តីសង្កេតសមស្រប
- ចាត់វិធានការចំបាច់នានា ដើម្បីធានាការប្រតិបត្តិកម្មវិធីរបស់សហព័ន្ធដោយអគ្គនាយក ដោយយោងតាមសេចក្តីសម្រេចរបស់សន្និបាតហើយគិតទៅដល់កាលៈទេសៈ ដែលកើតឡើងរវាងសម័យប្រជុំពេញអង្គទាំងពីររបស់សន្និបាត
- អនុវត្តការងារផ្សេងៗទៀត ដូចត្រូវបានគ្រោងទុកសម្រាប់ខ្លួននៅក្នុងក្រោមសន្ធិសញ្ញានេះ
- គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំម្តងនៅក្នុងសម័យប្រជុំពេញអង្គ តាមការកោះអញ្ជើញរបស់អគ្គនាយក និងត្រូវប្រជុំវិសាមញ្ញម្តង តាមការកោះអញ្ជើញរបស់អគ្គនាយក ឬ តាមសំណើរបស់ប្រធានគណៈកម្មការប្រតិបត្តិ ឬ សមាជិកចំនួន ១/៤ នៃចំនួនសមាជិករបស់ខ្លួន។[3]

### ១.២.៣ ការិយាល័យអន្តរជាតិ

ការិយាល័យអន្តរជាតិ គឺជាការិយាល័យអនុវត្តភារកិច្ចរដ្ឋបាលដែលដឹកនាំដោយអគ្គនាយក ហើយត្រូវផ្តល់ឲ្យលេខាធិការដ្ឋាននូវកម្មវិធីផ្សេងៗនៃសហព័ន្ធ។ អគ្គនាយកត្រូវតែជាប្រធានប្រតិបត្តនៃសហព័ន្ធ និងបោះពុម្ពផ្សាយព្រឹត្តិប័ត្រ និងបោះពុម្ពផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ជា ឬ តាមលក្ខខណ្ឌតម្រូវការរបស់អង្គសន្និបាត។ បទបញ្ជាត្រូវបញ្ជាក់សេវាកម្មដែលការិយាល័យជាតិត្រូវធ្វើ ក្នុងគោលបំណងជួយការិយាល័យអន្តរជាតិ អាជ្ញាធរអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិក្នុងការអនុវត្តន៍ភារកិច្ចរបស់គេនៅក្រោមច្បាប់នេះ។ អគ្គនាយក និងសមាជិកដែលជាបុគ្គលណាម្នាក់ដែលត្រូវបានចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមគ្រប់ការប្រជុំទាំងអស់ដែលធ្វើឡើងដោយសន្និបាត គណៈកម្មការប្រតិបត្តិ និងគណៈកម្មការផ្សេងទៀត ឬក្រុមការងារដែលបង្កើតនៅក្រោមសន្ធិសញ្ញាអន្តរជាតិមួយនេះ បទបញ្ជាគ្មានសិទ្ធិបោះឆ្នោតឡើយ។ អគ្គនាយក ឬសមាជិកដែលបុគ្គលិកចាត់តាំងដោយអគ្គនាយកត្រូវតែជា Exofficio Secretary នៃស្ថាប័នទាំងអស់។[4]

### ១.២.៤ គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស

គណៈកម្មការសហប្រតិបត្តការបច្ចេកទេស ត្រូវបង្កើតឡើងដោយសន្និបាត។ គោលបំណងនៃការបង្កើតគណៈកម្មការនេះ ក្នុងគោលបំណងចូលរួមផ្តល់ដំបូន្មាន និងការណែនាំ សំដៅធ្វើឲ្យប្រសើរឡើងជាប្រចាំនៃសេវាកម្មនានា ធានាឲ្យមានសង្គតិភាពក្នុងការផ្តល់ឯកសារ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ព្រម

[3] សន្ធិសញ្ញា PCT មាត្រា ៥៤

[4] សន្ធិសញ្ញា PCT មាត្រា ៥៥

ទាំងរកដំណោះស្រាយបញ្ហាបច្ចេកទេសនានា។ ចំពោះសមាសភាពរបស់គណៈកម្មការប្រតិបត្តិត្រូវបានកំណត់ដោយសន្និបាតហើយការចាត់តាំងសមាជិកគណៈកម្មការដោយគិតទៅដល់សមធម៌ តំណាងរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ អាជ្ញាធរអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវតែជាសមាជិកពេញសិទ្ធិរបស់គណៈកម្មការ។ ក្នុងករណីអាជ្ញាធរនោះជាការិយាល័យជាតិនៃរដ្ឋហត្ថលេខីនោះមិនត្រូវជាតំណាងបន្ថែមទៀតនៅក្នុងគណៈកម្មការឡើយ។ ប្រសិនបើចំនួនរដ្ឋហត្ថលេខីអនុញ្ញាតនោះចំនួនសរុបរបស់សមាជិកគណៈកម្មការត្រូវតែច្រើនទ្វេដងនៃចំនួនសមាជិកពេញសិទ្ធិ។ អគ្គនាយកត្រូវអញ្ជើញតំណាងអង្គការដែលមានការចាប់អារម្មណ៍ឲ្យចូលរួមនៅក្នុងកិច្ចពិភាក្សាអំពីការពាក់ព័ន្ធរបស់គេ ឈរលើការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬ តាមសំណើរបស់គណៈកម្មការ។ រដ្ឋហត្ថលេខីណាមួយ និងអង្គការអន្តរជាតិពាក់ព័ន្ធណាមួយ អាចទាក់ទងជាមួយគណៈកម្មការជាលាយលក្ខណ៍អក្សរស្តីពីបញ្ហានានាដែលជាសមត្ថកិច្ចរបស់គណៈកម្មការ។ គណៈកម្មការអាចផ្តល់ដំបូន្មាន និងការណែនាំចំពោះអគ្គនាយក ឬតាមរយៈអគ្គនាយកចំពោះសន្និបាត គណៈកម្មការប្រតិបត្តិអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិមួយចំនួន ឬ ទាំងអស់ និងការិយាល័យទទួលមួយចំនួនឬទាំងអស់ ក្នុងករណីណាក៏ដោយ អគ្គនាយកត្រូវបញ្ជូនឲ្យគណៈកម្មការប្រតិបត្តនូវអត្ថបទនានានៃដំបូន្មាន និងការណែនាំរបស់គណៈកម្មការ។ គណៈកម្មការប្រតិបត្តិអាចបញ្ចាក់ការយល់ឃើញ របស់ខ្លួននៅលើដំបូន្មានការណែនាំណាមួយ ឬ សកម្មភាពផ្សេងទៀតរបស់គណៈកម្មការ ហើយអាចអញ្ជើញគណៈកម្មការឲ្យទៅសិក្សា និងរាយការណ៍អំពីបញ្ហាដែលជាសមត្ថកិច្ចរបស់គណៈកម្មការ។ គណៈកម្មការប្រតិបត្តិអាចដាក់ជូនសន្និបាតនូវដំបូន្មានការណែនាំ និងរបាយការណ៍ព្រមជាមួយ និងសេចក្តីអធិប្បាយសមស្របរបស់គណៈកម្មការ។[5]

[5] សន្ធិសញ្ញា PCT មាត្រា ៥៦

# ជំពូកទី២
# នីតិវិធីចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញា សហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

នីតិវិធីចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញា (PCT) ត្រូវបានបែងចែកជាពីរកម្រិតគឺ នៅកម្រិតអន្តរជាតិ និង នៅកម្រិតជាតិ។ នៅក្នុងកម្រិតអន្តរជាតិ នីតិវិធីនៃការចុះបញ្ជី ត្រូវបានបែងចែកជា ០៥ ដំណាក់កាលបន្ថែមទៀត ដោយនីតិវិធីចំនួន ០៣ ជានីតិវិធីតម្រូវ គឺការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ(២.១) ការស្រាវជ្រាវអន្តរជាតិ របាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដោយអាជ្ញាធរអន្តរជាតិ (២.២) និងចុះផ្សាយជាអន្តរជាតិ (២.៣) ដែលជានីតិវិធីតម្រូវចាំបាច់សម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិទាំងអស់ដើម្បី ចុះបញ្ជីស្ថិតក្រោមសន្ធិសញ្ញានេះ។ ចំណែកនីតិវិធី ០២ ផ្សេងទៀតគឺ ជានីតិវិធីជម្រើសរបស់អ្នកដាក់ពាក្យសុំ ក្នុងការពិចារណាថាតើគួរអនុវត្ត ឬមិនគួរអនុវត្តរួមមាន ការស្រាវជ្រាវអន្តរជាតិបន្ថែម និងរបាយការណ៍ស្រាវជ្រាវ អន្តរជាតិបន្ថែម (២.៤) និងការត្រួតពិនិត្យជំហានដំបូងអន្តរជាតិ (២.៥) បន្ទាប់ពីចប់នីតិវិធីនៃការចុះបញ្ជីនៅ កម្រិតអន្តរជាតិដំណាក់កាលបន្ទាប់គឺ នីតិវិធីកម្រិតជាតិ នៃប្រទេសនីមួយៗដែលអ្នកដាក់ពាក្យសុំមានបំណង ចង់ឲ្យមានការពារនៅប្រទេសនោះដែលតម្រូវឲ្យបំពេញលក្ខខណ្ឌចាំបាច់មួយចំនួនដែលបានកំណត់តាមសន្ធិ សញ្ញានេះ(២.៦)។




*(រូបភាពសង្ខេបអំពីនីតិវិធីចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញា PCT)*

## ២.១ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ

ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ គឺជាដំណើរការនៃនីតិវិធីដំបូងក្នុងការរៀបចំឯកសារដែលតក្កករត្រូវអនុវត្តឲ្យសមស្របតាមបទដ្ឋាននៃសន្ធិសញ្ញាដែលមានចែង។ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិត្រូវដាក់រយៈពេល ១២ខែ ដោយគិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាពនៃសំណុំលិខិតស្នើសុំដំបូង[6]។




### ២.១.១ សំណុំលិខិតស្នើសុំអន្តរជាតិ

សំណុំលិខិតស្នើសុំអន្តរជាតិ ជាដំបូងត្រូវដាក់នៅការិយាល័យទទួល ផ្អែកតាមមាត្រា១០នៃសន្ធិសញ្ញា ហើយការិយាល័យទទួលនោះនឹងធ្វើការពិនិត្យ និងដំណើរការចំពោះសំណុំលិខិតស្នើសុំអន្តរជាតិនោះបន្ត។ ការិយាល័យទទួលសំណុំលិខិតស្នើសុំអន្តរជាតិ អាចជាការិយាល័យចុះបញ្ជីជាតិ ឬការិយាល័យចុះបញ្ជីតំបន់ ឬ ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកហើយសំណុំលិខិតអន្តរជាតិនោះ ត្រូវគោរពតាមលក្ខខណ្ឌ ដូចនឹងលក្ខខណ្ឌនៃសំណុំលិខិតស្នើប្រកាសនីយបត្រតក្កកម្មជាតិផងដែរ ពោលគឺត្រូវមានពាក្យសុំ សេចក្ដីអត្ថាធិប្បាយអំពីតក្កកម្ម សេចក្ដីអះអាង ខ្លឹមសារសង្ខេប និងគំនូសបង្ហាញ (ករណីបើមាន)។

**ក-ពាក្យសុំ**

ដើម្បីដាក់សំណុំលិខិតស្នើសុំអន្តរជាតិ អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទតាមទម្រង់ដែលបានដាក់កំណត់ជាអន្តរជាតិសម្រាប់សមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT (ទម្រង់

[6] បញ្ជាក់៖ កាលបរិច្ឆេទទាមទារអាទិភាព គឺកាលបរិច្ឆេទបានទាមទារអាទិភាពចំពោះតក្កកម្មរបស់ខ្លួនដែលទទួលបានការការពារកន្លងមក ក៏ប៉ុន្តែករណីសំណុំលិខិតស្នើសុំអន្តរជាតិពុំមានការទាមទារ នោះកាលបរិច្ឆេទទាមទារអាទិភាព គឺកាលបរិច្ឆេទទាមទារអាទិភាព គឺកាលបរិច្ឆេទនៃការចុះលេខសំណុំលិខិតស្នើសុំអន្តរជាតិ។

PCT/RO/101)ដែលទម្រង់នៃការដាក់ពាក្យសុំនេះ តម្រូវឲ្យអ្នកស្នើសុំត្រូវបង្ហាញព័ត៌មានអំពីសំណុំលិខិតស្នើសុំជាអន្តរជាតិលម្អិត។ ជាគោលការណ៍ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ពាក្យសុំត្រូវមានព័ត៌មានចាំបាច់ដូចខាងក្រោម៖

- ឈ្មោះ និងទិន្នន័យផ្សេងទៀតពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំ និងភ្នាក់ងារ ឬ អ្នកតំណាង(ប្រសិនបើមាន) ដូចជាអំពីអាសយដ្ឋាន សញ្ជាតិ ប្រទេស
- ចំណងជើងរបស់តក្កកម្មខ្លី និងច្បាស់លាស់ (គួរតែមានចាប់ពីពីរពាក្យទៅប្រាំពីរពាក្យ)
- ព្រមទាំងឈ្មោះ និងទិន្នន័យផ្សេងទៀត ពាក់ព័ន្ធនឹងតក្កកម្ម ដែលច្បាប់ជាតិរបស់រដ្ឋជ្រើសរើស ត្រូវឲ្យបញ្ជាក់នៅពេលលិខិតស្នើសុំជាតិ។[7]

**ខ-សេចក្តីអធិប្បាយអំពីតក្កកម្ម**

សេចក្តីអធិប្បាយគឺ ជាការពន្យល់អំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់ និងពេញលេញដើម្បីឲ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។ សេចក្តីអធិប្បាយអំពីតក្កកម្ម ត្រូវមានចំណុចសំខាន់ៗដូចខាងក្រោម៖

- មានចំណងជើងតក្កកម្ម និងអំពីជំនាញក្នុងវិស័យ ដែលយកទៅប្រើប្រាស់
- មានព័ត៌មានទូទៅអំពីបច្ចេកវិទ្យាពាក់ព័ន្ធនឹងតក្កកម្ម
- ពន្យល់អំពីបញ្ហាដែលកំពុងចួបប្រទះ ហើយបញ្ជាក់ថា តក្កកម្មនេះបានដោះស្រាយបញ្ហាកំពុងចួបប្រទះ និងឥទ្ធិពលជាវិជ្ជមានដល់សង្គម
- ពន្យល់សង្ខេបអំពីបច្ចេកទេសនៃការប្រើប្រាស់តក្កកម្មដែលល្អជាងគេ
- បញ្ជាក់ថាតក្កកម្មអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម។[8]

**គ-សេចក្តីអះអាង**

សេចក្តីអះអាង គឺជាការកំណត់ឲ្យបានច្បាស់លាស់ អំពីចំណុចដែលសុំឲ្យមានការការពារ ដូច្នេះសេចក្តីអះអាងត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ ក្បោះក្បាយ និងការពន្យល់នៅក្នុងសេចក្តីអធិប្បាយអំពីតក្កកម្ម។ ករណីបើសំណុំលិខិតស្នើសុំអន្តរជាតិនោះមានសេចក្តីអះអាងច្រើនជាងមួយ ត្រូវដាក់លេខជាលំដាប់នៃសេចក្តីអធិប្បាយអះអាងនោះ។[9]

[7] សន្ធិសញ្ញា PCT មាត្រា ៤(១),៤៣,៤៤,៤៥ និងវិធានក្រោមសន្ធិសញ្ញា PTC ប្រការ ៣,៤

[8] សន្ធិសញ្ញា PCT មាត្រា ៥

[9] សន្ធិសញ្ញា PCT មាត្រា ៦

ដោយសេចក្ដីអះអាងនេះ និងបង្ហាញអំពីវិសាលភាពដែលត្រូវការពារ ដូច្នេះសេចក្ដីអះអាងត្រូវបានបង្ហាញអំពីភាពចាំបាច់ និងសរសេរឲ្យក្បោះក្បាយ ច្បាស់លាស់អំពីលក្ខណៈបច្ចេកទេសដើម្បីបែងចែកឲ្យដាច់ពីតក្កកម្ម ដែលទទួលបានការការពាររួចមកហើយ និងបានបង្ហាញថាតក្កកម្មនេះមានជំហាននៃការបង្កើតថ្មី។[10]

**ឃ-គំនូសបង្ហាញ**

សំណុំលិខិតស្នើសុំអន្តរជាតិ ចាំបាច់ត្រូវមានគំនូសបង្ហាញ ដើម្បីពន្យល់អំពីតក្កកម្ម ដែលបានដាក់ពាក្យស្នើសុំនោះ។ ជាឧទាហរណ៍ គំនូសបង្ហាញចាំបាច់ត្រូវមាននៅក្នុងសំណុំលិខិតស្នើសុំជាពិសេស គឺតក្កកម្មពាក់ព័ន្ធ និងប្រព័ន្ធមេកានិច និងអគ្គិសនី ។ នៅក្នុងគំនូសបង្ហាញនេះ អ្នកដាក់ពាក្យស្នើសុំត្រូវមានដាក់លេខ និងពន្យល់អំពីតួនាទី និងដំណើរការរបស់តក្កកម្មឲ្យបានច្បាស់លាស់។[11]

**ខ-ខ្លឹមសារសង្ខេប**

ខ្លឹមសារសង្ខេប គឺជាសេចក្ដីសង្ខេបបច្ចេកទេសប្រើប្រាស់របស់តក្កកម្ម ក្នុងគោលបំណងពន្យល់ដោយសង្ខេប ច្បាស់លាស់អំពីការបង្កើត និងការប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសរបស់តក្កកម្មនោះ។ ខ្លឹមសារសង្ខេបត្រូវបានសរសេរឲ្យបានពី ៥០ ទៅ ១៥០ ពាក្យជាភាសាអង់គ្លេស។

## ២.១.២ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ

ដូចបានរៀបរាប់ខាងលើ ដើម្បីទទួលបានការការពារ អ្នកដាក់ពាក្យសុំត្រូវតែដាក់សំណុំលិខិតស្នើសុំអន្តរជាតិ នៅការិយាល័យទទួល ដែលការិយាល័យនោះ គឺការិយាល័យកម្រិតជាតិ ការិយាល័យកម្រិតតំបន់ ឬការិយាល័យអន្តរជាតិនៃអង្គការសិទ្ធិបញ្ញាពិភពលោក។ ក្នុងករណី អ្នកដាក់ពាក្យសុំជាពលរដ្ឋនៃប្រទេសដែលជាសមាជិកសន្ធិសញ្ញាតក្កកម្មថ្នាក់តំបន់ដូចជាពិធីសារ ARIPO Harare អនុសញ្ញាតក្កកម្មអាស៊ីអឺរ៉ុប អនុសញ្ញាតក្កកម្មអឺរ៉ុប ឬកិច្ចព្រមព្រៀង OAPI Bangui អ្នកដាក់ពាក្យសុំនោះ អាចដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅការិយាល័យទទួលថ្នាក់តំបន់នោះបាន។

**ក-ការិយាល័យទទួល**

ការិយាល័យទទួល គឺជាការិយាល័យដែលមានសមត្ថភាពទទួលសំណុំលិខិតស្នើសុំចុះបញ្ជីក្រោមនីតិវិធីនៃសន្ធិសញ្ញា PCT ទទួលថវិកាពាក់ព័ន្ធ និងការចុះបញ្ជី និងត្រួតពិនិត្យលើសំណុំលិខិតស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់សន្ធិសញ្ញា PCT ដើម្បីទទួលបានការចុះបញ្ជីជាអន្តរជាតិ។[12]

[10] សន្ធិសញ្ញា PCT មាត្រា ៦

[11] សន្ធិសញ្ញា PCT មាត្រា ៧ និង ៨

[12] សន្ធិសញ្ញា PCT មាត្រា ១០

វិធានស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT បានកំណត់ពីការិយាល័យទទួលគឺអាចជា៖

- ការិយាល័យចុះបញ្ជីជាតិ នៃប្រទេសហត្ថលេខី
- ប្រទេសហត្ថលេខីមួយនៃសន្ធិសញ្ញា PCT បានព្រមព្រៀងជាមួយនឹងប្រទេសហត្ថលេខីសន្ធិសញ្ញា PCT ឬ អង្គការអន្តររដ្ឋាភិបាលមួយថា ការិយាល័យចុះបញ្ជីជាតិរបស់ខ្លួន គឺជាការិយាល័យទទួលជំនួសឲ្យរដ្ឋហត្ថលេខី ឬ អង្គការអន្តររដ្ឋាភិបាល ដែលស្នើសុំនោះ
- ការិយាល័យអន្តរជាតិ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។[13]

**ខ- ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ**

ដើម្បីពិនិត្យសំណុំលិខិតស្នើសុំ ការិយាល័យទទួលត្រូវត្រួតពិនិត្យមើលលើចំណុចពីរសំខាន់ដោយទី១ ពិនិត្យលើលក្ខខណ្ឌដើម្បីទទួលកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ ទី២ភាពខ្វះចន្លោះដ៏ជាក់លាក់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ។

ការិយាល័យទទួល ត្រូវចុះកាលបរិច្ឆេទនៃការចុះបញ្ជីលើសំណុំលិខិតស្នើសុំអន្តរជាតិនៅពេលសំណុំលិខិតនេះបានបំពេញតាមលក្ខខណ្ឌខាងក្រោមត្រឹមត្រូវ៖

- អ្នកដាក់ពាក្យសុំ មានអាសយដ្ឋាន ឬសញ្ជាតិនៃប្រទេសជាសមាជិកសន្ធិសញ្ញា PCT
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវធ្វើជាភាសា ដែលបានកំណត់
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវមានយ៉ាងហោចណាស់នូវធាតុទាំងឡាយដូចតទៅ :
  - ការបញ្ជាក់ថា សំណុំលិខិតស្នើសុំនេះត្រូវបានគ្រោងទុកសំណុំលិខិតស្នើសុំអន្តរជាតិ
  - មានការជ្រើសរើសយ៉ាងហោចណាស់ក៏មានហត្ថលេខីមួយ
  - មានឈ្មោះរបស់អ្នកដាក់ពាក្យសុំយ៉ាងតិចម្នាក់
  - មានផ្នែកមួយ នៃសេចក្តីអធិប្បាយ និង
  - មានផ្នែកមួយ នៃសេចក្តីអះអាង។[14]

ករណីបើសំណុំលិខិតស្នើសុំមិនបានបំពេញលក្ខខណ្ឌខាងលើនេះ ការិយាល័យទទួលនឹងអញ្ជើញអ្នកដាក់ពាក្យសុំឲ្យមកកែតម្រូវក្នុងរយៈពេល ០២ខែ បន្ទាប់ពីចេញលិខិតអញ្ជើញកែតម្រូវ ហើយការកំណត់កាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ គឺនៅពេលអ្នកដាក់ពាក្យស្នើសុំបានបំពេញបែបបទត្រឹមត្រូវ និងចប់សព្វគ្រប់តាមលក្ខខណ្ឌដែលបានកំណត់។

[13] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ១៩

[14] សន្ធិសញ្ញា PCT មាត្រា ១១

បន្ទាប់ពីបានពិនិត្យលើចំណុចដូចមានការកំណត់ក្នុងចំណុចទី១ ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិក៏ត្រូវផ្អែកតាម ការិយាល័យទទួលក៏នឹងត្រូវពិនិត្យលើភាពខ្វះចន្លោះរបស់សំណុំលិខិតស្នើសុំអន្តរជាតិដូចខាងក្រោម៖

- មិនមានការចុះហត្ថលេខា
- មិនមានការបញ្ជាក់ដូចបានកំណត់ពាក់ព័ន្ធនឹងអ្នកដាក់ស្នើសុំ
- មិនមានចំណងជើងតក្កកម្ម
- មិនមានខ្លឹមសារសង្ខេប
- មិនបានបំពេញតាមការកំណត់ក្នុងបទបញ្ជា ព្រមទាំងការតម្រូវរូបសាស្ត្រ។[15]

ក្នុងករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌខាងលើ ការិយាល័យទទួលនឹងអញ្ជើញអ្នកដាក់ពាក្យសុំមកកែតម្រូវក្នុងរយៈពេលកំណត់ តែការឲ្យមកកែតម្រូវនេះនឹងមិនប៉ះពាល់ដល់កាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ PCT ទេ។ ក៏ប៉ុន្តែក្នុងករណីមានការខកខានមិនបានកែតម្រូវក្នុងពេលកំណត់នោះ សំណុំលិខិតស្នើសុំអន្តរជាតិនោះត្រូវចាត់ទុកថា បានដកយកពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT។

ជាចុងក្រោយនៅពេលទទួលបានកាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ការិយាល័យទទួលនឹងធ្វើសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ និងលេខលិខិតស្នើសុំអន្តរជាតិទៅឲ្យអ្នកដាក់ពាក្យសុំបានដឹង។

**គ.ការទាមទារអាទិភាព**

ជាធម្មតា សំណុំលិខិតស្នើសុំអន្តរជាតិអាចមានការទាមទារអាទិភាពចំពោះតក្កកម្មរបស់ខ្លួនដែលទទួលបានការការពារកន្លងមក។ ដូច្នេះអ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាព ដោយបញ្ជាក់ឲ្យច្បាស់អំពីប្រទេសដែលបានចុះបញ្ជី អំពីកាលបរិច្ឆេទនៃការចុះលេខសំណុំលិខិត និងអំពីការិយាល័យទទួល។

អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាពក្នុងរយៈពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចុះលេខលើសំណុំលិខិតលើកដំបូង។ ជាគោលការណ៍ អ្នកដាក់ពាក្យសុំត្រូវដាក់សំណុំលិខិតស្នើសុំអន្តរជាតិ និងទាមទារសិទ្ធិអាទិភាពក្នុងរយៈពេល១២ខែខាងលើ ដើម្បីរក្សាសិទ្ធិក្នុងការទាមទារសិទ្ធិ។

ទោះបីជាយ៉ាងណា ករណីដែលដាក់ពាក្យសុំមិនដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ក្នុងរយៈពេលកំណត់ ១២ ខែទេ អ្នកដាក់ពាក្យសុំអាចស្នើសុំទាមទារឲ្យផ្តល់អាទិភាពម្តងទៀត ក្នុងរយៈពេល០២ខែគិតចាប់ពី

[15] សន្ធិសញ្ញា PCT មាត្រា ១៤

កាលបរិច្ឆេទនៃការកំណត់រយៈពេលទាមទារអាទិភាព។ ដូចនេះអ្នកដាក់ពាក្យសុំត្រូវឲ្យធ្វើសេចក្តីថ្លែងការណ៍ ឬភស្តុតាងដើម្បីបញ្ជាក់ពីមូលហេតុដែលមិនបានដាក់សំណុំលិខិតស្នើសុំអន្តរជាតិទាន់ពេលវេលាកំណត់។[16]

**ឃ.ឯកសារទាមទារសិទ្ធិអាទិភាព**

អ្នកដាក់ពាក្យសុំត្រូវប្រគល់ឯកសារស្នើសុំដំបូង ទៅការិយាល័យទទួលបន្ទុកក្នុងរយៈពេល ១៦ខែ គិតចាប់ពីថ្ងៃទទួលអាទិភាពដំបូង។

ប្រសិនបើឯកសារទាមទារអាទិភាពចេញដោយការិយាល័យទទួល ដូច្នេះអ្នកដាក់ពាក្យសុំត្រូវស្នើឲ្យការិយាល័យទទួលរៀបចំឯកសារទាមទារអាទិភាព និងបញ្ជូនឯកសារទាំងនោះទៅការិយាល័យអន្តរជាតិ នៅក្នុងរយៈពេល ១៦ខែ និងឲ្យបានមុនការបោះផ្សាយអន្តរជាតិ។

**ង.ភាសាប្រើប្រាស់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ**

ភាសាដែលប្រើប្រាស់ជាផ្លូវការសម្រាប់សំណុំលិខិតស្នើអន្តរជាតិ ត្រូវតែជា៖

- ភាសាដែលទទួលស្គាល់ដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ
- ភាសាសម្រាប់បោះពុម្ពផ្សាយ មានដូចជា ភាសាអារ៉ាប់ ភាសាចិន ភាសាអង់គ្លេស ភាសាបារាំង ភាសាអាល្លឺម៉ង់ ភាសាជប៉ុន ភាសាកូរ៉េ ភាសាព័រទុយហ្គាល់ ឬភាសាអេស្បាញ ឬ
- ភាសាដែលទទួលស្គាល់ដោយការិយាល័យទទួល។

ករណីដែលសំណុំលិខិតត្រូវស្នើសុំអន្តរជាតិមិនបានប្រើប្រាស់ភាសា ដែលបានកំណត់តាមលក្ខខណ្ឌខាងលើ អ្នកដាក់ពាក្យសុំត្រូវបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាដែលកំណត់ក្នុងរយៈពេល ០១ ខែ បន្ទាប់ពីការិយាល័យទទួលបាននូវសំណុំលិខិតស្នើសុំអន្តរជាតិនោះ។ ប្រសិនបើមិនបានបកប្រែឲ្យទាន់ពេលវេលាកំណត់នោះទេ ការិយាល័យទទួលនឹងប្រកាសថាសំណុំលិខិតស្នើសុំអន្តរជាតិនោះនឹងត្រូវដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT)។[17]

**ច.ការបកប្រែ**

ថ្លៃសេវា នៃការចុះបញ្ជីប្រកាសសនីយបត្រតក្កកម្មតាម សន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម (PCT) បើប្រៀបធៀបទៅនឹងថ្លៃប្រកាសនីយបត្រតក្កកម្មសរុប ថ្លៃដើមចម្បងដែលគិតដោយ WIPO គឺជាថ្លៃឯកសារអន្តរជាតិចំនួន ១,៣៣០ CHF ឬ យើងអាចគិតជាដុល្លារស្មើ ១,៤៨០ ដុល្លារ ថ្លៃសេវានេះគឺតំណាងឲ្យផ្នែកតូចមួយនៃប្រកាសនីយបត្រតក្កកម្មរួមតែប៉ុណ្ណោះ។ ចំណែកចំណុចដាច់ដោយឡែកពីនេះ គឺជាថ្លៃសេវាដែលគិតដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងការពិនិត្យបឋម និងភាគច្រើននៃការចំណាយទាក់ទង

[16] សន្ធិសញ្ញា PCT មាត្រា ៨,២ (ខ)

[17] សន្ធិសញ្ញា PCT មាត្រា ៣ និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៨.៣

ជាមួយនឹងការបកប្រែ កម្រៃសេវាជាតិ ព្រមទាំងកម្រៃសេវាមេធាវី គឺជាកម្រៃផ្លូវការដែលគិតដោយការិយាល័យប្រកាសនីយបត្រតក្កកម្ម ឬតំបន់។

អ្នកដាក់ពាក្យ ត្រូវបង់កម្រៃមួយចំនួន ដើម្បីចុះបញ្ជីអន្តរជាតិទៅការិយាល័យទទួលដូចខាងក្រោម

- កម្រៃបញ្ជូនឯកសារ
- កម្រៃចុះបញ្ជីអន្តរជាតិ
- កម្រៃស្រាវជ្រាវ
- កម្រៃក្រដាសបន្ថែម
- កម្រៃនៃការកែសម្រួលឯកសារយឺត
- កម្រៃសម្រាប់ទាមទារសិទ្ធិអាទិភាពម្តងទៀត
- កម្រៃឯកសារថតចម្លងនានា។[18]

## ២.២ ការស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ




*(របាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ត្រូវរៀបចំក្នុងរយៈពេល១៦ ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព)*

[18] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ១៤,១៥,១៦,១៧

នៅក្នុងដំណាក់កាលនេះ បន្ទាប់ពីទទួលបានច្បាប់ចម្លង សម្រាប់ស្រាវជ្រាវពីការិយាល័យទទួល អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងអនុវត្តនីតិវិធីចំនួន ០៣ សំខាន់ៗគឺ ការស្រាវជ្រាវអន្តរជាតិ(២.២.១)បន្ទាប់មកទៀតត្រូវរៀបចំរបាយការណ៍ស្រាវជ្រាវអន្តរជាតិ(២.២.២)និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ(២.២.៣)។

ជាធម្មតា ការិយាល័យទទួលត្រូវជ្រើសរើសអាជ្ញាធរស្រាវជ្រាវអន្តរជាតិយ៉ាងតិចមួយ ដើម្បីស្រាវជ្រាវអន្តរជាតិ និងចេញរបាយការណ៍ស្រាវជ្រាវដល់អ្នកដាក់ពាក្យសុំ ក្នុងរយៈពេល១៦ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ អ្នកដាក់ពាក្យសុំនឹងទទួលបានរបាយការណ៍ស្រាវជ្រាវជាអន្តរជាតិដែលទទួលស្គាល់ដោយការិយាល័យទទួល ដែលបច្ចុប្បន្នអាជ្ញាធរអន្តរជាតិទាំងនោះមានចំនួន ១៩ រួមមានៈ ១.ការិយាល័យតក្កកម្មអូស្ត្រាលី ២.ការិយាល័យតក្កកម្មអូទ្រីស ៣.វិទ្យាស្ថានជាតិកម្មសិទ្ធិឧស្សាហកម្មប្រេស៊ីល ៤.ការិយាល័យកម្មសិទ្ធិបញ្ញាកាណាដា ៥.ការិយាល័យតក្កកម្មអេហ្ស៊ីប ៦.ការិយាល័យតក្កកម្មអឺរ៉ុប ៧.សេវាកម្មសហព័ន្ធរុស្ស៊ីសម្រាប់កម្មសិទ្ធិបញ្ញា ៨.ការិយាល័យតក្កកម្មឥណ្ឌា ៩.ការិយាល័យកម្មសិទ្ធិបញ្ញាសិង្ហបូរី ១០.ការិយាល័យតក្កកម្មអ៊ីស្រាអែល ១១.ការិយាល័យប្រកាសនីយបត្រជប៉ុន ១២.ការិយាល័យកម្មសិទ្ធិបញ្ញាកូរ៉េ ១៣.ក្រុមប្រឹក្សាជាតិ និងចុះបញ្ជីហ្វាំងឡង់ ១៤.វិទ្យាស្ថានជាតិកម្មសិទ្ធិឧស្សាហកម្មឈីលី ១៥.វិទ្យាស្ថានជាតិប្រកាសនីយបត្រតក្កកម្មណ័រឌិក ១៦.ការិយាល័យតក្កកម្ម និងម៉ាកអេស្ប៉ាញ ១៧.ការិយាល័យកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋប្រជាមានិតចិន ១៨.ការិយាល័យតក្កកម្មស៊ុយអ៊ែត និងចុះបញ្ជី ១៩.ការិយាល័យតក្កកម្ម និងម៉ាកសហរដ្ឋអាមេរិក។

### ២.២.១ ការស្រាវជ្រាវអន្តរជាតិ

គោលបំណងនៃការស្រាវជ្រាវអន្តរជាតិ គឺដើម្បីស្វែងរកស្នាដៃមុនៗ (prior art) ដែលធ្លាប់បានចុះបញ្ជីពីមុនមក ដើម្បីធានាសំណើតក្កកម្មកំពុងស្នើសុំ គឺថ្មីមានជំហាននៃការរកឃើញថ្មី។ ដូច្នេះអាជ្ញារធរស្រាវជ្រាវអន្តរជាតិ ត្រូវខំប្រឹងស្វែងរកស្នាដៃមុន ដែលពាក់ព័ន្ធឲ្យបានច្រើនតាមលទ្ធភាពរបស់ខ្លួន(is facilties permit) ។[19]

ការស្រាវជ្រាវអន្តរជាតិ គឺផ្អែកលើឯកសារសំខាន់មួយដែលមានឈ្មោះថា PCT minimum documentation ដែលជាប្រភេទឯកសារចងក្រងការបោះពុម្ពផ្សាយតក្កកម្ម ដែលចេញដោយប្រទេសចិនចាប់ពីឆ្នាំ ១៩២០ ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ចាប់ពីឆ្នាំ ១៩៤៥ ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសរុស្ស៊ី ប្រទេសស្វីស ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អង្គការកម្មសិទ្ធិបញ្ញាទ្វីបអាហ្វ្រិក អង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិក និងការិយាល័យចុះបញ្ជីតក្កកម្មអាស៊ី និងអឺរ៉ុប។ PCT minimum documentation ក៏មានចង

[19] សន្ធិសញ្ញា PCT មាត្រា ១៥ (ក) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៣៨.១

ក្រងនូវសៀវភៅផ្សព្វផ្សាយអំពីពាក្យសុំចុះបញ្ជីតក្កកម្ម ដែលចេញដោយការិយាល័យអន្តរជាតិ និងដោយប្រទេសដទៃទៀតចាប់ពីឆ្នាំ១៩២០ មកផងដែរ។[20]

**ក.កម្មវត្ថុ ដែលដកចេញពីការស្រាវជ្រាវអន្តរជាតិ**

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងមិនស្រាវជ្រាវអន្តរជាតិនោះទេ ករណីសំណើតក្កកម្ម ស្ថិតក្នុងប្រភេទទាំង៦ដូចខាងក្រោម៖

- ទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា
- រុក្ខជាតិ ឬ សត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើត តាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មរុក្ខជាតិ ឬ សត្វ
- គម្រោងការ ក្បួន ឬ វិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត
- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬ សត្វ ដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្តលើរាងកាយមនុស្ស ឬសត្វ
- បទបង្ហាញនៃព័ត៌មានដ៏កម្រ និង
- កម្មវិធីកុំព្យូទ័រ។[21]

**ខ.ការរួមបញ្ចូលនៃតក្កកម្ម**

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងពិនិត្យលើសំណុំលិខិតស្នើសុំអន្តរជាតិ ថាតើមានបំពេញតាមលក្ខខណ្ឌការរួមបញ្ចូលនៃតក្កកម្ម (Unity of Invention)។ ការរួមបញ្ចូលនៃតក្កកម្ម គឺសម្តៅថាតើសំណុំលិខិតស្នើសុំអន្តរជាតិ មានតក្កកម្ម ឬ ក្រុមនៃតក្កកម្ម ដែលមានបច្ចេកទេសប្រហាក់ប្រហែលគ្នា ដើម្បីបង្ហាញថាមានជំហ៊ាននៃការបង្កើតថ្មី។

ករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិរកឃើញថាខ្វះការរួមបញ្ចូលនៃតក្កកម្ម អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវអញ្ជើញអ្នកដាក់ពាក្យសុំឲ្យបង់កម្រៃបន្ថែមចំពោះការស្រាវជ្រាវបន្ថែមតក្កកម្មនោះ ក្នុងរយៈពេល ០១ខែ គិតចាប់ពីកាលបរិច្ឆេទដែលបានចេញលិខិតអញ្ជើញ។ របាយការណ៍ស្រាវជ្រាវអន្តរជាតិនឹងមិនត្រូវបានរៀបចំ ល្គឹកណាការបង់កម្រៃស្រាវជ្រាវ និងកម្រៃស្រាវជ្រាវបន្ថែម ត្រូវបានបង់ចប់សព្វគ្រប់[22]។

[20] សន្ធិសញ្ញា PCT មាត្រា ១៥

[21] សន្ធិសញ្ញា PCT មាត្រា ១៧.២ និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៣៩.១

[22] សន្ធិសញ្ញា PCT មាត្រា ១៧ និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ១៣, ៤០

### ២.២.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិ

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងចេញរបាយករណ៍ស្រាវជ្រាវអន្តរជាតិក្នុងរយៈពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទបានទទួលច្បាប់ចម្លងសម្រាប់ស្រាវជ្រាវពីការិយាល័យទទួល នៅក្នុងរយៈពេល ០៩ខែ (ប្រាំបួនខែ) គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ របាយការណ៍នេះនឹងបង្ហាញអំពីឯកសារគាំទ្រតក្កកម្មដែលពាក់ព័ន្ធ (Citation) ចំណាត់ថ្នាក់កម្មវត្ថុតក្កកម្មស្របតាមចំណាត់ថ្នាក់តក្កកម្មអន្តរជាតិ (International Patent Classification) និងការបញ្ជាក់អំពីប្រភេទនៃការស្រាវជ្រាវ (Field of Search) និង ប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវបាន (Electronic Data)។ គួរបញ្ជាក់ផងដែរថា នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិមិនត្រូវបង្ហាញទស្សនៈ ហេតុផល ឬ ការពន្យល់ណាមួយលើលទ្ធផលនៃការស្រាវជ្រាវនោះទេ[23]។

### ២.២.៣ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ

នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិនោះ អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរបឋម ក៏ប៉ុន្តែមិនចងកាតព្វកិច្ច ដោយវាយតម្លៃលើលក្ខខណ្ឌចំនួន ០៣គឺ ១.អំពីភាពថ្មី ២. អំពីភាពជំហាននៃការរកឃើញថ្មី ៣.អាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មនៃតក្កកម្មដែលបានរកឃើញនោះ។

ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរនេះ ត្រូវសរសេរភាសាឲ្យដូចទៅនឹងភាសារបស់របាយការណ៍ស្រាវជ្រាវអន្តរជាតិ ហើយត្រូវផ្ញើទៅអ្នកដាក់ពាក្យសុំ និងការិយាល័យទទួល ព្រមជាមួយនឹងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ។ ទាំងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ត្រូវធ្វើក្នុងរយៈពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទទទួលច្បាប់ចម្លងសម្រាប់ស្រាវជ្រាវ ឬ ក្នុងរយៈពេល ០៩ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ក៏អាចរកបានតាមប្រព័ន្ធ PATENSCOPE[24] នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបោះផ្សាយ។

#### ក.ការឆ្លើយតប និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ

ទោះក្នុងបទប្បញ្ញត្តិនៃ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) មិនបានចែងកំណត់ជាក់លាក់អនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំអាចឆ្លើយតបជាមួយនឹងការផ្តល់យោបល់ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិក៏ដោយក៏នៅក្នុងការអនុវត្តជាក់ស្តែងអ្នកដាក់ពាក្យសុំអាចឆ្លើយតបនឹងការផ្តល់យោបល់

[23] សន្ធិសញ្ញា PCT មាត្រា ១៨ និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤២, ៤៣

[24] គឺជាសេវាកម្មរបស់ WIPO ដែលអនុញ្ញាតឲ្យចូលមើលព័ត៌មានបច្ចេកទេសរបស់សំណុំលិខិតស្នើសុំអន្តរជាតិ ដែលបានចុះផ្សាយកន្លងមក

នោះបាន។ រាល់ការឆ្លើយតបទាំងអស់នោះ ត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធ PATENTSCOPE ដោយការិយាល័យអន្តរជាតិ[25]។

**ខ.ការកែសម្រួលការអះអាងនៅចំពោះមុខការិយាល័យអន្តរជាតិ**

បន្ទាប់ពីបានទទួលរបាយការណ៍ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរស្រាវជ្រាវ អ្នកដាក់ពាក្យសុំអាចកែសម្រួលការអះអាងរបស់ខ្លួនបាន ផ្អែកតាមនីតិវិធីនៃជំពូកទី១ នៃសន្ធិសញ្ញា PCT នេះ។ ក៏ប៉ុន្តែនៅក្នុងករណីដែលអ្នកដាក់ពាក្យសុំបានដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ អ្នកដាក់ពាក្យសុំមានឱកាសកែសម្រួលការអះអាងរបស់ខ្លួនម្តងទៀត។ ជាមួយគ្នានោះ អ្នកដាក់ពាក្យសុំអាចដាក់សេចក្តីថ្លែងបញ្ជាក់សង្ខេប ដែលមាននៅលើសេចក្តីអធិប្បាយ និងគំនូសបង្ហាញ។ ការកែសម្រួលនោះ មិនត្រូវឲ្យហួសពីការបញ្ចេញឲ្យដឹងក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នោះទេ។

ផ្អែកតាមមាត្រា ១៩ នៃសន្ធិសញ្ញា PCT រយៈពេលនៃការកែសម្រួលជាធម្មតាមិនលើសពី ០២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនរបាយការណ៍ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ពីអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេ ឬ ក្នុងរយៈពេល ១៦ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទារអាទិភាព។ ករណីចង់មានការកែប្រែសម្រួលនេះ ត្រូវដាក់ដោយផ្ទាល់នៅការិយាល័យអន្តរជាតិ មិនមែននៅអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេ។

**គ.ទំនាក់ទំនងរវាងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ និងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ**

ករណីអ្នកដាក់ពាក្យសុំមិនដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ (នឹងសិក្សានៅចំណុច ២.៥ បន្ទាប់) នោះការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងប្រែក្លាយជារបាយការណ៍ជំហ៊ានដំបូងអន្តរជាតិ ស្តីអំពីភាពទទួលបានប្រកាសនីយបត្រតក្កកម្មដែលនឹងចេញដោយការិយាល័យអន្តរជាតិ ហើយនឹងត្រូវផ្ញើទៅគ្រប់ការិយាល័យជ្រើសរើស។ របាយការណ៍ត្រួតពិនិត្យដំបូងអន្តរជាតិស្តីពីភាពទទួលបានប្រកាសនីយបត្រតក្កកម្ម នឹងផ្សព្វផ្សាយនៅក្នុងប្រព័ន្ធ PATENSCOPE ដល់សាធារណៈជន។

ប្រសិនបើមានការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ អាជ្ញាធរត្រួតពិនិត្យជំហានអន្តរជាតិនឹងប្រើប្រាស់ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិជាយោបល់បឋមរបស់ខ្លួន។[26]

[25] សន្ធិសញ្ញា PCT មាត្រា ១៨ (១) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤២ ៤៣ ៤៤

[26] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៤

## ២.៣ ការចុះផ្សាយអន្តរជាតិ




ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺជាអង្គភាពដែលទទួលខុសត្រូវក្នុងការចុះផ្សាយអន្តរជាតិនូវរាល់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម តាមនីតិវិធីនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ហើយការចុះផ្សាយអន្តរជាតិនេះ ត្រូវធ្វើភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ក្នុងរយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទាមទារអាទិភាព[27]។

### ២.៣.១ អានុភាពនៃការចុះផ្សាយអន្តរជាតិ

ការចុះផ្សាយអន្តរជាតិនឹងឲ្យមានការការពារនៅតាមបណ្តាប្រទេសជាសមាជិកនៃសន្ធិសញ្ញា PCT ករណីសំណុំលិខិតស្នើសុំអន្តរជាតិនោះទទួលការការពារ។ ការការពារអាចនឹងមានអានុភាពនៅពេលៈ

- បានផ្តល់ការបកប្រែជាភាសាអង់គ្លេស ដោយការិយាល័យអន្តរជាតិ ករណីសំណុំលិខិតស្នើសុំអន្តរជាតិមិនដាក់ជាភាសាអង់គ្លេស។ ករណីដែលសំណុំលិខិតដាក់មកភាសាដែលមិនទទួលស្គាល់ អ្នកដាក់ពាក្យសុំត្រូវដាក់មកជាភាសាដែលទទួលស្គាល់ជាផ្លូវការ
- បានទទួលដោយការិយាល័យចុះបញ្ជីនៃប្រទេសជ្រើសរើស នូវច្បាប់ចតចម្លងនៃការបោះពុម្ពផ្សាយតក្កកម្មដែលចុះបញ្ជីតាមនីតិវិធីសន្ធិសញ្ញា PCT និង
- បានបោះពុម្ពផ្សាយបន្ទាប់ពីការផុតកំណត់នៃរយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ។[28]

[27] សន្ធិសញ្ញា PCT មាត្រា ២១ (២) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៨ (២) (៤)
[28] សន្ធិសញ្ញា PCT មាត្រា ២៩

រាល់ការចុះសំណុំលិខិតឯកសារស្នើចុះបញ្ជីតាមនីតិវិធីសន្ធិសញ្ញា PCT នឹងត្រូវចុះផ្សាយក្នុងប្រព័ន្ធ PATENSCOPE[29] ដើម្បីឲ្យតតិយជនអាចពិនិត្យ និងប្រឹក្សាបាន។ តតិយជនមានឱកាសតាមដានតាមរយៈប្រព័ន្ធអ៊ីនធឺណេតនេះ និងអាចបញ្ចូលតក្កកម្មរបស់ពួកគេពីមុនបាន ឲ្យអ្នកដាក់ពាក្យសុំដឹងបាន។

### ២.៣.២ ភាសានៃការចុះផ្សាយអន្តរជាតិ

ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិដាក់ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង ជប៉ុន អាល្លឺម៉ង់ កូរ៉េខាងត្បូង ព័រទុយហ្កាល់ រុស្សី ឬ អេស្ប៉ាញ នោះការចុះផ្សាយអន្តរជាតិ ក៏ជាភាសាដូចនឹងសំណុំលិខិតស្នើសុំអន្តរជាតិដែរ ក៏ប៉ុន្តែសំណុំលិខិតស្នើសុំអន្តរជាតិនោះដូចជាចំណងជើងតក្កកម្មសេចក្តីសង្ខេប និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ត្រូវបកប្រែជាភាសាអង់គ្លេស ដោយការិយាល័យអន្តរជាតិ[30]។

## ២.៤ ការស្រាវជ្រាវអន្តរជាតិបន្ថែម និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម

អ្នកដាក់ពាក្យសុំមានជម្រើសមួយទៀតបន្ថែមលើការស្រាវជ្រាវអន្តរជាតិ គឺការស្រាវជ្រាវជាអន្តរជាតិបន្ថែម ដែលស្រាវជ្រាវដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិមួយផ្សេងទៀត។ គោលបំណងនៃការស្រាវជ្រាវអន្តរជាតិបន្ថែមនេះ គឺដើម្បីផ្តល់ឲ្យមានការបំពេញបន្ថែមនៃការស្រាវជ្រាវស្វែងរកស្នាដៃដែលមានពីមុនមកឲ្យកាន់តែទូលំទូលាយអ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យស្នើសុំការស្រាវជ្រាវអន្តរជាតិបន្ថែម ក្នុងរយៈពេល ១៩ខែ គិតចាប់ពីកាលបរិច្ឆេទការទាមទារអាទិភាព។




[29] Patent Scope គឺជាប្រព័ន្ធនៃការស្វែងរកទិន្នន័យរួមមួយដែលផ្តល់ឲ្យតក្កករអាចចូលទៅស្វែងរកតក្កកម្មដែលបានចុះបញ្ជីជាអន្តរជាតិនៅក្នុងសន្ធិសញ្ញា PCT

[30] សន្ធិសញ្ញា PCT មាត្រា ២១ (៤) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៥៥.១ ៤៨.៣ (ខ)

### ២.៤.១ នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម

អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យស្នើសុំការស្រាវជ្រាវអន្តរជាតិបន្ថែម នៅការិយាល័យអន្តរជាតិក្នុងរយៈពេល ០៩ខែ គិតចាប់ពីកាលបរិច្ឆេទការទាមទារអាទិភាព និងត្រូវបង់កម្រៃតាមការកំណត់ក្នុងរយៈពេល ០១ខែ បន្ទាប់ពីបានដាក់ពាក្យសុំ។ បន្ទាប់មក ការិយាល័យអន្តជាតិនឹងបញ្ជូនសំណុំឯកសារច្បាប់ចម្លងសម្រាប់ការស្រាវជ្រាវបន្ថែមទៅអាជ្ញាធរស្រាវជ្រាវអន្តរជាតិមួយផ្សេងទៀត ខុសពីអាជ្ញាធរដែលបានស្រាវជ្រាវអន្តរជាតិមុន។ សំណុំឯកសារច្បាប់ចម្លងសម្រាប់ការស្រាវជ្រាវបន្ថែមដែលត្រូវបញ្ជូនមានដូចជា៖

- ពាក្យស្នើសុំការស្រាវជ្រាវបន្ថែម
- សំណុំលិខិតស្នើសុំអន្តរជាតិ
- ច្បាប់ចម្លងអេឡិចត្រូនិចនៃការចុះលេខបន្តបន្ទាប់
- រាល់ឯកសារបកប្រែដែលបានប្រើសម្រាប់ការស្រាវជ្រាវបន្ថែម
- របាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ
- លិខិតអញ្ជើញចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិឲ្យបង់កម្រៃស្រាវជ្រាវបន្ថែម និង
- រាល់ការជំទាស់នានារបស់អ្នកដាក់ពាក្យសុំលើការស្រាវជ្រាវរបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ
- បន្ទាប់ពីទទួលបានឯកសារពាក់ព័ន្ធខាងលើចប់សព្វគ្រប់ពីការិយាល័យអន្តរជាតិ អាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមនឹងចាប់ផ្តើមការងាររបស់ខ្លួន ឲ្យបានមុនកាលបរិច្ឆេទបញ្ចប់ នៃរយៈពេល២២ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។[31]

ករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិចម្បងបានរកឃើញថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម ហើយអ្នកដាក់ពាក្យសុំមិនបានបង់កម្រៃស្រាវជ្រាវអន្តរជាតិបន្ថែម ដូច្នេះអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមមិនចាំបាច់ស្រាវជ្រាវបន្ថែមទៀតនោះទេ។ ទោះបីជាយ៉ាងណា ចំណុចនេះមិនបានចងនូវកាតព្វកិច្ចមិនឲ្យអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមស្រាវជ្រាវនោះទេ អាជ្ញាធរនោះអាចស្រាវជ្រាវថាតក្កកម្មកំពុងស្នើសុំបានបំពេញលក្ខខណ្ឌនៃការរួមបញ្ចូលនៃតក្កកម្មបាន[32]។

ករណីដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមបានរកឃើញ សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម នោះអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមនឹងមិនឲ្យអ្នកដាក់ពាក្យសុំបង់កម្រៃនៃការស្រាវជ្រាវបន្ថែមនោះទេ ហើយអាជ្ញាធរនោះនឹងរៀបចំរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម ហើយជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីការយល់ឃើញរបស់ខ្លួន សំណុំលិខិតស្នើសុំអន្តរជាតិមិនបាន

[31] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៥ ចំណុច ៥ (ក)

[32] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ១៣ ចំណុច ៥ (ឆ)

បំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម។ ជាមួយគ្នានេះអ្នកដាក់ពាក្យសុំនោះ អាចស្នើសុំឲ្យអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមនោះពិនិត្យបន្ថែមចំពោះការផ្តល់យោបល់នោះ ដោយមានការបង់កម្រៃបន្ថែម[33]។

### ២.៤.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម

អាជ្ញាធរដែលបានជ្រើសរើសឲ្យស្រាវជ្រាវអន្តរជាតិបន្ថែមនឹងត្រូវចេញរបាយការណ៍ស្រាវជ្រាវបន្ថែមនៅក្នុងរយៈពេល ២៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ហើយរបាយការណ៍នេះមានតម្លៃស្មើនឹងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ។

ជាទូទៅរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែមនឹងធ្វើការពន្យល់យ៉ាងជាក់លាក់ លើឯកសារគាំទ្រ (Citations of Documents) លម្អិតជាងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិចម្បង ក្នុងគោលបំណងឲ្យយល់កាន់តែច្បាស់អំពីតក្កកម្មពីមុន (prior art)[34] ហើយមិនមានការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដូចរបាយការណ៍ស្រាវជ្រាវអន្តរជាតិចម្បងឡើយ។ បន្ទាប់ពីចេញរបាយការណ៍របស់ខ្លួនមួយច្បាប់ទៅអ្នកដាក់ពាក្យសុំ និងមួយច្បាប់ទៀតទៅការិយាល័យអន្តរជាតិ ដើម្បីឲ្យការិយាល័យអន្តរជាតិបញ្ជូនបន្តទៅការិយាល័យជ្រើសរើសរបស់អ្នកដាក់ពាក្យសុំ។

## ២.៥ ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិ និងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ




*(ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិត្រូវដាក់ទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិដែលមានសមត្ថកិច្ចក្នុងរយៈពេល ២២ ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព)*

---

[33] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៥ ចំណុច៦ (ក) (គ) (ឃ) (ង)

[34] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៤៥ ចំណុច ៧ (ឃ) (ង)

អ្នកដាក់ពាក្យសុំអាចពិចារណាជ្រើសរើសនីតិវិធីពិនិត្យជំហានដំបូងជាអន្តរជាតិនេះ ពីព្រោះនីតិវិធីនេះនឹងនាំឲ្យអ្នកដាក់ពាក្យសុំដឹងជាមុនដើម្បីធ្វើការកែសម្រួលសេចក្តីអត្ថាធិប្បាយ ការអះអាង និងគំនូសបង្ហាញនៃសំណុំឯកសារស្នើសុំរបស់ខ្លួនជៀសវាងការជំទាស់ការចុះបញ្ជីនៅការិយាល័យជាតិ ឬនាំឲ្យខាតពេលវេលាពេលក្រោយនៅក្នុងដំណាក់កាលកម្រិតជាតិ។

### ២.៥.១ នីតិវិធីនៃការពិនិត្យជំហានដំបូងអន្តរជាតិ

ករណីដែលអ្នកដាក់ពាក្យសុំមិនពេញចិត្តនឹង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ អ្នកដាក់ពាក្យសុំអាចសុំបន្តពិនិត្យលក្ខណៈវិនិច្ឆ័យនៃតក្កកម្មរបស់ខ្លួនក្រោមនីតិវិធីការពិនិត្យជំហានដំបូងអន្តរជាតិ។ ការពិនិត្យជំហានដំបូងអន្តរជាតិ គឺជានីតិវិធីដែលអ្នកដាក់ពាក្យសុំអាចជ្រើសរើស និងដាក់ពាក្យទាមទារ ដាច់ដោយឡែកពីសំណុំលិខិតស្នើសុំអន្តរជាតិ ទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិហៅកាត់ថា (IPEA) ដោយផ្ទាល់។ ការិយាល័យទទួលត្រូវតែជ្រើសតាំងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអាចជាការិយាល័យជាតិនៃប្រទេសហត្ថលេខី ឬ ការិយាល័យថ្នាក់តំបន់ ដែលមានសមត្ថភាពក្នុងការអនុវត្តការពិនិត្យជំហានដំបូងអន្តរជាតិជាមុនសិន។ ករណីដែលការិយាល័យទទួលមានអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិច្រើនជាងមួយអ្នកដាក់ពាក្យសុំ អាចជ្រើសតាំងអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរទាំងនោះ។ សូមបញ្ជាក់ថា រាល់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅ ឬ ក្រោយថ្ងៃទី ១ ខែមករា ឆ្នាំ២០០៤ គ្រប់ការិយាល័យជាតិនៃប្រទេសហត្ថលេខី គឺអាចជាការិយាល័យជ្រើសតាំង ឲ្យអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិបាន។[35]

កម្មវត្ថុនៃការពិនិត្យជំហានដំបូងអន្តរជាតិ គឺចងក្រងយោបល់ជាជំហានដំបូង និងឲ្យយោបល់លើលក្ខណៈវិនិច្ឆ័យថាតើតក្កកម្មដែលស្នើសុំនោះមានភាពថ្មី មានជំហាននៃការរកឃើញថ្មីនឹងអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មដែរឬទេ។[36]

#### ក-ការទាមទារ

ការទាមទារ គឺជាពាក្យបច្ចេកទេសនៅក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) នេះ ដើម្បីសំដៅដល់ការស្នើសុំនូវការពិនិត្យជំហានដំបូងអន្តរជាតិ។ ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិត្រូវដាក់ទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិដែលមានសមត្ថកិច្ចក្នុងរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃ

[35] សន្ធិសញ្ញា PCT មាត្រា ៣១ (៤), ៦៤ (១) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៥៣ (៧) ៩០.៤
[36] សន្ធិសញ្ញា PCT មាត្រា ៣១ ៣២ ៣៣

បញ្ជូនរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ឬ ក្នុងនៅរយៈពេល ២២ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។[37]

ពោលគឺការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិមិនទាន់អាចចាប់ផ្តើមបានឡើយ រហូតដល់អាជ្ញាធរស្រាវជ្រាវអន្តរជាតិបានចាប់ផ្តើមនីតិវិធីសរសេររបាយការណ៍ស្រាវជ្រាវអន្តរជាតិ ព្រមទាំងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់ខ្លួន។ អ្នកដាក់ពាក្យសុំត្រូវរង់ចាំឯកសារទាំងពីរខាងលើសិន មុននឹងសម្រេចដាក់ពាក្យទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបាន។

ទោះបីជាយ៉ាងណា ដើម្បីអាចដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបានលុះត្រាតែគោរពតាមលក្ខខណ្ឌចំនួន ០២ ដូចខាងក្រោមៈ

- លក្ខខណ្ឌទី១ អ្នកដាក់ពាក្យសុំត្រូវមានអាសយដ្ឋាន ឬ សញ្ជាតិនៃប្រទេសជាសមាជិកដែលព្រមទទួលការអនុវត្តក្នុងជំពូកទី២ នៃសន្ធិសញ្ញា PCT និង
- លក្ខខណ្ឌទី២ សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែដាក់នៅការិយាល័យទទួល នៃប្រទេសជាសមាជិកដែលព្រមទទួលការអនុវត្តក្នុងជំពូកទី២នៃសន្ធិសញ្ញា PCT។[38]

**ខ-ការកែសម្រួលសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូសបង្ហាញ**

មុននឹងចេញរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិអ្នកដាក់ពាក្យសុំនោះ មានឱកាសក្នុងការកែសម្រួលសំណុំលិខិតស្នើសុំអន្តរជាតិបាន នៅក្នុងលក្ខខណ្ឌតម្រូវ និងមានពេលវេលាកំណត់ (គឺសំដៅដល់ការកែសម្រួលសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូសបង្ហាញបាន)។[39] តែការកែសម្រួលនោះមិនត្រូវឲ្យប្រាសចាក ពីការបង្ហាញឲ្យដឹងនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នោះឡើយ[40]។

**គ-ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ**

អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ នឹងផ្តល់យោបល់ជាលាយលក្ខណ៍ទៅដល់អ្នកដាក់ពាក្យសុំដោយបញ្ជាក់អំពីហេតុផលច្បាស់លាស់។ ការទាមទារពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅថ្ងៃ ឬក្រោយថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិនឹងប្រើយន្តការស្វែងរកដែលមានឈ្មោះថា TOP UP។ យន្តការស្វែងរកនេះមានសមត្ថភាពអាចបញ្ជាក់អំពីឯកសារពាក់ព័ន្ធបន្ថែមអំពីឯកសារតក្កកម្មពីមុននេះឲ្យអ្នកដាក់ពាក្យសុំបានដឹង និងមានឱកាសកែសម្រួលពាក្យសុំរបស់ខ្លួន ដើម្បីធានាកុំឲ្យមាន

[37] សន្ធិសញ្ញា PCT មាត្រា ៣៩ (១) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៥៤ ១(ក), ៦៩.១ (ក) (៣) ៦៩.២

[38] សន្ធិសញ្ញា PCT មាត្រា ៣១ (២)(ក) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ ១៨.១ និង ៥៤

[39] សន្ធិសញ្ញា PCT មាត្រា ៣៤

[40] សន្ធិសញ្ញា PCT មាត្រា ៣៨

ការបដិសេធថា តក្កកម្មកំពុងស្នើសុំនេះ មិនមានភាពថ្មី និង ជំហាននៃការរកឃើញថ្មី មុនចាប់ផ្តើមនីតិវិធីកម្រិតថ្នាក់ជាតិ។[41]

ការចេញការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរអាចចេញជាលើកទី២ ដែលផ្តល់ឱកាសឲ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលសំណុំលិខិតស្នើសុំរបស់ខ្លួនបានម្តងទៀត។ ចំនួននៃការផ្តល់ឱកាសឲ្យកែសម្រួលសំណុំលិខិតស្នើសុំ គឺអាស្រ័យទៅលើពេលវេលានៃការពិនិត្យជំហានដំបូងអន្តរជាតិ។ របាយការណ៍ស្តីពីការពិនិត្យជំហានដំបូងអន្តរជាតិ គឺត្រូវផ្តល់ឲ្យអ្នកដាក់ពាក្យសុំ ក្នុងអំឡុងពេល ២៨ខែ គិតចាប់ពីកាលបរិច្ឆេទ ទាមទារអាទិភាព។ រាល់ការកែសម្រួលណាដែលធ្វើក្រោយការប្រគល់របាយការណ៍ហើយនេះនឹងមិនត្រូវយកមកពិចារណានោះទេ។[42]

**ឃ-ការឆ្លើយតបនឹងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ**

ជាទូទៅ អ្នកដាក់ពាក្យសុំនឹងទទួលការផ្តល់យោបល់ និងការអនុញ្ញាតឲ្យឆ្លើយតបពីអាជ្ញាធរពិនិត្យជំហានដំបូង នៅមុនពេលប្រគល់របាយការណ៍ស្តីអំពីការពិនិត្យជំហានដំបូងអន្តរជាតិ។ នៅក្នុងករណីនេះ អ្នកដាក់ពាក្យសុំអាចឲ្យកែសម្រួល និង ផ្តល់អំណះអំណាងរបស់ខ្លួនបាន។

អ្នកដាក់ពាក្យសុំមានសិទ្ធិទាក់ទងផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរជាមួយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ដែលជាទំនាក់ទំនងក្រៅផ្លូវការ និងមិនចងកាតព្វកិច្ច លើកលែងតែការតវ៉ាដែលពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្ម[43]។

[41] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៦៦

[42] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៦៦.២ និង ប្រការ ៦៦.៤ (ក)

[43] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៦៦

## ២.៥.២-របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ




*(របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិដែលត្រូវធ្វើក្នុងរយៈពេល ២៨ ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព)*

នីតិវិធីនៃការពិនិត្យជំហានដំបូងអន្តរជាតិនឹងបញ្ចប់ នៅពេលរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិបានរៀបចំរួចរាល់ ដែលត្រូវធ្វើក្នុងរយៈពេល ២៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ឬ រយៈពេល ០៦ខែ គិតចាប់ពីកាលបរិច្ឆេទទទួលការទាមទារដោយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ។ របាយការណ៍ស្តីពីការពិនិត្យជំហានដំបូងអន្តរជាតិមិនចងកាតព្វកិច្ចនោះទេ តែរបាយការណ៍នេះនឹងផ្តល់យោបល់ដោយពិចារណាលើលក្ខណវិនិច្ឆ័យដែលត្រូវបំពេញថាតើ តក្កកម្មនោះមានភាពថ្មី ឬ មានជំហាននៃការបង្កើតថ្មី ហើយព្រមទាំងអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មបានឬទេ [44] ។ ជាទូទៅរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវរៀបចំឲ្យបានចប់សព្វគ្រប់ និងបញ្ជូនមកអ្នកដាក់ពាក្យសុំ ០២ខែ មុនចាប់ផ្តើមអនុវត្តនីតិវិធីកម្រិតជាតិ ដូច្នេះក្នុងរយៈពេលនេះអ្នកដាក់ពាក្យសុំនឹងអាចពិចារណាថាគួរបន្តនីតិវិធីកម្រិតជាតិឬយ៉ាងណា[45]។

បន្ទាប់ពីរៀបចំរួច អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិត្រូវបញ្ជូនរបាយការណ៍នេះទៅអ្នកដាក់ពាក្យសុំ និង ទៅការិយាល័យអន្តរជាតិ ដែលរបាយការណ៍ត្រូវសរសេរដូចនឹងភាសានៃសំណុំលិខិតស្នើសុំអន្តរជាតិ និង

[44] សន្ធិសញ្ញា PCT មាត្រា ៣៥ (១) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រកា ៦៩.២

[45] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៦៩.២

ភាសាដែលនឹងត្រូវបោះផ្សាយអន្តរជាតិ។ ការិយាល័យអន្តរជាតិត្រូវតែបកប្រែភាសានោះទៅជាភាសាអង់គ្លេស ក្នុងករណីភាសាប្រើប្រាស់ មិនមែនជាភាសាអង់គ្លេស[46]។

របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិនឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ដឹង ក្រៅពីអ្នកដាក់ពាក្យសុំ និង មន្ត្រីដែលបានជ្រើសតាំងក្នុងដំណាក់កាលកម្រិតអន្តរជាតិឡើយ។ ការិយាល័យអន្តរជាតិ ព្រមទាំងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ មិនត្រូវផ្តល់ព័ត៌មានស្តីអំពីការចេញរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ឬ ការដកការទាមទារ ឬការមិនដកការទាមទារ ទៅអ្នកផ្សេងឡើយដោយគ្មានការអនុញ្ញាត ឬការស្នើសុំពីអ្នកដាក់ពាក្យសុំ[47]។

នៅពេលទទួលបានរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិហើយ អ្នកដាក់ពាក្យសុំសម្រេចថាតើបន្តនីតិវិធីកម្រិតជាតិ ឬ កម្រិតតំបន់ នៅចំពោះមុខមន្ត្រីដែលបានជ្រើសតាំង ក្នុងរយៈពេល ០៣ខែ គិតចាប់ពីការបរិច្ឆេទទាមទារអាទិភាព។ របាយការណ៍នេះនឹងជាមូលដ្ឋានដ៏សំខាន់ សម្រាប់ការិយាល័យជ្រើសតាំងក្នុងការពិចារណាក្នុងការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្រិតជាតិដល់សំណុំលិខិតស្នើសុំអន្តរជាតិណា ដែលរបាយការណ៍បានពិនិត្យឃើញថាបានបំពេញតាមលក្ខណៈវិនិច្ឆ័យទាំង ៣ នៃតក្កកម្ម[48]។

## ២.៦ ការពិនិត្យកម្រិតជាតិ




*(ការពិនិត្យកម្រិតជាតិត្រូវចាប់ផ្តើមមិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ ខែគិតចាប់ពីកាលបរិច្ឆេទ)*

[46] វិធានក្រោមសន្ធិសញ្ញា PCT ប្រការ ៧០ ៧២ ៧៤

[47] សន្ធិសញ្ញា PCT មាត្រា ៣៦ (៣) (ក), ៣៨(១)

[48] សន្ធិសញ្ញា PCT មាត្រា ៣៦ (៤) និងវិធានក្រោមសន្ធិសញ្ញា PCT ប្រការ៧ ១.២

បន្ទាប់ពីបញ្ចប់ដំណាក់កាលនីតិវិធីកម្រិតអន្តរជាតិ នីតិវិធីនេះនឹងត្រូវបន្តពិនិត្យនៅកម្រិតជាតិដែលជាដំណាក់កាលបញ្ចប់នៃការបញ្ចប់នៃនីតិវិធីចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) នេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការពិនិត្យកម្រិតជាតិនឹងចាប់ផ្តើម លុះត្រាតែអ្នកដាក់ពាក្យសុំត្រូវអនុវត្តសកម្មភាពមួយចំនួនដែលបានកំណត់ ឲ្យបានមុនកាលបរិច្ឆេទផុតកំណត់។ គួរបញ្ជាក់ផងដែរថា អ្នកដាក់ពាក្យសុំត្រូវមានទំនួលខុសត្រូវចំពោះខ្លួនឯងក្នុងការចាប់ផ្តើមពិនិត្យកម្រិតជាតិ ឲ្យបានទាន់ពេលកំណត់របស់ច្បាប់។ រយៈពេលដើម្បីទទួលការពិនិត្យកម្រិតជាតិត្រូវចាប់ផ្តើមពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ មិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។[49]

### ២.៦.១-ឯកសារតម្រូវជាមូលដ្ឋាន

មុនចាប់ផ្តើមនីតិវិធីត្រួតពិនិត្យបន្តនៅកម្រិតជាតិ អ្នកដាក់ពាក្យសុំត្រូវផ្តល់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ព្រមជាមួយរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិ និងបង់កម្រៃជាតិ ជូនដល់ការិយាល័យជ្រើសរើសនីមួយៗ ដោយមិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។[50] ទន្ទឹមគ្នានេះផងដែរ ការិយាល័យជ្រើសរើសតម្រូវឲ្យមានអ្នកតំណាងដែលសញ្ជាតិមិនដូចនឹងអ្នកដាក់ពាក្យសុំ និងមានការិយាល័យបម្រើការងារនៅប្រទេសជ្រើសរើស[51]។

### ២.៦.២-ការពិចារណា

ក្នុងដំណាក់កាលនីតិវិធីអន្តរជាតិ ជាទូទៅសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបានស្រាវជ្រាវ និង ធ្វើការត្រួតពិនិត្យដោយអាជ្ញាធរស្រាវជ្រាវ ឬ/និងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលពាក្យសុំរបស់ខ្លួនបាន។ របាយការណ៍ទាំងនេះនឹងបង្កភាពងាយស្រួលដល់អ្នកដាក់ពាក្យសុំដឹងអំពីភាពដែលទទួលបានប្រកាសនីយបត្រតក្កកម្មជាតិ។

ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬ អាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ មិនចងកាតព្វកិច្ចដល់ការិយាល័យចុះបញ្ជីជាតិនោះទេ ពោលគឺរបាយការណ៍ទាំងនោះគ្រាន់តែផ្តល់យោបល់ថា សំណុំលិខិតស្នើសុំអន្តរជាតិនោះ បានបំពេញតាមលក្ខខណ្ឌ៖ ភាពថ្មី មានជំហាននៃការរកឃើញថ្មី ឬ បង្កើតថ្មី និង ព្រមទាំងអាចយកទៅអនុវត្តនៅក្នុងវិស័យឧស្សាហកម្មបាន។

---

49 សន្ធិសញ្ញា PCT មាត្រា ២២

50 សន្ធិសញ្ញា PCT មាត្រា ២២

51 សន្ធិសញ្ញា PCT មាត្រា ២៧ (៧)

### ២.៦.៣-ការកែសម្រួលនៅដំណាក់កាលនីតិវិធីកម្រិតជាតិ

នៅក្នុងដំណាក់កាលនីតិវិធីកម្រិតជាតិ អ្នកដាក់ពាក្យសុំអាចធ្វើការកែសម្រួលបន្ថែមនៅចំពោះមុខការិយាល័យចុះបញ្ជីជាតិបាន លើសេចក្តីអះអាង សេចក្តីអធិប្បាយ និង គំនូសបង្ហាញ ហើយការកែសម្រួលនេះគឺជាការបំពេញបន្ថែមទៅលើការអនុវត្តដំណាក់កាលនីតិវិធីកម្រិតអន្តរជាតិកន្លងមក និងឲ្យសមស្របទៅតាមច្បាប់ជាតិ ឬរដ្ឋដែលជ្រើសរើសនីមួយៗ។ ទោះបីជាយ៉ាងណាក៏ដោយ ការកែសម្រួលនៅដំណាក់កាលនេះ មិនត្រូវឲ្យខុសឆ្ងាយពីការបញ្ចេញឲ្យដឹងអំពីតក្កកម្មនៃសំណុំលិខិតស្នើសុំអន្តរជាតិឡើយ។[52]

[52] សន្ធិសញ្ញា PCT មាត្រា ២៨

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទអំពី **នីតិវិធីនៃការចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម** យើងខ្ញុំបានសង្កេតឃើញថាតាមរយៈត្រឹមតែការស្រាវជ្រាវអន្តរជាតិគឺមិនទាន់គ្រប់គ្រាន់នោះទេ គឺត្រូវសិក្សាបន្ថែមទៅលើនីតិវិធីកម្រិតជាតិដែលជានីតិវិធីមួយកម្រិតទៀតដើម្បីបំពេញនូវលក្ខខណ្ឌតម្រូវចាំបាច់នៃប្រទេសដែលតក្កករបានសម្រេចជ្រើសរើសក្នុងការទទួលបានការការពារ។ បើទោះបីជាមានសន្ធិសញ្ញានេះក៏ដោយ ក៏ប៉ុន្តែប្រសិនបើតក្កករមិនស្វះស្វែងក្នុងការរៀបចំឯកសារដើម្បីចុះបញ្ជីឲ្យបានត្រឹមត្រូវតាមរយៈ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) នេះទេ តក្កកម្មនោះនឹងត្រូវអសារបង់ដោយមិនទទួលបានការការពារនោះឡើយ។ ក្រៅអំពីគោលបំណងជួយសម្រួល និងផ្តល់ភាពងាយស្រួលដល់តក្កករ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បាននាំមកនូវបដិវត្តន៍ដ៏អស្ចារ្យនៅក្នុងវិស័យបច្ចេកវិទ្យា និងការសិក្សាស្រាវជ្រាវ ការច្នៃប្រឌិតរបស់តក្កករ ដោយសារតែសន្ធិសញ្ញានេះទទួលបានភាពជោគជ័យនិង បន្តរីកចម្រើននៅទូទាំងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ បានកំពុងបន្តការអភិវឌ្ឍន៍ និងអនុវត្តនូវច្បាប់កម្មសិទ្ធិបញ្ញា តាមរយៈការផ្តល់នូវភាពងាយស្រួលក្នុងការអនុវត្តនូវនីតិវិធីក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីជាលក្ខណៈអន្តរជាតិ។

បច្ចុប្បន្ននេះ តក្កករបានចុះបញ្ជីរាប់លានតក្កកម្មរួចមកហើយរួមមានទាំងក្រុមហ៊ុនតូចក្តី ធំក្តី ដែលជួយដល់ការរីកចំរើនផ្នែកបច្ចេកវិទ្យារបស់ពិភពលោក តាមរយៈការចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីប្រកាសនីយបត្រតកម្មកម្មអន្តរជាតិ ដែលនេះគឺជាមូលដ្ឋានគតិយុត្តដ៏សំខាន់មួយដែលតក្កករ ទទួលបានអត្ថប្រយោជន៍ជាច្រើនដែលបាននាំមកនូវការផ្លាស់ប្តូរតាមរបៀបដែលប្រកាសនីយបត្រតកក្កកម្មទទួលបាន នៅទូទាំងពិភពលោកហើយទទួលបានការការពារច្រើនប្រទេស ដែលនេះគឺជាដំណោះស្រាយ និងជម្រើស ដ៏ល្អបំផុតរបស់អ្នកដាក់ពាក្យសុំសម្រាប់ការទទួលបានប្រកាសនីយបត្រតក្កកម្មមួយប្រកបដោយភាពឆ្លាតវៃជាសកល។ មិនត្រឹមតែប៉ុណ្ណោះ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បានផ្តល់ឲ្យអ្នកប្រើប្រាស់នូវពេលវេលាបន្ថែមដើម្បីទទួលបានហិរញ្ញប្បទាន និងវាយតម្លៃឱកាសពាណិជ្ជកម្ម អាជ្ញាប័ណ្ណ និងភាពជាដៃគូជាច្រើននៅលើសកលលោក។ កាត់បន្ថយការចំណាយនានាបានច្រើនហើយផ្តល់ឲ្យអ្នកដាក់ពាក្យសុំមានពេលវេលាគ្រប់គ្រាន់ក្នុងការ

ពិចារណាជម្រើសនានា ដើម្បីទទួលបានប្រកាសសនីយបត្រតក្កកម្ម។ ប្រព័ន្ធចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនេះ ត្រូវបានក្រុមហ៊ុនធំៗជាច្រើនសម្រេចចិត្តជ្រើសរើសប្រើប្រាស់ដើម្បីការពារនូវតក្កកម្មរបស់ខ្លួនព្រមទាំងសាកលវិទ្យាល័យនានា និងស្ថាប័នស្រាវជ្រាវជាច្រើនទៀត ហើយនឹងមានភាពងាយស្រួលនៅពេលដែលពួកគេរកឃើញនូវតក្កកម្មថ្មី ហើយនឹងទទួលបានការការពារជាលក្ខណៈអន្តរជាតិ។ សន្ធិសញ្ញានេះផ្តល់នូវនីតិវិធីរួមតែមួយក្នុងការបំពេញបែបបទស្នើសុំប្រកាសនីយបត្រតក្កកម្ម ដើម្បីការពារការបង្កើតរបកគំហើញថ្មីៗនៅក្នុងរដ្ឋជា

សមាជិក។ ផ្តល់ភាពងាយស្រួលដល់អ្នកពាក្យសុំនៅព័ត៌មានជាក់លាក់ ដើម្បីសម្រេចចិត្តក្នុងការទទួលបានការការពារ។ ការកាត់បន្ថយថ្លៃសេវា នីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) អាចរកបាននៅពេលដែលពាក្យសុំសន្ធិសញ្ញាសហប្រតិបត្តិការតក្កកម្មត្រូវបានដាក់ជាឌីជីថល ឬបេក្ខជនដែលជាកម្មសិទ្ធិនៃប្រទេសកំពុងអភិវឌ្ឍន៍ ទទួលការបន្ធូរបន្ថយថ្លៃឯកសារផ្លូវការរហូតទៅដល់លើស ៥០% និងដើម្បីរៀបចំសំណុំលិខិតស្នើសុំដោយមិនចាំបាច់រៀបចំដាក់សំណុំលិខិតស្នើសុំដាច់ពីគ្នា ដើម្បីទទួលបានការការពារច្រើនប្រទេស ហើយក៏មានអានុភាពគតិយុត្តដូចនឹងសំណុំលិខិតស្នើសុំចុះបញ្ជី ដើម្បីទទួលបានការការពារចុះបញ្ជីនៅការិយាល័យជាតិនៃប្រទេសនីមួយៗផងដែរ។

ដូច្នេះជាចុងក្រោយយើងខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋគ្រប់រូបបានស្វែងយល់អំពីសន្ធិសញ្ញាមួយនេះ ជាពិសេសតក្កករគ្រប់រូបគួរតែទៅចុះបញ្ជីតក្កកម្មរបស់ខ្លួនដើម្បីការពារផលប្រយោជន៍របស់ខ្លួន។ រួមជាមួយគ្នានេះផងដែរចំពោះប្រទេសកម្ពុជាយើង ក៏ត្រូវមានការចូលរួមអំពីសំណាក់មន្ត្រីជំនាញដែលពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យឧស្សាហកម្ម ដែលជាអ្នកអនុវត្តត្រូវតែផ្សព្វផ្សាយគ្រប់រូបភាព គ្រប់មធ្យោបាយ ដើម្បីឲ្យសន្ធិសញ្ញាមួយនេះមានភាពទូលំទូលាយទៅកាន់ប្រជាពលរដ្ឋទូទាំងប្រទេស ស្របពេលប្រទេសកម្ពុជាយើងកំពុងមានការរីកចម្រើនគ្រប់វិស័យ ដែលមានធនធានមនុស្សជាតក្កករ កំពុងតែស្វែងរកតក្កកម្មថ្មីៗនាពេលបច្ចុប្បន្ននេះ។

# អនុសាសន៍

ឆ្លងកាត់ការសិក្សាស្រាវជ្រាវរួចមក យើងខ្ញុំបានរកឃើញនូវចំណុចដែលមានភាពខ្វះខាតមួយចំនួន ហើយខាងក្រោម គឺជាអនុសាសន៍មួយចំនួនដើម្បីអាចជួយសម្រួលនីតិវិធីនៃការចុះបញ្ជីតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មឱ្យមានភាពប្រសើជាងមុន ៖

ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក៏ដូចជាការិយាល័យចុះបញ្ជីថ្នាក់ជាតិនៃរដ្ឋជាសមាជិក ត្រូវតាក់បន្ថយការចំណាយលើឯកសារដែលពាក់ព័ន្ធក្នុងនីតិវិធីចុះបញ្ជី។

កាត់បន្ថយរយៈពេលនៃនីតិវិធីចុះបញ្ជីអន្តរជាតិពីរយៈ ២ឆ្នាំ ៤ខែ មកត្រឹមរយៈពេល ១៨ខែ។

អង្គការចាត់តាំងនៃសន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម ត្រូវកាត់ចោលនូវនីតិវិធីកម្រិតជាតិ។

គួរបន្ថែមការិយាល័យទទួលដែលជាអាជ្ញាធរអន្តរជាតិនៃការចុះបញ្ជីតក្កកម្មតាមតំបន់បន្ថែមទៀត។

យើងខ្ញុំទាំងពីរសង្ឃឹមថា គោលគំនិតនៃអនុសាសន៍ទាំងអម្បាលម៉ានខាងលើនេះ អាចជាចំណែកនៃការចូលរួមមតិដើម្បីស្ថាបនាដល់ដំណើរការនៃនីតិវិធីនៃការចុះបញ្ជីតក្កកម្ម តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ដើម្បីឲ្យសន្ធិសញ្ញាមួយនេះកាន់តែមានវឌ្ឍនភាព និងទទួលបានការគាំទ្របន្ថែមមួយកម្រិតទៀតអំពីសំណាក់តក្កករគ្រប់រូបដែលកំពុងស្វះស្វែងរកការការពារនូវតក្កកម្មរបស់ខ្លួន។

# ឯកសារយោង

## ១.សន្ធិសញ្ញាអន្តរជាតិ

- អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ២៥.កក្កដា.១៩៩៥។
- សន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម ។
- សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ស្តីពីការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម អន្តរជាតិ ០៨.ធ្នូ.២០១៦។
- អនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ២០.មីនា.១៨៨៣។
- វិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។
- កិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពីការចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ។

## ២.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (កិច្ចព្រមព្រៀងទទួលស្គាល់សុពលភាព)។
- ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្ម។
- ប្រកាសស្តីពី ការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

## ៣.ឯកសារយោងផ្សេងៗ

- សទ្ទានុក្រម នៃសន្ធិសញ្ញាសហប្រតិបត្រការប្រកាសនីយបត្រតក្កកម្ម (PCT Glossary)
- PCT – The International Patent System (wipo.int)
- PCT FAQs (wipo.int)
- Patent Cooperation Treaty (wipo.int)
- PCT Rules: Table of Contents (wipo.int)
- https://www.wipo.int/patentscope/en/
- The PATENTSCOPE User´s guide (wipo.int)
- (9) World Intellectual Property Organization – WIPO - YouTube

# ឧបសម្ព័ន្ធ

# សន្ធិសញ្ញា

# សហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

( Patent Cooperation Treaty )

# សន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្ម

## ធ្វើនៅទីក្រុងវ៉ាស៊ីនតោន នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០

## បានធ្វើវិសោធនកម្ម នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

## បានកែប្រែនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៨៤

## និងនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០១

## (ចូលជាធរមានពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២)

## តារាងមាតិកា

**បុព្វកថា**

**ជំពូក១: បទប្បញ្ញត្តិផ្ដើម**

មាត្រា១: ការបង្កើតសហព័ន្ធ

មាត្រា២: និយមន័យ

ជំពូក២: សំណុំលិខិតស្នើសុំអន្តរជាតិ និងការស្នើសុំអន្តរជាតិ

មាត្រា៣: សំណុំលិខិតស្នើសុំអន្តរជាតិ

មាត្រា៤: ពាក្យសុំ

មាត្រា៥: សេចក្តីអធិប្បាយ

មាត្រា៦: សេចក្តីអះអាង

មាត្រា៧: គំនូសបង្ហាញ

មាត្រា៨: សេចក្តីអះអាងអំពីអទិភាព

មាត្រា៩: សំណុំលិខិតស្នើសុំ

មាត្រា១០: ការិយាល័យទទួល

មាត្រា១១: កាលបរិច្ឆេទនៃការសុំចុះបញ្ជី និងអានុភាព នៃសំណុំលិខិតស្នើសុំអន្តរជាតិ

មាត្រា១២: ការបញ្ជូនសំណុំលិខិតស្នើសុំអន្តរជាតិទៅអោយការិយាល័យអន្តរជាតិ និង អាជ្ញាធរស្រាវជ្រាវអន្តរជាតិ។

មាត្រា១៣: ភាពដែលអាចរកបាននូវច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ចំពោះ ការិយាល័យជ្រើសរើស។

មាត្រា១៤: ភាពខ្វះចន្លោះដ៏ជាក់លាក់នៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ

មាត្រា១៥: ការស្រាវជ្រាវអន្តរជាតិ

មាត្រា១៦:	អាជ្ញាធរស្រាវជ្រាវអន្តរជាតិ

មាត្រា១៧:	បែបបទចំពោះមុខអាជ្ញាធរស្រាវជ្រាវអន្តរជាតិ

មាត្រា១៨:	របាយការណ៍ស្រាវជ្រាវអន្តរជាតិ

មាត្រា១៩:	ការកែសម្រួលសេចក្ដីអះអាងនៅចំពោះមុខការិយាល័យអន្តរជាតិ

មាត្រា២០:	ការទាក់ទងទៅការិយាល័យជ្រើសរើស

មាត្រា២១:	ការចុះផ្សាយអន្តរជាតិ

មាត្រា២២:	ការចម្លង ការបកប្រែ និងកម្រៃចំពោះការិយាល័យអន្តរជាតិ

មាត្រា២៣:	ការពន្យារនៃដំណើរការកម្រិតជាតិ

មាត្រា២៤:	លទ្ធភាពបាត់បង់អានុភាពក្នុងរដ្ឋជ្រើសរើស

មាត្រា២៥:	លក្ខខណ្ឌតម្រូវជាតិ

មាត្រា២៨:	ការកែសម្រួលនៃសេចក្ដីអះអាង សេចក្ដីអធិប្បាយ និង គំនូសបង្ហាញចំពោះមុខការិយាល័យជ្រើសរើស។

មាត្រា២៩:	អានុភាពនៃការបោះពុម្ពផ្សាយអន្តរជាតិ

មាត្រា៣០:	លក្ខខណ្ឌសម្ងាត់របស់សំណុំលិខិតលេខស្នើសុំអន្តរជាតិ

ជំពូកទី២:	ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣១:	ការទាមទារសម្រាប់ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣២:	អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣៣:	ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣៤:	នីតិវិធីសម្រាប់អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ

មាត្រា៣៥:	របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣៦:	ការបញ្ជូន ការបកប្រែ និងការទាក់ទងនៃរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣៧:	ការដកហូតយកទៅវិញ នូវការទាមទារឬការជ្រើសតាំង

មាត្រា៣៨:	លក្ខខណ្ឌសម្ងាត់របស់ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ

មាត្រា៣៩:	ការចម្លង ការបកប្រែនិងបង់កម្រៃចំពោះការិយាល័យជ្រើសតាំង

មាត្រា៤០:	ការពន្យារនៃការពិនិត្យកម្រិតជាតិ និងដំណើរការផ្សេងៗទៀត

មាត្រា៤១:	ការកែសម្រួលនៃសេចក្ដីអះអាង សេចក្ដីអធិប្បាយ និងគំនូសបង្ហាញចំពោះមុខការិយាល័យ

មាត្រា៤២:	លទ្ធភាពនៃការពិនិត្យកម្រិតជាតិ នៅក្នុងការិយាល័យជ្រើសរើស

**ជំពូក៣:	បទប្បញ្ញត្តិរួម**

មាត្រា៤៣:	ការស្វែងរកការការពារជាច្រើនប្រភេទដ៏ជាក់លាក់

មាត្រា៤៤:	ការស្វែងរកការការពារពីរប្រភេទ

មាត្រា៤៥:	សន្ធិសញ្ញាប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់

មាត្រា៤៦:	ការបកប្រែនៃសំណុំលិខិតស្នើសុំអន្តរជាតិមិនត្រឹមត្រូវ

មាត្រា៤៧:	ពេលវេលាកម្រិត

មាត្រា៤៨:	ការពន្យារពេលវេលាដែលម្រិតជាក់លាក់នៅក្នុងការបំពេញអោយបានត្រឹមត្រូវ

មាត្រា៤៩:	សិទ្ធិអនុវត្តចំពោះមុខអាជ្ញាធរអន្តរជាតិ

**ជំពូក៤:	សេវាកម្មបច្ចេកទេស**

មាត្រា៥០:	សេវកម្មព័ត៌មានប្រកាសនីបត្រតក្កកម្ម

មាត្រា៥១:	ជំនួយបច្ចេកទេស

មាត្រា៥២:	ទំនាក់ទំនងជាមួយបទប្បញ្ញត្តិផ្សេងទៀតនៃសន្ធិសញ្ញា

**ជំពូក៥:	បទប្បញ្ញត្តិរដ្ឋបាល**

មាត្រា៥៣:	សន្និបាត

មាត្រា៥៤:	គណៈកម្មការប្រតិបត្តិ

មាត្រា៥៥:	ការិយាល័យអន្តរជាតិ

មាត្រា៥៦:	គណៈកម្មការសម្រាប់កិច្ចការសហប្រតិបត្តិការបច្ចេកទេស

មាត្រា៥៧:	ហិរញ្ញវត្ថុ

មាត្រា៥៨:	បទបញ្ជា

**ជំពូក៦:	ជម្លោះ**

មាត្រា៥៩:	ជម្លោះ

**ជំពូក៧:	ការកែប្រែ និងវិសោធនកម្ម**

មាត្រា៦០:	ការកែប្រែនៃសន្ធិសញ្ញា

មាត្រា៦១:	ការកែប្រែនៃបទប្បញ្ញាត្តិជាក់លាក់របស់សិទ្ធិបញ្ញា

**ជំពូក៨:	អវសានប្បញ្ញត្តិ**

មាត្រា៦២:	ការក្លាយជាភាគីរបស់សន្ធិសញ្ញា

មាត្រា៦៣:	ការចូលជាធរមាន នៃសន្ធិសញ្ញា

មាត្រា៦៤:	ការមិនយកមកអនុវត្តទាំងស្រុង

មាត្រា៦៥:	ការអនុវត្តសន្សឹម

មាត្រា៦៦:	ការប្រកាសមិនយល់ព្រមជាឱឡារឹក

មាត្រា៦៧:	ហត្ថលេខានិងភាសា

មាត្រា៦៨:	មុខងារសេក្ខីប័ណ្ណ

មាត្រា៦៩:	សេចក្តីជូនដំណឹង

**<u>រដ្ឋហត្ថលេខី</u>**

សម្រេចធ្វើវិភាគទាន ចំពោះការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

សម្រេចបាននូវការការពារស្របច្បាប់នូវតក្កកម្មដ៏សុក្រិត សម្រេចធ្វើឱ្យងាយស្រួលនិងផ្តល់នូវភាពសន្សំសំចៃថែមទៀត ដើម្បីទទួលបានការការពារតក្កកម្មដែលការការពារ ត្រូវស្វែងរកក្នុងប្រទេសជាច្រើន។

សម្រេចជួយសម្រួល និងពន្លឿនការទទួលបានព័ត៌មានបច្ចេកទេសដែលមានផ្ទុកក្នុងឯកសារនានាដែលពិពណ៌នាអំពីតក្កកម្មថ្មីរបស់សាធារណៈជន។

សម្រេចពង្រឹង និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍ តាមរយៈការអនុម័តវិធានការដែលមានទិសដៅបង្កើនប្រសិទ្ធភាពប្រព័ន្ធច្បាប់របស់គេ ទោះបីជាកម្រិតជាតិឬ កម្រិតតំបន់ដែលអភិវឌ្ឍសម្រាប់ ការការពារតក្កកម្មដោយផ្តល់អោយនូវការទទួលបានដោយងាយស្រួលនូវព័ត៌មានស្តីពីភាពដែលអាចរកបាននៃដំណោះស្រាយ បច្ចេកវិទ្យាដែលអនុវត្តបានចំពោះសេចក្តីត្រូវការជាពិសេសរបស់គេ និងដោយជួយសម្រួលការទទួលបាននូវ បច្ចេកទេសវិទ្យាទំនើបដែលមានទំហំរីកដុះដាលជាដរាប។

ជឿជាក់ថា សហប្រតិបត្តិការក្នុងចំណោមជាតិទាំងឡាយ និងជួយសម្រួលយ៉ាងធំធេងដើម្បីសម្រេចបាននូវគោលបំណងទាំងនេះ។

សម្រេចសន្ធិសញ្ញាដូចខាងក្រោមនេះ៖

# បុព្វប្បញ្ញត្តិ

## មាត្រា១

## ការបង្កើតសហព័ន្ធមួយ

(១) រដ្ឋជាភាគីនៃសន្ធិសញ្ញានេះ (ដែលក្រោយមកហៅថា «រដ្ឋហត្ថលេខី») រួមគ្នាជាសហព័ន្ធមួយដើម្បីធ្វើសហប្រតិបត្តិការក្នុងការដាក់សំណុំលិខិតស្នើសុំ ការស្រាវជ្រាវសំណុំលិខិតស្នើសុំ និងពិនិត្យសំណុំលិខិតស្នើសុំ សម្រាប់ការការពារតក្កកម្ម និងសម្រាប់ផ្តល់សេវាកម្មបច្ចេកទេសពិសេស។ សហព័ន្ធត្រូវបានទទួលស្គាល់ថាជាសហព័ន្ធនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។

(២) គ្មានប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញានេះត្រូវបានស្រាយជាការបន្ថយសិទ្ធិដោយអនុលោមតាម អនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម របស់ជនជាតិណាមួយ អ្នកមានទីលំនៅនៃប្រទេសដែលជាភាគីចំពោះសន្ធិសញ្ញានោះ។

## មាត្រា២

## និយមន័យ

សម្រាប់គោលបំណងនៃសន្ធិសញ្ញានេះ និងបទបញ្ជាទាំងឡាយនិងលុះត្រាតែមានការថ្លែងបញ្ជាក់បើមិនដូច្នេះទេ៖

(i) «សំណុំលិខិតស្នើសុំ» មានន័យថា សំណុំលិខិតស្នើដើម្បីការការពារតក្កម្ម។ យោងចំពោះ សំណុំលិខិតស្នើសុំ ត្រូវតែបកស្រាយជាវិញ្ញាបនបត្រ របស់តក្កករ វិញ្ញាបនបត្រមានអត្ថប្រយោជន៍ វិញ្ញាបនបត្រម៉ូ

ដែលប្រកាសនីយបត្រតក្កកម្ម ឬ វិញ្ញាបនបត្របើការបន្ថែមវិញ្ញាបនបត្រនៃការបន្ថែមរបស់តក្កករ និង វិញ្ញាបនបត្រមានអត្ថប្រយោជន៍នៃការបន្ថែម។

(ii) «ការងារចំពោះ» ប្រកាសនីបត្រតក្កកម្មត្រូវតែបកស្រាយជាការយោង ចំពោះប្រកាសនីបត្រតក្កកម្ម សម្រាប់តក្កកម្ម វិញ្ញាបនបត្រតក្កករ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រកាសនីបត្រតក្កកម្ម ឬ វិញ្ញាបនបត្រនៃការបន្ថែម វិញ្ញាបនបត្រនៃការបន្ថែមរបស់តក្កករ វិញ្ញាបនបត្រករ និងវិញ្ញាបនបត្រនៃការ បន្ថែមរបស់ម៉ូដែល។

(iii) «ប្រកាសនីបត្រតក្កកម្មជាតិ» មានន័យថា ប្រកាសនីបត្រតក្កកម្មដែលផ្តល់ដោយអាជ្ញាធរជា តិ។

(iv) «ប្រកាសនីបត្រតក្កកម្មតំបន់» មានន័យថា ប្រកាសនីបត្រតក្កកម្មដែលផ្តល់ដោយអាជ្ញាធ រជាតិ ឬអាជ្ញាធរអន្តរជាតិរដ្ឋបាលដែលមានអំណាចផ្តល់ ប្រកាសនីបត្រតក្កកម្មមានអានុភាពក្នុងរដ្ឋ ច្រើនជាងមួយ។

(v) «សំណុំលិខិតស្នើសុំតំបន់» មានន័យថា សំណុំលិខិតស្នើសុំសម្រាប់ប្រកាសនីយបត្រតក្កកម្មតំបន់។

(vi) ការយោងចំពោះ «សំណុំលិខិតស្នើសុំជាតិ» ត្រូវតែបកស្រាយជាការយោងចំពោះសំណុំ លិខិតស្នើសុំសម្រាប់ប្រកាសនីយបត្រតក្កកម្មជាតិ ឬ ប្រកាសនីបត្រតក្កកម្មតំបន់ដែលមិនមែនជា សំណុំលិខិតស្នើសុំ ដែលបានដាក់អនុលោមតាមសន្ធិសញ្ញានេះ។

(vii)«សំណុំលិខិតស្នើសុំអន្តរជាតិ» មានន័យថា សំណុំលិខិតស្នើសុំដែលបានដាក់ដោយអនុលោមតាម សន្ធិសញ្ញានេះ។

(viii) ការយោងចំពោះ «សំណុំលិខិតស្នើសុំ» ត្រូវតែបកស្រាយជាការយោងចំពោះសំណុំលិខិតស្នើ សុំអន្តរជាតិ និងលិខិតស្នើសុំជាតិ។

(ix) ការយោងចំពោះ «ប្រកាសនីយបត្រតក្កកម្ម» ត្រូវតែបកស្រាយ ជាការយោងចំពោះប្រកាសនីបត្រតក្ក កម្មជាតិ និងប្រកាសនីយបត្រតក្កកម្មតំបន់។

(x) ការយោងចំពោះ «ច្បាប់ជាតិ» ត្រូវតែបកប្រែជាការយោងចំពោះច្បាប់ជាតិរបស់រដ្ឋហត្ថលេខី ឬចំពោះ សន្ធិសញ្ញាដែល ផ្តល់សម្រាប់ការដាក់សំណុំលិខិតស្នើសុំតំបន់ ឬសម្រាប់ផ្តល់ប្រកាសនីបត្រតក្កកម្ម តំបន់ ក្នុងករណីពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំតំបន់ប្រកាស ឬ ប្រកាសនីបត្រតក្កកម្មតំបន់។

(xi) «កាលបរិច្ឆេទអាទិភាព» សម្រាប់គោលបំណងគណនាពេលវេលាកំណត់មានន័យថា:

ក. ក្នុងករណីសំណុំលិខិតស្នើសុំអន្តរជាតិ មានសេចក្តីអះអាងអទិភាពដោយអនុលោមតាមមាត្រា៨ ជា កាលបរិច្ឆេទសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដែលមានសេចក្តីប្រកាសអាទិភាពនោះ។

ខ. ក្នុងករណីសំណុំលិខិតស្នើសុំអន្តរជាតិ មានសេចក្តីអះអាងច្រើន ដោយអនុលោមតាម មាត្រា៨ ជាកាល បរិច្ឆេទសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូងបង្អស់ដែលមានការប្រកាសអាទិភាព។

គ. ក្នុងករណីសំណុំលិខិតស្នើសុំអន្តរជាតិ មិនមានសេចក្តីប្រកាសអាទិភាពណាមួយ ដោយអនុលោមតាម មាត្រា៨ ជាកាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិរបស់សំណុំលិខិតស្នើសុំដូចនោះ។

(xii)«ការិយាល័យជាតិ» មានន័យថា អាជ្ញាធររដ្ឋបាលរបស់រដ្ឋហត្ថលេខីបានប្រគល់ជាមួយការផ្តល់ប្រកាសនីបត្រតក្កកម្ម។ ការយោងចំពោះ «ការិយាល័យជាតិ» គួរតែបកស្រាយជាការយោងផងដែរចំពោះអាជ្ញាធរអន្តររដ្ឋបាលណាមួយ ដែលជារដ្ឋជាច្រើន បានប្រគល់ភារកិច្ចនៃការផ្តល់ប្រកាសនីបត្រតក្កកម្មតំបន់ និងបានន័យថា យ៉ាងហោចណាស់រដ្ឋមួយនៃរដ្ឋទាំងនោះ ជារដ្ឋហត្ថលេខី និងអោយតែរដ្ឋនោះមានអំណាច ដែលជាអាជ្ញាសន្មតទុកជាកាតព្វកិច្ច និងអនុវត្តអំណាចដែលជាសន្ធិសញ្ញានេះ និងបទបញ្ជានានាផ្តល់អោយចំពោះការិយាល័យជាតិទាំងនោះ។

(xiii) «ការិយាល័យជ្រើសរើស» មានន័យថា ការិយាល័យជាតិរបស់រដ្ឋ ឬជំនួសមុខអោយរដ្ឋដែលត្រូវបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំ ដោយអនុលោមតាមជំពូក I នៃសន្ធិសញ្ញានេះ។

(xiv) «ការិយាល័យជ្រើសរើស» មានន័យថា ការិយាល័ជាតិរបស់រដ្ឋ ឬ ជំនួសមុខអោយរដ្ឋដែលត្រូវបានជ្រើសរើសដោយ អ្នកដាក់ពាក្យសុំដោយអនុលោមតាមជំពូក II នៃសន្ធិសញ្ញានេះ។

(xv) «ការិយាល័យជ្រើសរើស» មានន័យថា ការិយាល័យជាតិរបស់រដ្ឋ ឬ ជំនួសមុខរដ្ឋដែលត្រូវបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំ ដោយអនុលោមតាមជំពូក២ នៃសន្ធិសញ្ញានេះ។

(xvi) «ការិយាល័យជ្រើសរើស» មានន័យថា ការិយាល័យជាតិរបស់រដ្ឋ ឬ អង្គការអន្តរជាតិរដ្ឋាភិបាល ដែលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានដាក់។

(xvii) «សន្និបាត» មានន័យថា សន្និបាតរបស់សហព័ន្ធ។

(xviii) «អង្គការ» មានន័យថា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(xix) «ការិយាល័យ អន្តរជាតិ» មានន័យថា ការិយាល័យអន្តរជាតិរបស់អង្គការ និងការិយាល័យសហព័ន្ធអន្តរជាតិ សម្រាប់ការការពារកម្មសិទ្ធិបញ្ញា (BIRPI) ដែល (as long as subsists) មាន។

(xx) «អគ្គនាយក» មានន័យថាអគ្គនាយករបស់អង្គការ និងនាយករបស់ការិយាល័យសហព័ន្ធអន្តរជាតិ សម្រាប់ការការពារកម្មសិទ្ធិបញ្ញា (BIRPI) ដែលមាន។

# ជំពូក១
# សំណុំលិខិតស្នើសុំអន្តរជាតិ
# និង ការស្រាវជ្រាវអន្តរជាតិ
## មាត្រា៣
## សំណុំលិខិតស្នើសុំអន្តរជាតិ

(១) សំណុំលិខិតស្នើសុំសម្រាប់ការការពារតក្កកម្ម ក្នុងរដ្ឋហត្ថលេខីណាមួយអាចត្រូវបានដាក់សំណុំលិខិតស្នើសុំអន្តរជាតិបាន ដោយអនុលោមតាមសន្ធិសញ្ញានេះ។

(២) សំណុំលិខិតស្នើសុំអន្តរជាតិត្រូវមាន ពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាងមួយ ឬច្រើន គំនូសបង្ហាញមួយ ឬច្រើន (ក្នុងករណីតម្រូវ) និងខ្លឹមសារសង្ខេប ដូចមានចែងក្នុងសន្ធិសញ្ញានេះ និងបទបញ្ញា។

(៣) ខ្លឹមសារសង្ខេបគ្រាន់តែបម្រើគោលបំណងរបស់ព័ត៌មានបច្ចេកទេស មិនអាចយកទៅគិតសម្រាប់គោលបំណងណាមួយផ្សេងទៀតឡើយ ជាពិសេសមិនសម្រាប់គោលបំណងបកស្រាយទំហំនៃការការពារឡើយ។

(៤) សំណុំលិខិតស្នើសុំអន្តរជាតិត្រូវ

(i) ធ្វើជាភាសាដែលបានកំណត់។

(ii) អនុវត្តតាមការតម្រូវផ្នែករូបសាស្ត្រដែលបានកំណត់។

(iii) អនុវត្តតាមការតម្រូវដែលបានកំណត់ នៃការរួមបញ្ចូលតែមួយនៃតក្កកម្ម។

(iv) បង់កម្រៃតាមការកំណត់។

## មាត្រា៤
## ពាក្យសុំ

(១) ពាក្យសុំត្រូវមាន:

(ក) ការប្តឹងសុំចំពោះអានុភាពដែលសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវអនុវត្តដំណើរការទៅតាមសន្ធិសញ្ញានេះ។

(ខ) ការជ្រើសរើសរដ្ឋហត្ថលេខី ឬរដ្ឋដែលត្រូវបានគេប្រាថ្នាចង់បានការការពារតក្កកម្ម ដោយឈរលើមូលដ្ឋាននៃសំណុំលិខិតស្នើសុំអន្តរជាតិ (រដ្ឋជ្រើសរើស)។ ប្រសិនបើសម្រាប់រដ្ឋជ្រើសរើសណាមួយ ដែលមានប្រកាសនីយបត្រតក្កកម្មតំបន់ ហើយដែលអ្នកដាក់ពាក្យសុំមានបំណងចង់ទទួលបាន ប្រកាសនីយបត្រតក្កកម្មតំបន់ ជាជាងទទួលបានប្រកាសនីបត្រតក្កកម្មជាតិ ពាក្យសុំត្រូវបញ្ជាក់អំពីនេះផងដែរ។ ដោយអនុលោមតាមសន្ធិសញ្ញាពាក់ព័ន្ធប្រកាសនីយបត្រតក្កកម្មតំបន់ ប្រសិនបើអ្នកដាក់ពាក្យសុំមិនអាចកំណត់លិខិតស្នើសុំរបស់គាត់ ចំពោះភាពជាក់លាក់នៃរដ្ឋដែលជាសមាជិកនៃសន្ធិសញ្ញានោះ។ ការជ្រើសរើសរដ្ឋមួយក្នុងចំណោមរដ្ឋទាំងនោះ ហើយការបញ្ជាក់ពីបំណងចង់ទទួលបានប្រកាសនីយបត្រតក្កកម្មតំបន់ ត្រូវតែប្រព្រឹត្តដូចការជ្រើសរើសរដ្ឋដែលជាសមាជិកទាំងអស់នៃសន្ធិសញ្ញានោះ។ ដោយអនុលោមតាមច្បាប់ជាតិរបស់រដ្ឋជ្រើសរើស ប្រសិនបើការជ្រើសរើសរដ្ឋនោះដែលមានអានុភាពរបស់សំណុំលិខិតស្នើសុំ សម្រាប់ប្រកាសនីយបត្រតក្កកម្មតំបន់ ការជ្រើសរើសរដ្ឋនោះ ត្រូវតែប្រព្រឹត្តដូចការបញ្ជាក់នៃបំណងចង់ទទួលបាន ប្រកាសនីយបត្រតក្កកម្មតំបន់។

(គ) ឈ្មោះ និងទិន្នន័យផ្សេងទៀតដែលបានកំណត់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំ និងភ្នាក់ងារ (ប្រសិនបើមាន)។

(ឃ) ចំណងជើងរបស់តក្កកម្ម

(ច) ឈ្មោះ ន័យ និងទិន្នន័យផ្សេងទៀតដែលបានកំណត់ពាក់ព័ន្ធនឹងតក្កកម្ម ក្នុងករណីច្បាប់ជាតិយ៉ាងហោចណាស់ក៏របស់រដ្ឋមួយនៃរដ្ឋមួយនសរដ្ឋជ្រើសរើសទាំងឡាយតម្រូវថា ការបញ្ជាក់ទាំងនេះត្រូវផ្តល់

អោយនាពេលដាក់សំណុំលិខិតស្នើសុំជាតិ។ បើពុំដូច្នេះទេ ការបញ្ជាក់ទាំងនោះ អាចត្រូវផ្តល់តាមការស្នើសុំ ឬតាមការជូនដំណឹងដោយឡែក ទៅកាន់ការិយាល័យជ្រើសរើសនីមួយៗ ដែលច្បាប់ជាតិនៃរដ្ឋនោះ តម្រូវអោយផ្តល់ការបញ្ជាក់ទាំងនោះ ប៉ុន្តែក៏អនុញ្ញាតអោយបានដែរថា វាត្រូវបានផ្តល់អោយនាពេលក្រោយ បន្ទាប់ពីការដាក់សំណុំលិខិតស្នើសុំជាតិ។

(២) ការជ្រើសរើសនីមួយៗ ត្រូវបង់មកប្រែតាមការកំណត់ក្នុងរយៈពេលកំណត់មួយ។

(៣) លុះត្រាតែអ្នកដាក់ពាក្យសុំសួររកការពារប្រភេទណាមួយផ្សេងទៀត ដោយយោងតាមមាត្រា៤៣ ការជ្រើសរើសត្រូវមានន័យថា ការការពារដែលប្រាថ្នាចង់បានត្រូវមានការផ្តល់ប្រកាសនីយបត្រតួកកម្ម ឬជួសមុខអោយរដ្ឋជ្រើសរើស សម្រាប់គោលបំណងនៃវាក្យខ័ណ្ឌនេះ មាត្រា២ (ii) មិនត្រូវយលមកអនុវត្ត។

(៤) ការខកខានមិនបានបញ្ជាក់ឈ្មោះនិង ទិន្នន័យដែលបានកំណត់ផ្សេងៗទៀតពាក់ព័ន្ធនឹងតក្កករ មិនត្រូវចាត់ទុកថា មានផលវិបាកក្នុងរដ្ឋជ្រើសរើស ដែលច្បាប់ជាតិនៃរដ្ឋនោះតម្រូវឲ្យផ្តល់ការបញ្ជាក់ទាំងនេះ ប៉ុន្តែក៏អនុញ្ញាតអោយបានដែរថា វាត្រូវផ្តល់ឲ្យនាពេលក្រោយបន្ទាប់ពីការសំណុំលិខិតស្នើសុំជាតិ។ ការខកខានមិនបានផ្តល់ការបញ្ជាក់ទាំងនោះ ក្នុងការជូនដំណឹងដោយឡែក មិនចាតិទុកថា មានផលវិបាកក្នុងរដ្ឋជ្រើសរើសណាមួយដែលច្បាប់ជាតិនៃរដ្ឋនោះមិនតម្រូវឲ្យផ្តល់ការបញ្ជាក់ទាំងនោះឡើយ។

## មាត្រា៥

## សេចក្តីអធិប្បាយ

សេចក្តីអធិប្បាយ ត្រូវបានលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និង ពេញលេញដើម្បីឲ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញ អាចអនុវត្តបាននៅតក្កកម្មនោះ។

## មាត្រា៦

## សេចក្តីអះអាង

សេចក្តីអះអាង ត្រូវតែកំណត់អោយបានច្បាស់លាស់ អំពីចំណុចដែលសុំអោយមានការការពារ។ សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប។ សេចក្តីអះអាងត្រូវតែផ្អាកទាំងស្រុងលើសេចក្តីអធិប្បាយ។

## មាត្រា៧

## គំនូសបង្ហាញ

(១) លើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ(២)(ii) គំនូសបង្ហាញត្រូវតែតម្រូវអោយមាននៅពេលចាំបាច់ ដើម្បីយកមកស្រាយពន្យល់តក្កកម្ម។

(២) ក្នុងករណីគ្មានការចាំបាច់ ដើម្បីយកមកស្រាយពន្យល់អំពីគំនូសបង្ហាញៈ

(i) អ្នកដាក់ពាក្យសុំអាចបញ្ចូលគំនូសទាំងនោះក្នុងសំណុំលិខិតស្នើសុំអន្តរជាតិនៅពេលដាក់។

(ii) ការិយាល័យជ្រើសរើសនីមួយៗ អាចតម្រូវអោយអ្នកដាក់ពាក្យសុំដាក់គំនូសបង្ហាញទាំងនេះក្នុងពេលកំណត់ណាមួយ។

## មាត្រា៨

## សេចក្ដីអំពីអទិភាព

(១) សំណុំលិខិតស្នើសុំអន្តរជាតិ អាចមានសេចក្តីប្រកាសដែលអះអាងអំពីអាទិភាពរបស់សំណុំលិខិតស្នើសុំដំបូងមួយ ឬច្រើនដែលបានដាក់ក្នុង ឬសម្រាប់ប្រទេសដែលជាសមាជិកអនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម។

(២) ក. លើកលែងបទប្បញ្ញត្តិនៃអនុវាក្យខណ្ឌ (ខ) ល័ក្ខខ័ណ្ឌទាំងឡាយសម្រាប់ និងអានុភាពនៃការអះអាងអាទិភាពណាមួយដែលប្រកាស ដោយអនុលោមតាមវាក្យខ័ណ្ឌ (១) ត្រូវតែដូចការចែងក្នុងមាត្រា៤ នៃច្បាប់ទីក្រុងស្តុកហូល្មរបស់ អនុសញ្ញាទីក្រុងប៉ារីសស្តីពីកម្មសិទ្ធិឧស្សាហកម្ម។

ខ. សំណុំលិខិតស្នើសុំអន្តរជាតិ ដែលមានការអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំដំបូងមួយ ឬច្រើនបានដាក់ក្នុងឬសម្រាប់រដ្ឋហត្ថលេខីអាចមានការជ្រើសរើសរដ្ឋនោះ។ ក្នុងករណីនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ មានការអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំជាតិមួយ ឬច្រើនបានដាក់ក្នុងឬសម្រាប់រដ្ឋមួយជ្រើសរើស ឬក្នុងករណីមានការអះអាងអាតីភាពនៃសំណុំស្នើសុំអន្តរជាតិដែលជ្រើសរើសតែរដ្ឋមួយ លក្ខខណ្ឌសម្រាប់នឹងអានុភាពនៃការអះអាងអាទិភាពនៅក្នុងរដ្ឋនោះត្រូវគ្រប់ដណ្តប់ដោយច្បាប់ជាតិនៃរដ្ឋនោះ។

## មាត្រា៩

## អ្នកដាក់ពាក្យ

(១) អ្នកមានទីលំនៅ ឬជនជាតិណាមួយនៃរដ្ឋហត្ថលេខីអាចដាក់សំណុំស្នើសុំអន្តរជាតិបាន។

(២) សន្និបាតអាចសម្រេចអនុញ្ញាតអោយអ្នកមានទទីលៅនៅ និងជនជាតិនៃរដ្ឋហត្ថលេខី ណាមួយនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីការពារកម្មសិទ្ធិឧស្សាហកម្ម ដែលមិនមែនជាហត្ថលេខីនៃសន្ធិសញ្ញានេះ ដាក់សំណុំលិខិតស្នើសុំអន្តរជាតិបាន។

(៣) គោលការណ៍នៃទីលំនៅ និងសញ្ជាតិ និងការអនុវត្តគោលបំណងទាំងនោះក្នុងករណីមានអ្នកដាក់ពាក្យសុំច្រើន ឬក្នុងករណីអ្នកដាក់ពាក្យស្នើសុំមិនដូចគ្នាសម្រាប់គ្រប់រដ្ឋជ្រើសរើសទាំងអស់ត្រូវកំណត់សេចក្តីក្នុងបទបញ្ជា។

## មាត្រា១០

## ការិយាល័យ

សំណុំលិខិតស្នើសុំជាតិ ត្រូវតែដាក់នៅការិយាល័យទទួលដែលបានកំណត់ ដែលការិយាល័យនឹងធ្វើការពិនិត្យ និងដំណើរការចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដូចមានចែងក្នុងសន្ធិសញ្ញា និងបទបញ្ជា។

## មាត្រា១១

## កាលបរិច្ឆេទនៃការសុំចុះបញ្ជី និងអានុភាពនៃសំណុំលិខិតស្នើសុំអន្តរជាតិ

(១) ការិយាល័យទទួល ត្រូវកត់ត្រាកាលបរិច្ឆេទទទួលសំណុំលិខិតស្នើសុំអន្តរជាតិ ជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីអន្តរជាតិ អោយតែការិយាល័យទទួលនោះបានរកឃើញ នៅពេលដែលទទួលពាក្យសុំ ៖

(i) អ្នកដាក់ពាក្យសុំមិនខ្វះនូវព័ត៌មានអំពីលំនៅ ឬសញ្ជាតិដែលជាមូលដ្ឋាននៃសិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ នៅការិយាល័យទទួល

(ii) សំណុំលិខិតស្នើសុំអន្តរជាតិត្រូវធ្វើជាភាសា ដែលបានកំណត់

(iii) សំណុំលិខិតស្នើសុំអន្តរជាតិមានយ៉ាងហោចណាស់នូវធាតុទាំងឡាយដូចតទៅ:

ក. ការបញ្ជាក់ថា សំណុំលិខិតស្នើសុំនេះត្រូវបានគ្រោងទុកជាសំណុំលិខិតស្នើសុំអន្តរជាតិ

ខ. មានការជ្រើសរើសយ៉ាងហោចណាស់ក៏រដ្ឋហត្ថលេខីមួយ

គ. ឈ្មោះអ្នកដាក់ពាក្យសុំដូចបានពណ៌នា

ឃ. ផ្នែកមួយនៃសំណុំលិខិតលេចចេញជាសេចក្តីអធិប្បាយ

ង. ផ្នែកមួយនៃសំណុំលិខិត លេចចេញជាសេចក្តីអះអាងមួយឬ ច្រើន។

(២) ក. នៅពេលទទួលពាក្យសំណុំលិខិតស្នើសុំ ប្រសិនបើការិយាល័យទទួលពិនិត្យឃើញថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញត្រឹមត្រូវ តាមការតម្រូវទៅតាមការចែងក្នុងវាក្យខ័ណ្ឌ(១)ទេ ការិយាល័យទទួលត្រូវស្នើសុំអោយអ្នកដាក់ពាក្យសុំកែតម្រូវតាមលក្ខខណ្ឌតម្រូវនោះ ដូចមានចែងក្នុងបទបញ្ជា។

ខ. ប្រសិនបើអ្នកដាក់ពាក្យសុំអនុវត្តតាមការណែនាំ ដូចមានចែងក្នុងបទបញ្ជាការិយាល័យទទួល ត្រូវកត់ត្រាកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ ជាកាលបរិច្ឆេទនៃការសុំចុះបញ្ជី។

(៣) លើកលែងមាត្រា៦៤(៤) សំណុំលិខិតស្នើសុំអន្តរជាតិណាមួយ ដែលបំពេញតាមការតម្រូវដូចមានចែងពីចំណុច(i) ដល់ចំណុច(iii) នៃវាក្យខ័ណ្ឌ(១) នឹងដែលបានកំណត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីអន្តរជាតិ ដែលកាលបរិច្ឆេទនោះត្រូវបានចាត់ទុក ជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីជាក់ស្តែងក្នុងរដ្ឋជ្រើសរើសនីមួយៗ។

(៤) សំណុំលិខិតស្នើសុំអន្តរជាតិណាមួយ ដែលបំពេញតាមការតម្រូវដែលមានចែងក្នុងចំណុច(i) ដល់ចំណុច(iii) នៃវាក្យខ័ណ្ឌ(១) ត្រូវតែសមមូលទៅនឹងការសុំចុះបញ្ជីជាតិធម្មតា ក្នុងអត្ថន័យនៃអានុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម។

## មាត្រា១២

## ការបញ្ជូនសំណុំលិខិតស្នើសុំអន្តរជាតិទៅអោយការិយាល័យអន្តរជាតិ និង អាជ្ញាធរស្រាវជ្រាវអន្តរជាតិ

(១) ច្បាប់ចម្លងចំនួនមួយច្បាប់នៃសំណុំលិខិតស្នើសុំ ត្រូវតែរក្សាទុកដោយការិយាល័យ(home copy = ច្បាប់ចម្លងការិយាល័យ) ច្បាប់ចម្លងមួយច្បាប់ទៀត(record copy = ច្បាប់ចម្លងកត់ត្រា) ត្រូវតែបញ្ជូនទៅអោយការិយាល័យអន្តរជាតិ និងច្បាប់ចម្លងផ្សេងទៀត(search copy = ច្បាប់ចម្លងស្រាវជ្រាវ) ត្រូវតែបញ្ជូនទៅអោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិមានសមត្ថកិច្ច ដោយយោងតាមមាត្រា១៦ និងដូចមានចែងក្នុងបញ្ជា។

(២) ច្បាប់ចម្លងកត់ត្រាត្រូវតែចាត់ទុកថា ជាច្បាប់ចម្លងពិតរបស់សំណុំលិខិតស្នើសុំអន្តរជាតិ។

(៣) សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែចាត់ទុកថា បានដកហូតយកទៅវិញ ប្រសិនបើច្បាប់ចម្លងកត់ត្រា មិនទទួលដោយការិយាល័យអន្តរជាតិក្នុងរយៈពេលកំណត់។

## មាត្រា១៣

## ភាពដែលអាចរកបាននៃច្បាប់ចម្លងនៃសំណុំ

## លិខិតស្នើសុំអន្តរជាតិចំពោះការិយាល័យជ្រើសរើស

(១) ការិយាល័យជ្រើសរើសណាមួយ អាចស្នើសុំការិយាល័យអន្តរជាតិ បញ្ជូនអោយនូវច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ មុនការទំនាក់ទំនងដូចមានចែងក្នុងមាត្រា២០ ហើយការិយាល័យអន្តរជាតិត្រូវបញ្ជូនច្បាប់ចម្លងដូចនេះ ទៅអោយការិយាល័យជ្រើសរើសអោយបានឆាប់រហ័សតាមការដែលអាចធ្វើទៅបាន ក្រោយពីការផុតកំណត់ នៃរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។

(២) ក. អ្នកដាក់ពាក្យសុំអាចបញ្ជូនច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំរបស់គាត់ ទៅអោយការិយាល័យជ្រើសរើសណាមួយ នៅពេលវេលាណាមួយ។

ខ. អ្នកដាក់ពាក្យអាចស្នើសុំការិយាល័យអន្តរជាតិ បញ្ជូនច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ទៅអោយការិយាល័យណាមួយ ហើយការិយាល័យអន្តរជាតិត្រូវបញ្ជូនច្បាប់ចម្លងដូចនេះ ទៅអោយការិយាល័យជ្រើសរើសនោះអោយបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាននៅពេលវេលាណាមួយ។

គ. ការិយាល័យ ជាតិណាមួយអាចជូនដំណឹងឲ្យការិយាល័យអន្តរជាតិថា ខ្លួនមិនមានបំណងចង់ទទួលច្បាប់ចម្លង ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ(ខ) ក្នុងករណីដែលអនុវាក្យខ័ណ្ឌនោះមិនសមស្របទៅអោយការិយាល័យនោះ។

## មាត្រា១៤
## ភាពខ្វះខាតចន្លោះដ៏ជាក់លាក់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ

(១) ក. ការិយាល័យទទួលត្រូវពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិថា តើមានផ្ទុកការខ្វះខាតណាមួយដូចខាងក្រោមនេះដែរឬទេ គឺមានន័យថា

(i) មិនមានចុះហត្ថលេខា ដូចមានចែងក្នុងបញ្ញា

(ii) មិនមានការបញ្ជាក់ដូចបានកំណត់ពាក់ព័ន្ធអ្នកដាក់ពាក្យសុំ

(iii) មិនមានចំណងជើងតក្កកម្ម

(iv) មិនមានខ្លឹមសារសង្ខេប

(v) មិនបានបំពេញតាមការកំណត់ក្នុងបទបញ្ញា ព្រមទាំងការតម្រូវផ្នែករូបសាស្ត្រដូចបានកំណត់។

ខ. ប្រសិនបើការិយាល័យទទួលពិនិត្យឃើញថា មានការខ្វះខាតណាមួយខាងលើការិយាល័យទទួលត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ឲ្យកែតម្រូវសំណុំលិខិតស្នើសុំអន្តរជាតិក្នុងរយៈពេលកំណត់។ ក្នុងករណីមានការខកខានមិនបានបំពេញទេនោះ សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែចាត់ទុកថា បានដកយកទៅវិញ ហើយការិយាល័យទទួលត្រូវប្រកាសព័ត៌មាននេះផងដែរ។

(២) ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិយោងទៅគំនូសបង្ហាញ ដែលតាមការជាក់ស្តែងមិនត្រូវបានបញ្ចូលក្នុងសំណុំលិខិតនោះទេ ការិយាល័យទទួលត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីហេតុការណ៍នេះ ហើយអ្នកដាក់ពាក្យសុំអាចផ្តល់ទៅឱ្យការិយាល័យក្នុងរយៈពេកកំណត់ ហើយប្រសិនបើគាត់បានបំពេញហើយនោះ កាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិត្រូវតែជាការបរិច្ឆេទដែលការិយាល័យទទួលនិង បានទទួលគំនូស

បង្ហាញនោះ។ បើពុំដូច្នេះទេ ការយោងណាមួយទៅនឹងគំនូបង្ហាញដែលបានរៀបរាប់នេះត្រូវតែចាត់ទុកថាលែងមានទៀតហើយ។

(៣) ក. ប្រសិនបើការិយាល័យទទួលពិនិត្យឃើញថា កម្រៃដែលបានកំណត់ដូចមានចែងក្នុងមាត្រា៤ (iv) មិនត្រូវបានបង់តាមពេលកំណត់ទេនោះ ឬកម្រៃដែលបានកំណត់ដូចមានចែងក្នុងមាត្រា៤(២) មិនត្រូវបានបង់ពាក់ព័ន្ធទៅនឹងរដ្ឋជ្រើសរើសណាមួយ នោះសំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែចាត់ទុកថា បានដកយកទៅវិញ ហើយការិយាល័យទទួលត្រូវប្រកាសអំពីព័ត៌មាននេះផងដែរ។

## មាត្រា១៥
## ការស្រាវជ្រាវអន្តរជាតិ

(១) សំណុំលិខិតស្នើសុំអន្តរជាតិនីមួយៗ ត្រូវតែឆ្លងកាត់ការស្រាវជ្រាវអន្តរជាតិ។

(២) កម្មវត្ថុនៃការស្រាវជ្រាវអន្តរជាតិគឺ ស្វែងរកស្នាដៃមុន (prior art) ដែលពាក់ព័ន្ធ។

(៣) ការស្រាវជ្រាវអន្តរជាតិត្រូវតែធ្វើដោយពឹងផ្អែកលើសេចក្តីអធិប្បាយ និងគំនូសបង្ហាញ(ប្រសិនបើមាន)។

(៤) អាជ្ញាធរស្រាវជ្រាវអន្តរជាតិ ដូចមានចែងក្នុងមាត្រា៦ ត្រូវខិតខំប្រឹងប្រែងស្វែងរកស្នាដៃមុន ដែលពាក់ព័ន្ធអោយបានច្រើនតាមលទ្ធភាពខ្លួនមាន (is facilities permit) ហើយក្នុងករណីខ្លះត្រូវមើលឯកសារដែលបញ្ជាក់ក្នុងបទបញ្ជា។

(៥) ក. ប្រសិនបើច្បាប់ជាតិនៃរដ្ឋហត្ថលេខីអនុញ្ញាត អ្នកដាក់ពាក្យសុំលិខិតស្នើសុំជាតិ នៅការិយាល័យជាតិរបស់រដ្ឋនោះ ឬនៅការិយាល័យដែលបំពេញតួនាទីជំនួសរដ្ឋនោះ អាចស្នើថាការស្រាវជ្រាវដែលស្រដៀងការស្រាវជ្រាវអន្តរជាតិ (ការស្រាវជ្រាវបែបអន្តរជាតិ) ត្រូវអនុវត្តលើសំណុំលិខិតស្នើសុំ លើកលែងតែមានលក្ខខណ្ឌចែងក្នុងច្បាប់នោះ។

ខ. ប្រសិនបើច្បាប់នៃរដ្ឋហត្ថលេខី អនុញ្ញាតិអោយការិយាល័យជាតិនៃរដ្ឋនោះ ឬការិយាល័យដែលបំពេញតួនាទីជំនួសរដ្ឋនោះ អាចអនុវត្តការស្រាវជ្រាវបែបអន្តរជាតិដែលបានដាក់នៅការិយាល័យនោះ។

គ. ការស្រាវជ្រាវបែបអន្តរជាតិត្រូវតែអនុវត្តដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ យោងតាមមាត្រា១៦ ដែលជាអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការស្រាវជ្រាវអន្តរជាតិ ប្រសិនបើសំណុំលិខិតស្នើសុំជាតិក្លាយទៅជាសំណុំលិខិតស្នើសុំអន្តរជាតិ ហើយត្រូវបានដាក់នៅការិយាល័យដោយយោងតាមវាក្យខ័ណ្ឌ (ក) និង(ខ)។ ប្រសិនបើសំណុំលិខិតស្នើសុំជាតិត្រូវបានសរសេរជាភាសាដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិយល់ឃើញថា មិនអាចយកទៅអនុវត្តបានក្នុងការស្រាវជ្រាវបែបអន្តរជាតិ ត្រូវតែអនុវត្តលើការបកប្រែដែលរៀបចំដោយអ្នកដាក់ពាក្យស្នើសុំជាភាសាដែលបានកំណត់ សម្រាប់លិខិតស្នើសុំអន្តរជាតិ ហើយដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិទទួលយកបាន សម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិ។ នៅពេលមានការតម្រូវសំណុំលិខិតស្នើសុំជាតិ និងការបកប្រែត្រូវតែរៀបចំឡើងតាមទម្រង់ដែលបានកំណត់សម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិ។

## មាត្រា១៦
## អាជ្ញាធរស្រាវជ្រាវអន្តរជាតិ

(១) ការស្រាវជ្រាវអន្តរជាតិត្រូវតែអនុវត្តដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ដែលអាចជាការិយាល័យជាតិ ឬក៏ជាអង្គការអន្តររដ្ឋាភិបាលដូចជា វិទ្យុស្ថានប្រកាសនីយបត្រតក្កកម្មអន្តរជាតិដែលមានភារកិច្ចជាច្រើន រាប់បញ្ចូលទាំងការបង្កើតឯកសាររបាយការណ៍ស្រាវជ្រាវ អំពីស្នាដៃមុនដែលពាក់ព័ន្ធទៅនឹងតក្កកម្ម ដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំ។

(២) ក្នុងពេលរងចាំបង្កើតអាជ្ញាធរស្រាវជ្រាវអន្តរជាតិរួមតែមួយ ប្រសិនបើមានអាជ្ញាធរស្រាវជ្រាវអន្តរជាតិច្រើន ការិយាល័យទទួលនីមួយៗត្រូវកំណត់នូវអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការស្រាវជ្រាវសំណុំលិខិតស្នើសុំអន្តរជាតិទាំងឡាយដែលដាក់នៅការិយាល័យរបស់ខ្លួន ដោយយោងតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដែលអាចមានដូចមានចែងក្នុងវាក្យខ័ណ្ឌ(៣)(ខ)។

(៣) ក. អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវតែតែងតាំងដោយមហាសន្និបាត។ ការិយាល័យជាតិ និងអង្គការអន្តររដ្ឋភិបាលដែលបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ(គ) អាចត្រូវបានតែងតាំងជាអាជ្ញាធរស្រាវជ្រាវអន្តរជាតិ។

ខ. ការតែងតាំងត្រូវមានលក្ខខណ្ឌដោយឈរលើការយល់ព្រមរបស់ការិយាល័យជាតិ ឬអង្គការអន្តររដ្ឋាភិបាលដែលនឹងតែងតាំង និងចុះកិច្ចព្រមព្រៀងរវាងការិយាល័យនោះ ឬអង្គការនោះ និងការិយាល័យអន្តរជាតិហើយដែលកិច្ចព្រមព្រៀងត្រូវសុំការអនុម័តពីសភា។ កិច្ចព្រមព្រៀងកំណត់សិទ្ធិ និងកាតព្វកិច្ចទាំងឡាយរបស់គ្រប់ភាគី ជាពិសេសទម្រង់ការដែលទទួលរ៉ាប់រងដោយការិយាល័យនោះ ឬអង្គការនោះដើម្បីអនុវត្ត និងប្រព្រឹត្តតាមបទបញ្ញារួមទាំងអស់របស់ការស្រាវជ្រាវអន្តរជាតិ។

គ. បទបញ្ញាចែងអំពីលក្ខខណ្ឌតម្រូវអប្បរមា ជាពិសេសអំពីកម្លាំងមនុស្ស និងឯកសារដែលការិយាល័យណាមួយ ឬអង្គការមួយត្រូវបំពេញអោយបានត្រឹមត្រូវជាមុន មុនពេលអាចបានតែងតាំង និងត្រូវបន្តបំពេញអោយបានត្រឹមត្រូវទៅទៀត ក្រោយពេលត្រូវបានតែងតាំងរួចហើយ។

ឃ. ការតែងតាំងត្រូវបានតែបានធ្វើសម្រាប់រយៈពេលកំណត់ ហើយអាចពន្យារពេលទៀតបាន។

ង. មុនពេលសន្និបាតធ្វើការសម្រេចស្តីពីការតែងតាំងការិយាល័យជាតិណាមួយ ឬអង្គការអន្តររដ្ឋាភិបាលណាមួយ ឬស្តីពីការពន្យល់ការតែងតាំងបន្តទៀត ឬមុនពេលសន្និបាតអនុញ្ញាតអោយចាត់ទុកជាការមិនបានការនូវការតែងតាំងដូចនោះណាមួយ សន្និបាតត្រូវបានស្តាប់យោបល់ការិយាល័យពាក់ព័ន្ធ ឬអង្គការពាក់ព័ន្ធហើយស្វែងរកឱវាទរបស់គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស ដូចមានចែងក្នុងមាត្រា៥៦ដែលគណៈកម្មការនេះត្រូវបង្កើត។

## មាត្រា១៧
## បែបបទចំពោះមុខអាជ្ញាធរស្រាវជ្រាវអន្តរជាតិ

(១) បែបបទចំពោះមុខអាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវតែកំណត់ដោយបទប្បញ្ញត្តិនានានៃសន្ធិសញ្ញានេះបទបញ្ញាទាំងឡាយ និងកិច្ចព្រមព្រៀងដែលការិយាល័យអន្តរជាតិបានចុះហត្ថលេខាជាមួយអាជ្ញាធរនោះយោងតាមសន្ធិសញ្ញា និងបទបញ្ញាទាំងឡាយ។

(២) ក. ប្រសិនបើអាជ្ញាធរស្រាវជ្រាវអន្តរជាតិចាត់ទុកះ

(i) ថាសំណុំលិខិតស្នើសុំអន្តរជាតិពាក់ព័ន្ធទៅនឹងកម្មវត្ថុដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិមិនតម្រូវអោយធ្វើការស្រាវជ្រាវដូចមានចែងក្នុងបទបញ្ជាហើយក្នុងករណីណាមួយនោះសម្រេចមិនធ្វើការស្រាវជ្រាវ។

(ii) ថាសេចក្ដីអធិប្បាយសេចក្ដីអះអាង ឬគំនូសបង្ហាញមិនបានបំពេញតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ ដែលនាំអោយការស្រាវជ្រាវដ៏មានអត្ថន័យមួយមិនអាចត្រូវអនុវត្តបានអាជ្ញាធរនោះត្រូវតែប្រកាស និងត្រូវជូនដំណឹងអ្នកដាក់ពាក្យសុំនិងការិយាល័យអន្តរជាតិថាគ្មានរបាយការណ៍ស្រាវជ្រាវនឹងត្រូវធ្វើទេ។

ខ. ប្រសិនបើគោលការណ៍ណាមួយនៃសភាពការណ៍ទាំងឡាយដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក) ត្រូវពិនិត្យឃើញថា កើតមានជាប់ពាក់ព័ន្ធជាមួយតែសេចក្ដីអះអាងដ៏ជាក់លាក់របាយការណ៍នោះត្រូវតែធ្វើដូចមានចែងក្នុងមាត្រា១៨។

(៣) ក. ប្រសិនបើអាជ្ញាធរស្រាវជ្រាវអន្តរជាតិចាត់ទុកថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃការចូលរួមបញ្ចូលនៃតក្កកម្មដូចមានចែងក្នុងបទបញ្ជាទេនោះ អាជ្ញាធរត្រូវអញ្ជើញអ្នកដាក់ពាក្យសុំអោយបង់កម្រៃបន្ថែម។ អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវធ្វើរបាយការណ៍ស្រាវជ្រាវអន្តរជាតិ អំពីផ្នែកទាំងឡាយរបស់សំណុំលិខិតស្នើសុំអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងតក្កកម្មដែលបានបញ្ជាក់លើកដំបូងក្នុងសេចក្ដីអះអាង (តក្កកម្មចម្បង) និងកម្រៃបន្ថែមតាមលក្ខខណ្ឌតម្រូវដែលត្រូវបានបង់ក្នុងពេលវេលាកំណត់ ហើយអំពីផ្នែកទាំងឡាយរបស់សំណុំលិខិតស្នើសុំអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងតក្កកម្មទាំងនោះដែលកម្រៃនោះត្រូវបានបង់រួចហើយ។

ខ. ច្បាប់ជាតិនៃរដ្ឋជ្រើសរើសអាចចែងថា ក្នុងករណីការិយាល័យជាតិរបស់រដ្ឋនោះពិនិត្យឃើញថាការអញ្ជើញរបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិដូចមានចែងក្នុងអនុវាក្យខណ្ឌ(ក) បានធ្វើត្រឹមត្រូវហើយ ករណីអ្នកដាក់ពាក្យស្នើសុំមិនបានបង់កម្រៃបន្ថែមទាំងអស់ ផ្នែកទាំងឡាយរបស់សំណុំលិខិតស្នើសុំអន្តរជាតិដែលជាផលវិបាកមិនបានស្រាវជ្រាវ ត្រូវចាត់ទុកថាបានដកហូតយកទៅវិញ លុះត្រាតែអ្នកដាក់ពាក្យបានបង់កម្រៃពិសេសជូនការិយាល័យជាតិនៃរដ្ឋនោះដែលនៅមានអានុភាពលើសំណុំលិខិតនោះនៅឡើយ។

## មាត្រា១៨

## របាយការណ៍ស្រាវជ្រាវអន្តរជាតិ

(១) របាយការណ៍ស្រាវជ្រាវអន្តរជាតិ ត្រូវតែធ្វើក្នុងពេលវេលាកម្រិតតាមការកំណត់ និងក្នុងទម្រង់តាមការកំណត់។

(២) អាជ្ញាធរស្រាវជ្រាវអន្តរជាតិ ត្រូវបញ្ជូលរបាយការណ៍ស្រាវជ្រាវអន្តរជាតិទៅអោយអ្នកដាក់ពាក្យសុំនិងការិយាល័យអន្តរជាតិអោយបានឆាប់រហ័ស បន្ទាប់ពីរបាយការណ៍ត្រូវបានធ្វើរួចហើយ។

(៣) របាយការណ៍ស្រាវជ្រាវអន្តរជាតិ ឬសេចក្ដីប្រកាសដូចមានចែងក្នុងមាត្រា១៧(ក) ត្រូវបានបកប្រែដូចមានចែងក្នុងបទបញ្ជា។ ការបកប្រែតែរៀបចំដោយ ឬក្រោមការទទួលខុសត្រូវរបស់ការិយាល័យអន្តរជាតិ។

## មាត្រា១៩

## ការកែសម្រួលសេចក្ដីអះអាង

## នៅចំពោះមុខការិយាល័យអន្តរជាតិ

(១) ក្រោយពីបានទទួលរបាយការណ៍ស្រាវជ្រាវអន្តរជាតិ អ្នកដាក់ពាក្យសុំត្រូវបានផ្ដល់ឱកាសសម្រាប់កែសម្រួលសេចក្ដីប្រកាសរបស់សំណុំលិខិតស្នើសុំអន្តរជាតិ ដោយដាក់ការសម្រួលនៅការិយាល័យអន្តរជាតិ ក្នុងពេលវេលាកម្រិតតាមការកំណត់។ នៅពេលជាមួយគ្នានេះគាត់អាចដាក់សេចក្ដីថ្លែងបញ្ជាក់ដ៏សង្ខេបនោះអាចមានៅលើសេចក្ដីអធិប្បាយ និងគំនូសបង្ហាញ។

(២) ការកែសម្រួលមិនត្រូវធ្វើះអោយហួសពីការបញ្ចេញអោយដឹង ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ដែលបានដាក់នោះទេ។

(៣) ប្រសិនបើច្បាប់ជាតិជ្រើសរើសណាមួយ អនុញ្ញាតអោយមានការកែសម្រួលហួសពីការបញ្ចេញ ការខកខានមិនបានបំពេញដូចមានចែងក្នុងវាក្យខ័ណ្ឌ(២) មិនត្រូវមានផលវិបាកក្នុងរដ្ឋនោះទេ។

## មាត្រា២០

## ការផ្ដល់ដំណឹងទៅឲ្យការិយាល័យជ្រើសរើស

(១) ក. សំណុំលិខិតស្នើសុំអន្តរជាតិ ព្រមជាមួយនឹងរបាយកាណ៍ស្រាវជ្រាវអន្តរជាតិ រាប់បញ្ចូលទាំងការបញ្ជាក់ណាមួយ ដូចមានចែងក្នុងមាត្រា១៧(២)(ខ) ឬសេចក្ដីប្រកាស ដូចមាចែងក្នុងមាត្រា១៧ (២)(ក) ត្រូវតែផ្ដល់អោយចំពោះការិយាល័យជ្រើសរើសណានីមួយៗ ដូចមានចែងក្នុងបទបញ្ជាលុះត្រាតែការិយាល័យជ្រើសរើសបដិសេធ លក្ខខណ្ឌតម្រូវនោះទាំងស្រុង ឬក្នុងផ្នែកណាមួយ។

## មាត្រា២១

## ការចុះផ្សាយអន្តរជាតិ

(១) ការិយាល័យអន្តរជាតិ ត្រូវចុះផ្សាយសំណុំលិខិតស្នើសុំអន្តរជាតិ។

(២) (ក) យោងតាមការលើកលែង ដូចមានចែងក្នុងវាក្យខ័ណ្ឌ (ខ) និងក្នុងមាត្រា៦៤ (៣) ការចុះផ្សាយអន្តរជាតិ នូវសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវមានអានុភាពយ៉ាងឆាប់រហ័ស ក្រោយពីការផុតកំណត់រយះពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព របស់សំណុំលិខិតស្នើសុំ។

(ខ) អ្នកដាក់ពាក្យសុំ អាចស្នើការិយាល័យអន្តរជាតិឲ្យចុះផ្សាយសំណុំលិខិតស្នើសុំអន្តរជាតិរបស់គាត់ នៅពេលណាមួយមុនការផុតកំណត់នៃពេលវេលាកម្រិត ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក)។ ការិយាល័យអន្តរជាតិត្រូវដំណើរការឲ្យបានសមស្រប ដូចមានចែងក្នុងបទបញ្ជា។

(៣) របាយការណ៍ស្រាវជ្រាវអន្តរជាតិ ឬសេចក្ដីប្រកាស ដូចមានចែងក្នុងមាត្រា១៧ (២) (ក)ត្រូវតែបោះពុម្ពផ្សាយតាមការចែងក្នុងបទបញ្ជា។

(៤) ភាសានិងទម្រង់នៃការផ្សាយអន្តរជាតិ និងការលំអិតផ្សេងទៀតកំណត់ដោយបទបញ្ជា។

(៥) មិនមានការបោះផ្សាយអន្តរជាតិទេ ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបានដកហូត ឬត្រូវបានដកហូតយកទៅវិញ មុនការរៀបចំបច្ចេកទេសសម្រាប់ការបោះផ្សាយ ត្រូវបានបញ្ចប់ពេញលេញ។

(៦) ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិមានសេចក្ដីអធិប្បាយ ឬគំនូសបង្ហាញដែលការិយាល័យអន្តរជាតិយល់ឃើញថា ផ្ទុយពីសីលធម៌ ឬសណ្ដាប់ធ្នាប់សាធារណៈ ឬប្រសិនបើការិយាល័យអន្តរជាតិយល់

ឃើញថា សំណុំលិខិតស្នើសំណុំអន្តរជាតិមានសេចក្តីពណ៌នាដែលខុសស្រឡះ ដូចមានចែងក្នុងបទបញ្ជាការិយាល័យអន្តរជាតិអាចលុបសេចក្តីអធិប្បាយ គំនូសបង្ហាញនិងសេចក្តីថ្លែងបញ្ជាក់ ចេញពីការបោះផ្សាយដោយបញ្ជាក់ទីកន្លែង និងចំនួនពាក្យឬគំនូសបង្ហាញដែលបានលុបនោះ ហើយអាចផ្តល់ឲ្យច្បាប់ចម្លង នៃអត្ថបទដែលលុបនោះ ប្រសិនបើមានការសុំ។

## មាត្រា២២

## ការចម្លង ការបកប្រែ និង
## កម្រៃ ចំពោះការិយាល័យ

(១) អ្នកដាក់ពាក្យសុំ ត្រូវផ្តល់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ (លុះត្រាតែការផ្តល់ដំណឹងដូចមានចែងក្នុងមាត្រា២០បានអនុវត្តរួចហើយ) និងការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិនោះ (ដូចមានចែង) និងបង់កម្រៃជាតិ (ប្រសិនបើមាន) ជូនដល់ការិយាល័យជ្រើសរើសនីមួយៗដោយមិនយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។ ក្នុងករណីច្បាប់ជាតិនៃរដ្ឋជ្រើសរើស តម្រូវឲ្យបញ្ជាក់ឈ្មោះ និងទន្នន័យកំណត់ផ្សេងទៀត ពាក់ព័ន្ធនឹងតក្កករ ប៉ុន្តែក៏អនុញ្ញាតឲ្យបានដែរថា ការបញ្ជាក់ទាំងនោះត្រូវផ្តល់នាពេលក្រោយ បន្ទាប់ពីការចុះបញ្ជីសំណុំលិខិតស្នើសុំជាតិ អ្នកដាក់ពាក្យត្រូវផ្តល់ការបញ្ជាក់ទាំងនោះជូនដល់ការលិយាល័យជាតិនៃរដ្ឋនោះ ឬការិយាល័យដែលមានតួនាទីជំនួសរដ្ឋនោះ ដោយមិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព បើពុំដូច្នេះទេគេត្រូវបញ្ជាក់ក្នុងសំណើ។

(២) ក្នុងករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិធ្វើសេចក្តីប្រកាស ដែលមានចែងក្នុងមាត្រា១៧ (២) (ក) ថាគ្មានរបាយការណ៍ស្រាវជ្រាវអន្តរជាតិណា នឹងត្រូវទេ ពេលវេលាកម្រិតសម្រាប់អនុវត្តសកម្មភាពដូចមានចែងក្នុងវាក្យខ័ណ្ឌ (១) នៃមាត្រា ត្រូវតែដូចគ្នាដូចមានចែងក្នុងវាក្យខ័ណ្ឌ(១)។

(៣) ដើម្បីអនុវត្តសកម្មភាព ដូចមានចែងក្នុងវាក្យខ័ណ្ឌ (១) ឬ (២) ច្បាប់ជាតិណាក៏ដោយអាចកំណត់ពេលវេលាកម្រិត ដែលផុតកំណត់យឺតជាងពេលវេលាកម្រិត ដូចមានចែងក្នុងវាក្យខ័ណ្ឌទាំងនោះ។

## មាត្រា២៣

## ការពន្យារពេលដំណើរការកម្រិតជាតិ

(១) គ្មានការិយាល័យជ្រើសរើសណាមួយ ដំណើរការ ឬពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិមុនការផុតកំណត់នៃពេលវេលាកម្រិតសមស្រប ដូចមានចែងនៅក្នុងមាត្រា២២។

(២) ថ្វីបើមានបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ (១) ក៏ដោយក៏ការិយាល័យណាមួយអាចដំណើរការ ឬពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិបាននៅគ្រប់ពេលវេលា យោងលើការស្នើសុំដែលបញ្ជាក់របស់អ្នកដាក់ពាក្យសុំ។

## មាត្រា២៤

## លទ្ធភាពបាត់បង់អានុភាពក្នុងរដ្ឋជ្រើសរើស

(១) លើកលែងបទប្បញ្ញត្តិនៃមាត្រា២៥ ក្នុងករណី (ii) ខាងក្រោម អានុភាពនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដូចមានចែងក្នុងមាត្រា១១ (៣) ត្រូវបញ្ឈប់ក្នុងរដ្ឋជ្រើសរើសណាមួយ ជាមួយនឹងផលវិបាកដូចគ្នា ដូចការដកហូតយកទៅវិញនូវសំណុំលិខិតស្នើសុំក្នុងរដ្ឋនោះ

(i) ប្រសិនបើអ្នកដាក់ពាក្យសុំ ដកហូតសំណុំលិខិតស្នើសុំរបស់គាត់ ឬដកហូតការជ្រើសរើសរដ្ឋនោះ។

(ii) ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានចាត់ទុកថា បានដកហូតយកទៅវិញដោយអានុភាពនៃមាត្រា១២ (៣) (១៤) (១) (ខ) (៤) (៣) (ក) ឬ (១៤) (៤) ឬប្រសិនបើការជ្រើសរើសរដ្ឋនោះ ត្រូវបានចាត់ទុកថា បានដកហូតយកទៅវិញដោយអានុភាពនៃមាត្រា (១៤) (៣) (ខ)។

(iii) ប្រសិនបើអ្នកដាក់ពាក្យសុំ ខកខានមិនបានអនុវត្តសកម្មភាព ដូចមានចែងក្នុងមាត្រា២២ ក្នុងពេលវេលាកម្រិតសមស្រប។

(២) ទោះបីជាមានបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ (១) ក៏ដោយ ក៏ការិយាល័យជ្រើសរើសណាមួយអាចរក្សាទុកអានុភាព ដូចមានចែងក្នុងមាត្រា១១ (៣) ថ្វីបើក្នុងករណីអានុភាពនោះ មិនត្រូវបានតម្រូវឲ្យរក្សាទុក ដូចមានចែងក្នុងមាត្រា២៥ (២) ក៏ដោយ។

## មាត្រា២៥
## ការពិនិត្យឡើងវិញដោយការិយាល័យជ្រើសរើស

(១) (ក) ក្នុងករណីការិយាល័យបានបដិសេធផ្តល់កាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិ ឬបានប្រកាសថា សំណុំលិខិតស្នើសុំអន្តរជាតិត្រូវចាត់ទុកថា បានដកហូតយកមកវិញ ឬក្នុងករណីការិយាល័យអន្តរជាតិបានពិនិត្យឃើញ ដូចមានចែងក្នុងមាត្រា១២ (៣) ការិយាល័យអន្តរជាតិត្រូវធ្វើឲ្យបានឆាប់រហ័ស នូវច្បាប់ចម្លងនៃឯកសារណាមួយ ដែលមានជូនការិយាល័យជ្រើសរើសណាមួយដែលផ្តល់ឲ្យឈ្មោះឲ្យ ដោយអ្នកដាក់ពាក្យសុំតាមសំណើររបស់អ្នកដាក់ពាក្យសុំ។

(ខ) ក្នុងករណីការិយាល័យទទួលបានប្រកាសថា ការជ្រើសរើសរដ្ឋដែលផ្តល់ឲ្យមួយត្រូវចាត់ទុកថា បានដកយកទៅវិញការិយាល័យអន្តរជាតិត្រូវធ្វើឲ្យបានឆាប់រហ័សនូវច្បាប់ចម្លងនៃឯកសារណាមួយ ដែលមានជូនការិយាល័យជាតិនៃរដ្ឋតាមសំណើររបស់អ្នកដាក់ពាក្យសុំ។

(គ) សំណើរដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) ឬ (ខ) ត្រូវប្រគល់ឲ្យក្នុងពេលកម្រិតតាមការកំណត់។

(២) (ក) លើកលែងតែបទប្បញ្ញត្តិនៃវាក្យខណ្ឌ (ខ) ប្រសិនបើកម្រៃជាតិ (ប្រសិនបើមាន) ត្រូវបានបង់ និងការបកប្រែតាមការកំណត់ ត្រូវបានប្រគល់ឲ្យក្នុងពេលវេលាមានកម្រិត តាមការកំណត់នោះ ការិយាល័យជ្រើសរើសនីមួយៗត្រូវសម្រេចថា តើបដិសេធការប្រកាស ឬការពិនិត្យឃើញដូចមានចែងក្នុងវាក្យខ័ណ្ឌ១ត្រូវបានបង្ហាញសមហេតុផល ដូចមានចែងក្នុងបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ និងបទបញ្ជា ហើយប្រសិនបើមានការពិនិត្យឃើញថា ការបដិសេធ ឬការប្រកាសគឺជាលទ្ធផលនៃការភ័ន្តច្រឡំ ឬការលុបដែលស្ថិតនៅលើការទទួលខុសត្រូវរបស់ការិយាល័យទទួលអន្តរជាតិ ចំណែកអានុភាពក្នុងរដ្ឋនៃការិយាល័យជ្រើសរើស ត្រូវអនុវត្តចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដូចជាការភ័ន្តច្រឡំ ឬការលុបមិនបានកើតឡើង។

(ខ) ក្នុងករណីច្បាប់ចម្លងកត់ត្រា (recorded copy) បានទៅដល់ការិយាល័យអន្តរជាតិក្រោយការផុតកំណត់នៃពេលវេលាកម្រិត ដូចមានចែងក្នុងមាត្រា១២ (៣) ដោយមូលហេតុនៃការភ័ន្តច្រឡំណាមួយ ឬការ

លុបដែលស្ថិតនៅលើការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំ បទប្បញ្ញត្តិនៃអនុវាក្យខណ្ឌ (ក) ត្រូវអនុវត្តក្រោមកាលៈទេសៈដូចមានចែងក្នុងមាត្រា៤៨(២)។

## មាត្រា២៦
## ឱកាសសម្រាប់កែតម្រូវនៅចំពោះមុខ ការិយាល័យជ្រើសរើស

គ្មានការិយាល័យជ្រើសរើសណាមួយ ត្រូវប្រានចោលសំណុំលិខិតអន្តរជាតិទាំងស្រុង ដោយសារការមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវរបស់សន្ធិសញ្ញានេះ និងបទបញ្ជា ដោយមិនបានផ្តល់ឱកាសដំបូងឲ្យដល់អ្នកដាក់ពាក្យសុំ ដើម្បីកែតម្រូវសំណុំលិខិតស្នើសុំនោះ ដើម្បីបន្តនឹងយោងតាមបែបបទ ដូចមានចែងដោយច្បាប់ជាតិសម្រាប់សភាពការណ៍ដូចគ្នា ឬសភាពការណ៍ដែលអាចប្រៀបធៀបបានពាក់ព័ន្ធសំណុំលិខិតស្នើសុំអន្តរជាតិ។

## មាត្រា២៧
## លក្ខខណ្ឌតម្រូវជាតិ

(១) គ្មានច្បាប់ជាតិណាមួយ ត្រូវតម្រូវឲ្យបំពេញតាមលក្ខខណ្ឌតម្រូវ ពាក់ព័ន្ធទៅនឹងទម្រង់ឬអ្វីៗដែលមាននៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ដែលខុសពី ឬបន្ថែមទៅលើអ្វីដែលមានចែងក្នុងសន្ធិសញ្ញានេះ និងបទបញ្ជា។

(២) កាលដំណើរការសំណុំលិខិតស្នើសុំអន្តរជាតិបានចាប់ផ្តើម ក្នុងការិយាល័យជ្រើសរើស បទប្បញ្ញត្តិនៃវាក្យខណ្ឌ (១) ដែលមិនមានអានុភាពអនុវត្តទៅលើបទប្បញ្ញត្តិនៃមាត្រា៧ (២) ក៏មិនប្រានចោលច្បាប់ជាតិណាមួយពីការតម្រូវឲ្យផ្តល់៖

(i) នូវឈ្មោះរបស់មន្ត្រីដែលជាតិតំណាងដោយស្របច្បាប់

(ii) នូវឯកសារដែលមិនមែនជាផ្នែកនៃសំណុំលិខិតស្នើសុំអន្តរជាតិ ក៏ប៉ុន្តែជាភស្តុតាងនៃការចោទប្រកាន់ ឬសេចក្តីថ្លែងដែលធ្វើឡើងក្នុងសំណុំលិខិតស្នើសុំនោះ រាប់បញ្ចូលទាំងការបញ្ជាក់នៃសំណុំលិខិតស្នើសុំអន្តរជាតិ ដោយចុះហត្ថលេខាដោយតំណាងរបស់គាត់ ឬភ្នាក់ងារ។

(៣) សម្រាប់គោលបំណងរបស់រដ្ឋជ្រើសរើសណាមួយ ក្នុងករណីអ្នកដាក់ពាក្យសុំមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ យោងតាមច្បាប់ជាតិនៃរដ្ឋនោះ ដើម្បីដាក់លិខិតស្នើសុំជាតិពីព្រោះគាត់មិនមែនជាតក្កករ សំណុំលិខិតស្នើសុំអន្តរជាតិអាចត្រូវបានប្រានចោលដោយការិយាល័យជ្រើសរើស។

(៤) ក្នុងករណីច្បាប់ជាតិចែងអំពីទម្រង់ ឬអ្វីដែលមានចែងនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិតាមទស្សនៈរបស់អ្នកដាក់ពាក្យសុំ គឺជាលក្ខខណ្ឌតម្រូវដែលអនុគ្រោះជាងលក្ខខណ្ឌតម្រូវចំពោះសំណុំលិខិតស្នើសុំអន្តរជាតិដែលចែងដោយសន្ធិសញ្ញានេះ និងបទបញ្ជាការិយាលល័យជាតិ តុលាការនឹងស្ថាប័នមានសមត្ថកិច្ចណាមួយផ្សេងទៀតរបស់រដ្ឋជ្រើសរើស ឬការិយាល័យបំពេញតួនាទីជួសមុខរដ្ឋជ្រើសរើសនោះ និងបទបញ្ជាត្រូវអនុវត្តចំពោះសំណុំលិខិតអន្តរជាតិរបស់គាត់។

(៥) គ្មានអ្វីនៅក្នុងសន្ធិសញ្ញា និងបទបញ្ជាមានបំណងបកស្រាយជាការដាក់បញ្ញត្តិអ្វីមួយដែលកម្រិតសេរីភាពរបស់រដ្ឋនីមួយៗ គឺមានសេរីភាពក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យរបស់ច្បាប់ជាតិរបស់គេចំពោះស្នាដៃ

មុន និងលក្ខខ័ណ្ឌផ្សេងទៀតរបស់ភាពដែទ្បអាចទទួលប្រកាសនីយបត្រតក្កកម្មបាន មិនមែនជាលក្ខខ័ណ្ឌតម្រូវចំពោះទម្រង់និងអ្វីដែលមានក្នុងសំណុំលិខិតឡើយ។

(៦) ច្បាប់ជាតិអាចតម្រូវថាអ្នកដាក់ពាក្យសុំប្រគល់ប្រកាសនីយបត្រតក្កកម្មបានតាមការកំណត់ដោយច្បាប់នោះ។

(៧) ការិយាល័យទទួលណាមួយ ឬនៅពេលដែលដំណើរការនៃសំណុំលិខិតស្នើសុំអន្តរជាតិបានចាប់ផ្តើម ក្នុងការិយាល័យជ្រើសរើស ការិយាល័យនោះអាចអនុវត្តច្បាប់ជាតិដែលពាក់ព័ន្ធជាមួយនឹងលក្ខខ័ណ្ឌតម្រូវណាមួយ ដែលអ្នកដាក់ពាក្យសុំត្រូវជំនួសដោយតំណាងដែលជាភ្នាក់ងារដែលដែលមានសិទ្ធិធ្វើជាតំណាងអ្នកដាក់ពាក្យសុំ នៅចំពោះមុខការិយាល័យនោះហើយ ឬដែលអ្នកដាក់ពាក្យសុំមានអាស័យដ្ឋានក្នុងរដ្ឋជ្រើសរើសសម្រាប់គោលបំណងទទួលសេចក្តីជូនដំណឹង។

(៨) គ្មានអ្វីនៅក្នុងសន្ធិសញ្ញានេះ និងបទបញ្ជាមានបំណងដាក់កម្រិតសេរីភាពរបស់រដ្ឋដែលជាម្ចាស់ហត្ថលេខីណាមួយដើម្បីអនុវត្តវិធានការដែលចាត់ទុកថា ចាំបាច់សម្រាប់ការរក្សាសន្តិសុខជាតិរបស់ខ្លួនក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចទូទៅរបស់រដ្ឋនោះ។

## មាត្រា២៨

## ការកែសម្រួល នៃសេចក្តអះអាង សេចក្តីអធិប្បាយ និងគំនូសបង្ហាញ នៅចំពោះមុខការិយាល័យជ្រើសរើស

(១) អ្នកដាក់ពាក្យសុំត្រូវផ្តល់ឱកាសឲ្យកែសម្រួល សេចក្តីអះអាង សេចក្តីអធិប្បាយ និងគំនូសបង្ហាញនៅចំពោះមុខ ការិយាល័យជ្រើសរើស ក្នុងពេលវេលាកម្រិតតាមការកំណត់។ គ្មានការិយាល័យជ្រើនរើសណាត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬបដិសេដការផ្តល់ប្រកាសនីយបត្រតក្កកម្មមុនការផុតកំណត់នៃពេលវេលាកម្រិតឡើយ លើកលែងមានការយល់ព្រមដែលមានការបញ្ជាក់ពីអ្នកដាក់ពាក្យសុំ។

(២) ការកែសម្រួលមិនត្រូវធ្វើឲ្យហួសពីការបញ្ចេញឲ្យដឹងនូវសំណុំលិខិតស្នើសុំ អន្តរជាតិដែលបានដាក់នោះឡើយ លុះត្រាតែច្បាប់ជាតិរបស់រដ្ឋជ្រើសរើសអនុញ្ញាតឲ្យកែប្រែធ្វើហួសពីការបញ្ចេញឲ្យដឹងនោះ។

(៣) ការកែប្រែ ត្រូវតែសមស្របទៅតាមច្បាប់ជាតិរបស់រដ្ឋជ្រើសរើស ក្នុងគ្រប់ការពាក់ព័ន្ធដែលមិនមានចែងក្នុងសន្ធិសញ្ញានេះ និងបទបញ្ជា។

(៤) ក្នុងករណីការិយាល័យជ្រើសរើស តម្រូវឲ្យមានការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិ ការកែប្រែត្រូវធ្វើជាភាសានៃការបកប្រែនោះ ( the language of the translation)។

## មាត្រា២៩

## អានុភាពនៃការបោះពុម្ពផ្សាយអន្តរជាតិ

(១) ចំណែកឯការការពារសិទ្ធិណាមួយរបស់អ្នកដាក់ពាក្យសុំក្នុងរដ្ឋជ្រើសរើស អានុភាពនៃការបោះពុម្ពផ្សាយអន្តរជាតិ របស់សំណុំលិខិតស្នើសុំអន្តរជាតិនៅក្នុងរដ្ឋនោះ ត្រូវតែដូចអ្វីដែលច្បាប់ជាតិនៃរដ្ឋជ្រើសរើស ចែងសម្រាប់ការបោះពុម្ពផ្សាយជាតិ ដែលខានមិនបាននូវសំណុំលិខិតស្នើសុំជាតិ ដែលមិនទាន់បានពិនិត្យលើកលែងតែបទប្បញ្ញត្តិនៃវាក្យខណ្ឌ (២) ដល់វាក្យខណ្ឌ (៤)។

(២) ប្រសិនបើភាសាដែលមានអានុភាពនៃការបោះពុម្ពផ្សាយអន្តរជាតិ ខុសពីភាសាដែលមានអានុភាពក្នុងការចុះផ្សាយ តាមការចែងនៃច្បាប់ជាតិ នៅក្នុងរដ្ឋជ្រើសរើស ច្បាប់ជាតិនោះអាចចែងថា អានុភាពដែលមានចែងក្នុងវាក្យខ័ណ្ឌ(១) ត្រូវអនុវត្តបាន តែចាប់ពីពេលវេលាដូចខាងក្រោមនេះ។

(i) ការបកប្រែភាសាក្រោយ (the latter language) ត្រូវបានបោះពុម្ពផ្សាយដូចមានចែងក្នុងច្បាប់ជាតិឬ

(ii) ការបកប្រែភាសាក្រោយត្រូវបានផ្សព្វផ្សាយដល់សាធារណៈ ដូចមានចែងក្នុងច្បាប់ជាតិឬ

(iii) ការបកប្រែភាសាក្រោយត្រូវបានបញ្ជូនដោយដាក់ពាក្យសុំចំពោះការជាក់ស្តែង

(iv) សកម្មភាពទាំងពីដូចមានចែង (i) (iii) ឬសកម្មភាពទាំងពីរដូចមានចែងក្នុង (ii) ត្រូវបានប្រកាន់យក។

(៣) ក្នុងករណីការបោះពុម្ពផ្សាយអន្តរជាតិត្រូវមានអានុភាព ច្បាប់ជាតិនៃរដ្ឋជ្រើសរើសណាមួយអាចចែងថា តាមសំណើររបស់ដាក់ពាក្យសុំមុនការផុតកំណត់នៃរយៈពេល១៨ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព អានុភាពដូចមានចែងក្នុងវាក្យខ័ណ្ឌ (១) ត្រូវតែអាចអនុវត្តបាន ចាប់ពីកាលផុតកំណត់រយៈពេល១៨ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។

(៤) ច្បាប់ជាតិនៃរដ្ឋជ្រើរើសណាមួយអាចចែងថា អានុភាពដូចមានចែងក្នុងវាក្យខ័ណ្ឌ (១) ត្រូវតែអនុវត្តបាន តែបន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដូចបានបោះពុម្ពផ្សាយ ដូចមានចែងក្នុងមាត្រា២១ ត្រូវបានទទួលនៅការិយាល័យជាតិនៃរដ្ឋនោះ ឬការិយាល័យដែលដើរតួនាទីជំនួសរដ្ឋនោះ។ ការិយាល័យនោះត្រូវចុះកាលបរិច្ឆេទនៃការទទួលក្នុងព្រឹត្តិបត្ររបស់គេ ឲ្យបានឆាប់រហ័ស។

## មាត្រា៣០

## លក្ខណៈសម្ងាត់របស់សំណុំលិខិតស្នើសុំអន្តរជាតិ

(១) (ក) លើកលែងបទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌ (ខ) ការិយាល័យអន្តរជាតិ និងអាជ្ញាធរស្រាវជ្រាវអន្តរជាតិនានា មិនត្រូវអនុញ្ញាតឲ្យបុគ្គលណា ឬអាជ្ញាធរមួយពិនិត្យមើលសំណុំលិខិតស្នើសុំអន្តរជាតិ មុនការបោះពុម្ពផ្សាយអន្តរជាតិរបស់សំណុំលិខិតស្នើសុំនោះឡើយ លុះត្រាតែមានសំណើរ ឬការអនុញ្ញាតពីអ្នកដាក់ពាក្យសុំ។

(ខ) បទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌ (ក) មិនត្រូវអនុវត្តចំពោះការបញ្ជូនទៅកាន់អាជ្ញាធរស្រាវជ្រាវអន្តរជាតិមានសមត្ថកិច្ច ចំពោះការបញ្ជូនដូចមានចែងក្នុងមាត្រា១៣ និងចំពោះការទាក់ទងដូចមានចែងក្នុងមាត្រា២០។

(២) (ក) គ្មានការិយាល័យជាតិណា ផ្តល់ការអនុញ្ញាតឲ្យមានការពិនិត្យមើលសំណុំលិខិតស្នើសុំអន្តរជាតិ ដោយភាគីទីបីឡើយ មុនកាលបរិច្ឆេទដំបូងបំផុតដូចខាងក្រោម៖

(i) កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយអន្តរជាតិនៃសំណុំលិខិតស្នើសុំអន្តរជាតិ

(ii) កាលបរិច្ឆេទនៃទំនាក់ទំនងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដូចមានចែងក្នុងមាត្រា២០

(iii) ការបរិច្ឆេទនៃការទទួលនូវច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដូចមានចែងក្នុងមាត្រា ២២។

(ខ) បទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌ (ក) មិនត្រូវបញ្ចៀសការិយាល័យជាតិណាមួយ ពីការជូនព័ត៌មានឲ្យភាគីទីបីថា សំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានជ្រើសរើស ឬបញ្ចៀសពីការបោះពុម្ពផ្សាយកត្តានោះ។ ដូច្នេះ ព័ត៌មានទាំងនេះ ឬការបោះពុម្ពផ្សាយអាចមានព័ត៌មានដូចតទៅនេះ អត្តសញ្ញាណរបស់ការិយាល័យទទួល ឈ្មោះរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិ លេខសំណុំលិខិតស្នើសុំអន្តរជាតិ និងចំណងជើងរបស់តក្កកម្ម។

(គ) បទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌ (ក) មិនត្រូវបញ្ចៀសការិយាល័យជ្រើសពីការអនុញ្ញាតឲ្យពិនិត្យមើលសំណុំលិខិតស្នើសុំអន្តរជាតិ សម្រាប់គោលបំណងរបស់អាជ្ញាធរតុលាការ (judicial authorities) ឡើយ។

(៣) បទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌ២ (ក) ត្រូវអនុវត្តចំពោះការិយាល័យទទួលណាមួយ លើកលែងតែពាក់ព័ន្ធទៅនឹងការបញ្ជូន ដូចមានចែងក្នុងមាត្រា១២ (១)។

(៤) សម្រាប់គោលបំណងនៃមាត្រានេះពាក្យ (ពិនិត្យមើល) គឺគ្របដណ្តប់លើមធ្យោបាយណាមួយដែលភាគីទីបីអាចទទួលដឹងបាន រួមទាំងការទាក់ទងទីទៃពីគ្នា (individual communication) និងការបោះពុម្ពផ្សាយជាទូទៅ។ ដូច្នេះមានន័យថា គ្មានការិយាល័យជាតិត្រូវបោះពុម្ពផ្សាយសំណុំលិខិតស្នើសុំអន្តរជាតិជាទូទៅ ឬបោះពុម្ពផ្សាយការបកប្រែនៃសំណុំលិខិតស្នើសុំនោះមុនការចុះផ្សាយអន្តរជាតិឡើយ ឬមុនកាលកំណត់នៃរយៈពេល២០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព ប្រសិនបើកា ារបោះពុម្ពផ្សាយអន្តរជាតិមិនទាន់បានសម្រេចរហូតដល់ការផុតកំណត់នៃរយៈពេល២០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាពនោះ។

## ជំពូកទី២

## ការពិនិត្យជំហានដំបូងអន្តរជាតិ

### មាត្រា៣១

### កាលបរិច្ឆេទសម្រាប់ការពិនិត្យ ជំហ៊ានដំបូងអន្តរជាតិ

(១) ឈរនៅលើការទាមទាររបស់អ្នកដាក់ពាក្យសុំសំណុំលិខិតស្នើសុំអន្តរជាតិ របស់គាត់ត្រូវឆ្លងកាត់ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ដូចមានចែងក្នុងបទប្បញ្ញត្តិដូចតទៅនេះ និងបញ្ញា។

(២) (ក) អ្នកដាក់ពាក្យសុំណាដែលមានទីលំនៅ ឬជាប្រជាជាតិរបស់រដ្ឋហត្ថលេខីដែលចែងដោយជំពូកទី២ ដូចមានចែងក្នុងបទបញ្ញាហើយសំណុំលិខិតស្នើសុំអន្តរជាតិរបស់គេត្រូវបានដាក់នៅការិយាល័យទទួលនៃរដ្ឋនោះ ឬការិយាល័យដែលមានតួនាទីជំនួសរដ្ឋនោះ អាចធ្វើការទាមទារការពិនិត្យជំហ៊ានដំបូងអន្តរជាតិ។

(ខ) សន្និបាតអាចអនុញ្ញាតសម្រេចឲ្យបុគ្គល ដែលបានទទួលសិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ទាមទារការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ថ្វីបើគេជាជនដែលមានទីលំនៅ ឬប្រជាជាតិនៃរដ្ឋដែលមិនមែនជាហត្ថលេខីនៃសន្ធិសញ្ញានេះ ឬរដ្ឋដែលចងដោយជំពូកទី២ក៏ដោយ។

(៣) ការទាមទារសម្រាប់ការពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវធ្វើដោយឡែកពីសំណុំលិខិតស្នើសុំអន្តរជាតិ។ ការទាមទារត្រូវមានការចែងជាក់លាក់ និងត្រូវតែធ្វើជាភាសា និងតាមទម្រង់ដែលបានកំណត់។

(៤) (ក) ការទាមទារត្រូវបញ្ជាក់រដ្ឋហត្ថលេខី ឬរដ្ឋដែលអ្នកដាក់ពាក្យសុំមានបំណងប្រើប្រាស់លទ្ធផលនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ (រដ្ឋជ្រើសតាង) រដ្ឋហត្ថលេខីបន្ថែមទៀតអាចត្រូវបានជ្រើសតាងជាក្រោយ។ ការជ្រើសតាងអាចពាក់ព័ន្ធចំពោះតែរដ្ឋហត្ថលេខី ដែលត្រូវបានជ្រើសរើសរួចហើយ ដូចមានចែងក្នុងមាត្រា៤។

(ខ) អ្នកដាក់ពាក្យសុំដូចមានចែងក្នុងវាក្យខ័ណ្ឌ (២) (ក) អាចជ្រើសតាងរដ្ឋហត្ថលេខីណាមួយដែលចងដោយជំពូក២។ អ្នកដាក់ពាក្យសុំដូចមានចែងក្នុងវាក្យខ័ណ្ឌ (២) (ខ) អាចជ្រើសតាងរដ្ឋហត្ថលេខីណាដែលចងដោយជំពូកទី២ ដូចដែលបានប្រកាសថា រដ្ឋទាំងនោះត្រូវបានរៀបចំជ្រើសតាងដោយដោយអ្នកដាក់ពាក្យសុំ។

(៥) ការទាមទារត្រូវបង់កម្រៃតាមការកំណត់ ក្នុងពេលវេលាកម្រិតតាមការកំណត់។

(៦)(ក) ការទាមទារត្រូវដាក់នៅអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៣២។

(ខ) ការជ្រើសតាងក្រោយណាមួយ ត្រូវតែដាក់នៅការិយាល័យអន្តរជាតិ។

(គ) ការិយាល័យជ្រើសតាងនីមួយៗ ត្រូវតែជូនដំណឹងអំពីការជ្រើសតាងរបស់ខ្លួននោះ។

## មាត្រា៣២
## អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ

(១) ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវតែអនុវត្តដោយអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ។

(២) ក្នុងការទាមទារដូចមានចែងក្នុងមាត្រា៣១ (២) (ខ) សន្និបាតត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ដល់អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ ឬ អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ដោយយោងតាមកិច្ចព្រមព្រៀងដែលអាចអនុវត្តបាន រវាងអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិមួយ ឬច្រើនដែលជាប់ពាក់ព័ន្ធនឹងការិយាល័យអន្តរជាតិ។

(៣) បទប្បញ្ញត្តិនៃមាត្រា១៦ (៣) ត្រូវយកមកអនុវត្តដូចគ្នាពាក់ព័ន្ធទៅននឹងអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ។

## មាត្រា៣៣
## ការពិនិត្យជំហ៊ានដំបូងអន្តរជាតិ

(១) កម្មវត្ថុនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ គឺចងក្រងយោបល់ជំហ៊ានដំបូង និងយោបល់ដោយគ្មានការបង្ខិតបង្ខំអំពីសំណួរថា តើតក្កកម្មដែលបានអះអាងនោះ មានភាពថ្មី មានជំហ៊ាននៃការរកឃើញថ្មី (to benon-obvious) និងអាចយកមកអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មដែរឬទេ។

(២) សម្រាប់គោលបំណងនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ តក្កកម្មដែលបានអះអាងត្រូវបានចាត់ទុកថាថ្មី ប្រសិនបើតក្កកម្មនោះ មិនដូចស្នាដៃមុន ដូចមានចែងក្នុងបទបញ្ជា។

(៣) សម្រាប់គោលបំណងនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ដោយគិតទៅដល់ស្នាដៃមុនដូចមានចែងក្នុងបទបញ្ជា តក្កកម្មដែលបានអះអាងត្រូវចាត់ទុកថា មានជំហ៊ានជំហ៊ានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះ

មិនអាចឲ្យបុគ្គលណាមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន នៅកាលបរិច្ឆេទពាក់ព័ន្ធតាមកាលកំណត់នោះ។

(៤) សម្រាប់គោលបំណងនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ តក្កកម្មត្រូវចាត់ទុកថា អាចអនុវត្តក្នុងវិស័យឧស្សាហកម្មបាន ប្រសិនបើតក្កកម្មនោះត្រូវបានផលិត ឬប្រើប្រាស់ (ក្នុងន័យបច្ចេកវិទ្យា) នៅក្នុងប្រភេទនៃឧស្សាហកម្មបាន យោងតាមលក្ខណៈរបស់តក្កកម្ម។ **ឧស្សាហកម្ម** ត្រូវបានយល់នៅក្នុងអត្ថន័យទូលាយ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម។

(៥) លក្ខណៈវិនិច្ឆ័យដែលបានចែងខាងលើ គ្រាន់តែគោលបំណងនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិ។ រដ្ឋហត្ថលេខីណាមួយដែលអាចអនុវត្តលក្ខណៈវិនិច្ឆ័យខុសប្លែកដើម្បីគោលបំណងសម្រេចថា តើតក្កកម្មដែលបានអះអាង អាចទទួលប្រកាសនីយបត្រតក្កកម្មបានដែរឬទេ នៅរដ្ឋនោះ។

(៦) ការពិនិត្យជំហានដំបូងអន្តរជាតិត្រូវតែគិតទៅដល់ ឯកសារទាំងអស់ដែលបានរកឃើញក្នុងរបាយការស្រាវជ្រាវអន្តរជាតិ។ ការពិនិត្យនេះអាចគិតទៅដល់ឯកសារបន្ថែមណាមួយដែលបានចាត់ទុកថា មានការពាក់ព័ន្ធនៅក្នុងករណីជាក់លាក់ណាមួយ។

## មាត្រា៣៤
## នីតិវិធីនៅចំពោះមុខអាជ្ញាធរពិនិត្យ
## ជំហ៊ានដំបូងអន្តរជាតិ

(១) នីតិវិធីនៅចំពោះមុខអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវតែគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ បទបញ្ជានិងកិច្ចព្រមព្រៀងដែលការិយាល័យអន្តរជាតិបានចុះហត្ថលេខាជាមួយអាជ្ញាធរនោះ។

(២)(ក) អ្នកដាក់ពាក្យសុំមានសិទ្ធិទាក់ទងផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ជាមួយអាជ្ញាធរជំហ៊ានដំបូងអន្តរជាតិ។

(ខ) មុនរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិត្រូវបានធ្វើរួចហើយ អ្នកដាក់ពាក្យសុំមានសិទ្ធិកែតម្រូវសេចក្តីអះអាង សេចក្តីអធិប្បាយ និងគំនូសបង្ហាញបាន នៅក្នុងលក្ខខណ្ឌតម្រូវនឹងមានពេលវេលាកំណត់។ ការកែសម្រួលមិនត្រូវប្រាសចាកពីការបង្ហាញឲ្យដឹងនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នោះឡើយ។

(គ) អ្នកដាក់ពាក្យសុំត្រូវទទួលយ៉ាងហោចណាស់ យោបល់ជាលាយលក្ខណ៍អក្សរមួយពីអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ លុះត្រាអាជ្ញាធរនោះពិចារណាថា គ្រប់លក្ខខ័ណ្ឌត្រូវបានបំពេញ៖

(i) តក្កកម្មបានបំពេញត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ៣៣

(ii) សំណុំលិខិតស្នើសុំបំពេញតាមលក្ខខ័ណ្ឌតាមសន្ធិសញ្ញានេះ និងបទបញ្ជាក្រោមការបញ្ជារបស់អាជ្ញាធរនោះ។

(iii) គ្មានករប្រព្រឹត្តណាមានបំណង ដូចមានចែងក្នុងមាត្រា៣៥ (២)ឃ្លាចុងក្រោយ។

(៣) (ក) ប្រសិនបើអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិពិចារណាឃើញថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបំពេញតាមលក្ខខ័ណ្ឌតម្រូវ នៃការរួមបញ្ចូលគ្នានៃតក្កកម្ម ដូចមានចែងក្នុងបទបញ្ជា អាជ្ញាធរនេះអាច

ស្នើឲ្យអ្នកដាក់ពាក្យសុំ ធ្វើកម្រិតសេចក្តីអះអាងដើម្បីបំពេញតាមលក្ខខ័ណ្ឌ ឬ បង់កម្រៃបន្ថែមអាស្រ័យតាមជម្រើសរបស់គាត់។

(ខ) ក្នុងករណីអ្នកដាក់ពាក្យស្នើសុំជ្រើសរើសយកការកម្រិតសេចក្តីអះអាង ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក) ច្បាប់ជាតិនៃរដ្ឋជ្រើសតាំងណាមួយអាចចែងថា ជាផលវិបាកនៃការកម្រិតនោះផ្នែកទាំងនោះនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដែលមិនឆ្លងកាត់ការពិនិត្យជំហ៊ានដំបូងអន្តរជាតិហើយពាក់ព័ន្ធទៅនឹងអានុភាពក្នុងរដ្ឋនោះ ត្រូវចាត់ទុកថាបានដកហូតយកទៅវិញ លុះត្រាតែអ្នកដាក់ពាក្យសុំបានបង់កម្រៃជូនពិសេសទៅការិយាល័យជាតិនៃរដ្ឋនោះ។

(គ) ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបំពេញតាមការស្នើ ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក) តាមពេលវេលាកម្រិតតាមការកំណត់ អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវធ្វើរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិស្តីពីផ្នែកទាំងនោះ របស់សំណុំលិខិតស្នើសុំអន្តរជាតិដែលពាក់ព័ន្ធទៅនឹងអ្វី ដែលលេចចេញជាមូលដ្ឋានសំខាន់នៃតក្កកម្ម ហើយត្រូវបញ្ជាក់អំពីកត្តាពាក់ព័ន្ធនៅក្នុងរបាយការណ៍នោះ។ ច្បាប់ជាតិនៃរដ្ឋជ្រើសតាំងណាមួយអាចចែងថា ក្នុងការិយាល័យជាតិ របស់ខ្លួនពិនិត្យឃើញថា ការស្នើរបស់អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ ដែលមិនពាក់ព័ន្ធទៅនឹងតក្កកម្មសំខាន់ ចំណែកឯអានុភាពដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះវិញ ត្រូវតែចាត់ទុកថាបានដកហូតយកទៅវិញ លុះត្រាតែអ្នកដាក់ពាក្យសុំបានបង់កម្រៃពិសេសជូនការិយាល័យនោះ។

(៤)(ក) ប្រសិនបើអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិចាត់ទុកៈ

(i) ថាសំណុំលិខិតអន្តរជាតិពាក់ព័ន្ធនឹងកម្មវត្ថុ ដែលអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ មិនតម្រូវឲ្យអនុវត្ត ឲ្យអនុវត្តការពិនិត្យជំហ៊ានដំបូងអន្តរជាតិ ក្នុងបទបញ្ជាដូចមានចែង ហើយក្នុងករណីពិសេសសម្រេចមុនអនុវត្តការពិនិត្យនោះ ឬ

(ii) ជាសេចក្តីអធិប្បាយ សេចក្តីអះអាង ឬគំនូសបង្ហាញមិនច្បាស់លាស់ ឬសេចក្តីអះអាងត្រូវបានគាំទ្រមិនគ្រប់គ្រាន់ដោយសេចក្តីអធិប្បាយដែលថា គ្មានគំនិតដែលមានអត្ថន័យអាចត្រូវបាន បង្កើតស្តីពីភាពថ្មីជំហ៊ាននៃការរកឃើញថ្មី (to be non-obvious) ឬអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្មរបស់តក្កកម្មដែលបានអះអាងនោះ។ អាជ្ញាធរត្រូវជូនដំណឹងដល់សំណួរ យោងតាមការចែងក្នុងមាត្រា៣៣ (១) ហើយត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ អំពីគំនិតនឹងមូលហេតុរបស់វា។

(ខ) ប្រសិនបើសភាពការណ៍ណាមួយ នៃសភាពការណ៍ទាំងនេះ ដូចមានចែងនៅក្នុងអនុវាក្យខ័ណ្ឌ (ក) ត្រូវបានរកឃើញថា កើតមាននៅក្នុង ឬ ពាក់ព័ន្ធជាមួយសេចក្តីអំអាងជាក់លាក់តែប៉ុណ្ណោះ បទប្បញ្ញត្តិនៃអនុវាក្យខ័ណ្ឌនោះ ត្រូវអនុវត្តចំពោះតែសេចក្តីអះអាងនោះ។

## មាត្រា៣៥
## របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ

(១) របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវតែធ្វើនៅក្នុងពេលវេលាកម្រិត តាមការកំណត់ និងទម្រង់តាមការកំណត់។

(២) របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ មិនត្រូវមានការថ្លែងណាមួយ អំពីសំណួរថា តើតក្កកម្ម ដែលអះអាងនោះ អាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន ឬមិនអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន ដោយយោងតាមច្បាប់ជាតិណាមួយទេ។ លើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ (៣) របាយការណ៍នោះត្រូវថ្លៃបញ្ជាក់ពាក់ព័ន្ធការអះអាងនីមួយៗ ថាតើសេចក្តីអះអាងលេចចេញដើម្បីបំពេញលក្ខណៈវិនិច្ឆ័យរបស់ភាពថ្មី (to be non-obvious) និងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ដូចមានចែងសម្រាប់គោលបំណងនៃការពិនិត្យជំហ៊ានដំបូងអន្តរជាតិនៅក្នុងមាត្រា៣៣ (១) និង (៤)។ សេចក្តីថ្លែងត្រូវភ្ជាប់មកជាមួយនូវការដកដស្រង់ឯកសារដែលជឿជាក់ថា សម្រាប់គាំទ្រសេចក្តីបញ្ចប់ដែលបានថ្លែងរួមជាមួយការបន្យល់នោះ ទៅតាមកាលៈទេសៈករណី ដែលត្រូវការសេចក្តីថ្លែងត្រូវតែភ្ជាប់មកជាមួយផង ដែលនូវការប្រតិបត្តផ្សេងទៀតដូចមានចែងនៅក្នុងបទបញ្ញា។

(៣) (ក) នៅពេលរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ ប្រសិនបើអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិចាត់ទុកថាសភាពការណ៍នោះ ត្រូវថ្លែងបញ្ជាក់ណាមួយដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ (២)ទេ។

(ខ) ប្រសិនបើសភាពការណ៍ដូចមានចែងនៅក្នុងមាត្រា៣៤ (៤) (ខ) ត្រូវបានឃើញថាកើតមានក្នុងករណីពាក់ព័ន្ធសេចក្តីអះអាង ដែឡស្ថិតក្នុងការពិនិត្យរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវមានសេចក្តីថ្លែងដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក) ហើយក្នុងករណីពាក់ព័ន្ធសេចក្តីអះអាងផ្សេងទៀតរបាយការណ៍ត្រូវមានសេចក្តីថ្លែង ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌទី (២)។

## មាត្រា៣៦

## ការបញ្ជូនការបកស្រាយ និងទំនាក់ទំនង របស់របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ

(១) របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ រួមជាមួយនិងឧបសម្ព័ន្ធតាមការកំណត់ ត្រូវបញ្ជូនឲ្យអ្នកដាក់ពាក្យសុំ និងការិយាល័យជាតិ។

(២) (ក) របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ និងឧបសម្ព័ន្ធរបស់វា ត្រូវតែបកប្រែជាភាសាតាមការកំណត់។

(ខ) ការបកស្រាយណាមួយនៃរបាយការណ៍នេះ ត្រូវតែរៀបចំដោយ ឬក្រោមការទទួលខុសត្រូវរបស់ការិយាល័យអន្តរជាតិ។ ចំណែកឯការបកប្រែ នៃឧបសម្ព័ន្ធខាងលើនេះ ត្រូវតែរៀបចំដោយអ្នកដាក់ពាក្យសុំ។

(៣) (ក) របាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិរួមជាមួយ និងការបកប្រែរបស់វា (ដូចមានចែង) និង ឧបសម្ព័ន្ធរបស់វា (ជាភាសាដើម) ត្រូវតែផ្តល់ឲ្យការិយាល័យជ្រើសតាំងនីមួយៗដោយការិយាល័យអន្តរជាតិ។

(៤) បទប្បញ្ញត្តិ នៃមាត្រា២០ (៣) ត្រូវយកមកអនុវត្តដូចគ្នាចំពោះឯកសារចម្លងណាមួយនិងដែលត្រូវបានដកស្រង់នៅក្នុងរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ និង ដែលមិនត្រូវបានដកស្រង់នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ។

## មាត្រា៣៧

## ការដកហូតនូវការទាមទារ ឬការជ្រើសតាង

(១) អ្នកដាក់ពាក្យសុំអាចដកហូត ការជ្រើសតាងណាមួយ ឬ ជ្រើសតាងទាំងអស់។

(២) ប្រសិនបើការជ្រើសតាងរដ្ឋជ្រើសតាងទាំងអស់ត្រូវបានដកហូត ការទាមទារត្រូវតែចាត់ទុកថា បានដកហូតយកទៅវិញ។

(៣) (ក) ការដកហូតណាមួយត្រូវតែជូនដំណឹងទៅការិយាល័យអន្តរជាតិ។

(ខ) ការិយាល័យជ្រើសតាងពាក់ព័ន្ធ និង អាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិពាក់ព័ន្ធ ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ។

(៤) (ក) លើកលែងបទប្បញ្ញត្តិ នៃអនុវាក្យខ័ណ្ឌ (ខ) ប្រសិនបើច្បាប់ជាតិនៃរដ្ឋនោះ ពុំមានចែងនោះទេ ការដកហូតទៅវិញនូវការទាមទារ ឬការជ្រើសតាំងរដ្ឋហត្ថលេខី ត្រូវចាត់ទុកថាមានការពាក់ព័ន្ធទៅនឹងរដ្ឋនោះ។

(ខ) ការដកហូតយកទៅវិញនូវការទាមទារ ឬ ការជ្រើសតាងមិនត្រូវបានចាត់ទុកថា បានដកហូតយកទៅវិញ នូវសំណុំលិខិតស្នើសុំអន្តរជាតិទេ ប្រសិនបើការដកហូតនោះមានអានុភាព មានការផុតកំណត់នៃពេលវេលាមានកម្រិត ដែលត្រូវអនុវត្តដូចមានចែងក្នុងមាត្រា២២។ ដូច្នេះរដ្ឋហត្ថលេខីណាមួយ អាចចែងនៅក្នុងច្បាប់ជាតិរបស់គេថា ការរៀបរាប់ខាងលើត្រូវអនុវត្តចំពោះតែក្នុងករណីការិយាល័យជាតិរបស់ខ្លួន បានទទួលច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិរួមជាមួយនិងការបកប្រែ (ដូចមានចែង) និងកម្រៃជាតិនៅក្នុងពេលវេលាកម្រិត។

## មាត្រា៣៨
## លក្ខណៈសម្ងាត់នៃការពិនិត្យជំហ៊ានអន្តរជាតិ

(១) មិនមែនការិយាល័យអន្តរជាតិ ហើយមិនមែនអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិដែរត្រូវអនុញ្ញាតឲ្យពិនិត្យមើលនៅក្នុងន័យ និង បទប្បញ្ញត្តិ នៃមាត្រា៣០ (៤) ចំពោះការដាក់ពិនិត្យជំហ៊ានដំបូងអន្តរជាតិ ដោយបុគ្គលណា ឬ អាជ្ញាធរណាមួយនៅគ្រប់ពេលវេលា លើកលែងតែការិយាល័យជ្រើសតាង នៅពេលដែលរបាយការណ៍ពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវបានធ្វើឡើង លុះត្រាតែមានសំណើ ឬ ការអនុញ្ញាតពីអ្នកដាក់ពាក្យសុំ។

(២) លើកលែងបទប្បញ្ញត្តិ នៃវាក្យខ័ណ្ឌ (១) និងមាត្រា៣៦ (១) និង (៣) និងមាត្រា៣៧ (៣)មិនមែនការិយាល័យអន្តរជាតិ ហើយក៏មិនមែនអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិ ត្រូវផ្តល់ឲ្យព័ត៌មានអំពីការចេញ ឬ ការមិនចេញនៃរបាយការណ៍ពិនិត្យជំហ៊ាមដំបូងអន្តរជាតិ និង អំពីការដកយកទៅវិញ ឬមិនដកហូតយកទៅវិញនូវការទាមទារ ឬការជ្រើសតាងណាមួយ។

## មាត្រា៣៩
## ការចម្លង ការបកប្រែ និង កម្រៃចំពោះការិយាល័យជ្រើសរើស

(១) (ក) ប្រសិនបើការជ្រើសតាងរដ្ឋហត្ថលេខីណាមួយ ត្រូវបានចូលជាធរមានមុនការផុតកំណត់នៃរយៈពេល ១៩ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាពបទប្បញ្ញត្តិនៃមាត្រា២២ មិនត្រូវអនុវត្តចំពោះរដ្ឋនោះ ហើយអ្នកដាក់ពាក្យសុំត្រូវផ្តល់នូវច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ (លុះត្រាតែមានការជូនដំណឹង ដូចមានចែងក្នុងមាត្រា២០ត្រូវបានទទួលយក) និង ការបកប្រែសំណុំលិខិត (ដូចមានចែង) និងបង់កម្រៃជាតិ

(ប្រសិនបើមាន) ជូនការិយាល័យជ្រើសតាងនីមួយៗ មិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព។

(២) សម្រាប់ការអនុវត្តសកម្មភាពដូចមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក) ច្បាប់ជាតិណាមួយអាចកំណត់ពេលវេលាកម្រិត ដូចមានចែងក្នុងអនុវាក្យខ័ណ្ឌនោះ។

(៣) អានុភាពដូចមានចែងក្នុងមាត្រា១១ (៣) ត្រូវបញ្ចប់នៅក្នុងរដ្ឋជ្រើសតាងជាមួយផលវិបាកដូចគ្នាដូចការដកហូតយកទៅវិញនូវសំណុំលិខិតស្នើសុំអន្តរជាតិណាមួយនៅក្នុងរដ្ឋនោះ ប្រសិនបើអ្នកដាក់ពាក្យសុំនោះខកខានមិនបានអនុវត្តសកម្មភាព ដូចមានចែងក្នុងវាក្យខ័ណ្ឌ(១) (ក) ឬ (ខ)។

(៤) ការិយាល័យជ្រើសតាងណាមួយអាចរក្សាអានុភាព ដូចមានចែងក្នុងមាត្រា១១ (៣) ថ្វីបើក្នុងករណីអ្នកដាក់ពាក្យសុំមិនបានបំពេញតាមលក្ខខ័ណ្ឌតម្រូវ ដូចមានចែងក្នុងវាក្យខ័ណ្ឌ (១) (ក) ក៏ដោយ។

## មាត្រា៤០

## ការពន្យានៃការពិនិត្យជាតិ និងដំណើរការផ្សេងទៀត

(១) ប្រសិនបើការជ្រើសតាងរដ្ឋហត្ថលេខីណាមួយ ត្រូវបានចូលជាធរមាន មុនការផុតកំណត់នៃរយៈពេល ១៩ខែ គិតចាប់ពីកាលបរិច្ឆេទអាទិភាព បទប្បញ្ញត្តិនៃមាត្រា២៣ មិនត្រូវអនុវត្តចំពោះរដ្ឋនោះ និងការិយាល័យជាតិរដ្ឋនោះ ឬការិយាល័យដែលដើរតួនាទីជំនួសឲ្យរដ្ឋនោះ ដែលមិនដំណើរការលើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ (២) ចំពោះការពិនិត្យ និងដំណើរការផ្សេងទៀតរបស់សំណុំលិខិតស្នើសុំអន្តរជាតិមុនការផុតកំណត់ នៃពេលវេលាកម្រិតដែលអាចអនុវត្តបាន ដូចមាននៅចែងក្នុងមាត្រា៣៩។

(២) ថ្វីបើមានបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ (១) ការិយាល័យជ្រើសតាងណាមួយ អាចដំណើរការពិនិត្យ និងដំណើរការផ្សេងទៀតចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ នៅគ្រប់ពេលវេលាតាមសំណើបញ្ជាក់របស់អ្នកដាក់ពាក្យសុំ។

## មាត្រា៤១

## ការកែសម្រួលសេចក្តីអះអាង សេចក្តីអធិប្បាយ និងគំនូសបង្ហាញនៅចំពោះមុខការិយាល័យជ្រើសតាង

(១) អ្នកដាក់ពាក្យសុំត្រូវបានផ្តល់ឱកាស កែសម្រួលសេចក្តីអះអាង សេចក្តីអធិប្បាយ និងគំនូសបង្ហាញនៅចំពោះមុខការិយាល័យជ្រើសតាងនីមួយៗ នៅក្នុងពេលវេលាកម្រិតតាមការកំណត់។ គ្មានការិយាល័យជ្រើសតាងណាត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬ បដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម មុនការកំណត់នៃពេលវេលាកម្រិតឡើយ លើកលែងតែមានការយល់ព្រមដែលបញ្ជាក់ពីការដាក់ពាក្យសុំ។

(២) ការកែសម្រួលមិនត្រូវធ្វើឲ្យហួស ពីការបញ្ចេញឲ្យដឹងនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នោះឡើយ លុះត្រាតែច្បាប់ជាតិនៃរដ្ឋជ្រើសតាងអនុញ្ញាតឲ្យធ្វើការកែប្រែធ្វើឲ្យហួសពីការបញ្ចេញឲ្យដឹងនោះ។

(៣) ការកែប្រែត្រូវតែសមស្របជាមួយច្បាប់ជាតិរបស់រដ្ឋជ្រើសតាង ក្នុងគ្រប់ការពាក់ព័ន្ធដែលមិនមានចែងក្នុងសន្ធិសញ្ញានេះ និងបទបញ្ជា។

(៤) ក្នុងករណីការិយាល័យជ្រើសតាង តម្រូវឲ្យមានការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិការកែប្រែត្រូវតែធ្វើជាភាសា នៃការបកប្រែនោះ (in the language of the translation)។

## មាត្រា៤២
## លទ្ធផលនៃការពិនិត្យកម្រិតជាតិ
## នៅក្នុងការិយាល័យជ្រើសតាំង

គ្មានការិយាល័យជ្រើសតាងណា ដែលទទួលរបាយការពិនិត្យជំហ៊ានដំបូងអន្តរជាតិ អាចតម្រូវថា អ្នកដាក់ពាក្យសុំត្រូវផ្តល់ច្បាប់ចម្លង ឬ ព័ត៌មានស្តីពីមាតិកានៃឯកសារមួយពាក់ព័ន្ធទៅនឹងការពិនិត្យ ពាក់ព័ន្ធទៅនឹងសំណុំលិខិតដូចគ្នា នៅក្នុងការិយាល័យជ្រើសតាំងណាមួយផ្សេងទៀតឡើយ។

## ជំពូកទី៣
## បទប្បញ្ញត្តិរួម
## មាត្រា៤៣
## ការស្វែងរកប្រភេទជាក់លាក់នៃការការពារ

ពាក់ព័ន្ធទៅនឹងប្រព័ន្ធជ្រើសរើស ឬរដ្ឋជ្រើសតាំងដែលច្បាប់ជាតិរបស់គេ មានចែងសម្រាប់ការផ្តល់វិញ្ញាបនបត្រតក្កកម្ម វិញ្ញាបនបត្រមានអត្ថប្រយោជន៍ ម៉ូដែលមានអត្ថប្រយោជន៍ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រនៃការបន្ថែម វិញ្ញាបនបត្រតក្កកម្មបន្ថែម ឬវិញ្ញាបនបត្រមានអត្ថប្រយោជន៍នៃការបន្ថែម ហើយអានុភាពដែលកើតមានឡើងគឺត្រូវតែចាត់ចែងដោយជម្រើសរបស់អ្នកដាក់ពាក្យសុំ។ សម្រាប់គោលបំណងនៃមាត្រានេះ និងប្រការណាមួយដែលពាក់ព័ន្ធមាត្រា ២ (ii) មិនត្រូវយកមកអនុវត្តទេ។

## មាត្រា៤៤
## ការស្វែងរកការការពារពីរប្រភេទ

ពាក់ព័ន្ធទៅនឹងរដ្ឋជ្រើសរើស ឬរដ្ឋជ្រើសតាំងណាមួយដែលច្បាប់របស់រដ្ឋ អនុញ្ញាតឲ្យសំណុំលិខិតស្នើសុំ អាចផ្តល់ការការពារប្រទេសទៀតផ្សេងទៀតផងដែរ ក្នុងចំណោមការការពារជាច្រើនប្រភេទដូចដែលបានរៀបរាប់នៅពេលមុនផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬ ការការពារមួយប្រភេទក្នុងចំណោម ការការពារជាច្រើនប្រភេទផ្សេងទៀត ដូចមានចែងក្នុងមាត្រា៤៣។ អ្នកដាក់ពាក្យសុំអាចបញ្ជាក់ ដូចមានចែងក្នុងបទបញ្ជា នូវការការពារពីរប្រភេទដែលគាត់ស្វែងរក ហើយអានុភាពដែលកើតឡើង ត្រូវតែចាត់ចែង ដោយការបញ្ជាក់របស់អ្នកដាក់ពាក្យសុំ។ សម្រាប់គោលបំណងនៃមាត្រា២ (ii) មិនត្រូវយកមកអនុវត្តទេ។

## មាត្រា៤៥
## សន្ធិសញ្ញាប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់

(១) សន្ធិសញ្ញាណាមួយដែលចែងសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្មថ្នាក់តំបន់ (សន្ធិប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់) និងផ្តល់ចំពោះបុគ្គលគ្រប់រូបដែលជាអ្នកមានសិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ សិទ្ធិដាក់សំណុំលិខិតស្នើសុំការផ្តល់ប្រកាសនីយបត្រតក្កកម្មនោះយោងតាមមាត្រា៩ អាចចែងថា

សំណុំលិខិតស្នើសុំអន្តរជាតិដែលជ្រើសរើស ឬជ្រើសតាំងរដ្ឋដែលជាសមាជិកនៃសន្ធិសញ្ញាទាំងពីរ គឺសន្ធិសញ្ញាប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់ និងសន្ធិសញ្ញានេះអាចដាក់សំណុំលិខិតស្នើសុំប្រកាសនីបត្រតក្កកម្មនេះបាន។

(២) ច្បាប់ជាតិរបស់រដ្ឋជ្រើសរើស ឬរដ្ឋជ្រើសតាំងដែឡបានរៀបរាប់ខាងលើ អាចចែងថា ការជ្រើសរដ្ឋណាមួយនៃរដ្ឋទាំងនោះ នៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវតែបញ្ជាក់បំណងប្រាថ្នាដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់ នៅក្រោមសន្ធិសញ្ញាប្រកាសនីយបត្រតក្កកម្មកម្រិតតំបន់។

## មាត្រា៤៦

## ការបកប្រែនៃ សំណុំលិខិតស្នើសុំអន្តរជាតិមិនត្រឹមត្រូវ

ប្រសិនបើវិសាលភាពនៃប្រកាសនីយបត្រតក្កកម្មដែឡបានផ្តល់រួចហើយណាមួយ ដែលផ្អែកលើមូលដ្ឋាននៃសំណុំលិខិតស្នើសុំនោះ លើសវិសាលភាពនៃសំណុំលិខិតស្នើសុំអន្តរជាតិនោះ ដែលមាននៅក្នុងភាសាដើមនោះ ដោយសារតែការបកប្រែនៃសំណុំលិខិតស្នើសុំអន្តរជាតិនោះមិនត្រឹមត្រូវអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋហត្ថលេខីពាក់ព័ន្ធ អាចកម្រិតប្រតិសកម្មនៃវិសាលភាពនៃប្រកាសនីយបត្រតក្កកម្ម អាចនឹងប្រកាសចាត់ទុកថាមិនបានការ និងទុកជាមោឃៈនូវវិសាលភាពរបស់សំណុំលិខិត ដោយឈរលើវិសាលភាពដែលមានក្នុងភាសាដើមនៃសំណុំលិខិតស្នើសុំអន្តរជាតិនោះ។

## មាត្រា៤៧

## ពេលវេលាកម្រិត

(១) សេចក្តីកម្រិតសម្រាប់ការគណនាពេលវេលាកម្រិត ដូចមានចែងនៅក្នុងសន្ធិសញ្ញាត្រូវកំណត់ដោយបទបញ្ជា។

(២) (ក) គ្រប់ពេលវេលាកម្រិតទាំងអស់ ដែលចែងនៅក្នុងជំពូកទី១ និងជំពូកទី២ នៃសន្ធិសញ្ញានេះ អាចត្រូវបានផ្លាស់ប្តូរ អាស្រ័យដោយសេចក្តីសម្រេចរបស់រដ្ឋហត្ថលេខីដែលស្ថិតនៅក្រៅការបន្ថែមបន្ថយ ដូចមានចែងនៅក្នុងមាត្រា៦០។

(ខ) សេចក្តីសម្រេចនោះត្រូវធ្វើដោយសន្និបាត ឬតាមរយៈការបោះឆ្នោតឆ្លើយឆ្លង (vothing by correspondence) និងត្រូវតែឯកច្ឆ័ន្ទ (unanimous)

(គ) សេចក្តីលំអិតនៃនីតិវិធីត្រូវកំណត់ដោយបទបញ្ជា។

## មាត្រា៤៨

## ការពន្យារពេលវេលាកម្រិតជាក់លាក់

## នៅក្នុងការបំពេញឲ្យបានត្រឹមត្រូវ

(១) ក្នុងករណីពេលវេលាកម្រិតណាមួយដែលកំណត់នៅក្នុងសន្ធិសញ្ញានេះ ឬនៅក្នុងបទបញ្ជាមិនត្រូវបានបំពេញត្រឹមត្រូវ ពីព្រោះតែការផ្អាកនៅក្នុងសេវាកម្មប្រៃសណីយ៍ ឬការបាត់បង់ដែលមិនអាចជៀសវាងបាន ឬការពន្យានៅក្នុងការផ្ញើតាមប្រៃសណីយ៍ ពេលវេលាកម្រិតត្រូវតែចាត់ទុកថា បានបំពេញត្រឹមត្រូវនៅក្នុងលក្ខខ័ណ្ឌទាំងនោះ ហើយត្រូវតែបង្ហាញភស្តុតាង និងលក្ខណៈផ្សេងទៀត ដូចមានចែងក្នុងបទបញ្ជា។

(២) (ក) ចំពោះតែផ្នែកដែលពាក់ព័ន្ធនឹងរដ្ឋហត្ថលេខីណាមួយ ត្រូវអនុគ្រោះដល់ការយឺតយ៉ាវណាមួយនៅក្នុងការបំពេញតាមពេលវេលាកម្រិតណាមួយ ដោយសារហេតុផលក្រៅពីហេតុផលដែលមានចែងនៅក្នុងអនុវាក្យខ័ណ្ឌ (ក)។

## មាត្រា៤៩

## សិទ្ធិអនុវត្តចំពោះមុខអាជ្ញាធរអន្តរជាតិ

មេធាវីណាមួយ ភ្នាក់ងារប្រកាសនីយបត្រតក្កកម្មណាមួយ ឬបុគ្គលផ្សេងទៀតដែលមានសិទ្ធិអនុវត្តនៅចំពោះមុខការិយាល័យជាតិដែលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានដាក់ ត្រូវតែមានសិទ្ធិអនុវត្តចំពោះមុខការិយាល័យអន្តរជាតិ និងអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហ៊ានដំបូងអន្តរជាតិមានសមត្ថភាពពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំនោះ។

# ជំពូកទី៤

# សេវាកម្មបច្ចេកទេស

## មាត្រា៥០

## សេវាកម្មព័ត៌មានប្រកាសនីយបត្រតក្កកម្ម

ការិយាល័អន្តរជាតិអាចផ្តល់ណុវសេវាកម្ម អាចផ្តល់នូវបច្ចេកទេស និងព័ត៌មានពាក់ព័ន្ធណាមួយផ្សេងទៀត ដែលអាចមានដោយឈរលើមូលដ្ឋាននៃឯកសារបោះពុម្ពផ្សាយ ឯកសារដំបូងនៃប្រកាសនីយបត្រតក្កម្ម និងសំណុំលិខិតស្នើសុំដែលបានបោះពុម្ពផ្សាយ (យោងតាមការចែងនៅក្នុងមាត្រានេះជាសេវាកម្មព័ត៌មាន information service)។

(២) ការិយាល័យអន្តរជាតិអាចផ្តល់សេវាកម្មព័ត៌មានទាំងអស់នេះដោយផ្ទាល់ តាមរយៈអាជ្ញាធរអន្តរជាតិមួយ ឬច្រើន វិទ្យាស្ថានឯកទេសជាតិ ឬអន្តរជាតិផ្សេងទៀតដែលការិយាល័យអន្តរជាតិអាចចុះកិច្ចសន្យាជាមួយ។

(៣) សេវាកមម្មព័ត៌មានត្រូវតែប្រតិបត្តការនៅក្នុងមធ្យោបាយ ដែលជួយសម្រួលពិសេសនូវការទទួលបានចំណេះដឹងនឹងបច្ចេកទេស និងបច្ចេកវិទ្យា រួមទាំងបញ្ចូលទាំងព័ត៌មានដែលបានបោះពុម្ពផ្សាយអំពីជំនាញរបស់រដ្ឋហត្ថលេខី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍។

(៤) សេវាកម្មព័ត៌មានត្រូវតែផ្តល់ឲ្យរដ្ឋាភិបាលនៃរដ្ឋហត្ថលេខី និងជនជាតិរបស់គេ នឹងអ្នកមានទីលំនៅទីនោះ។ សន្និបាតអាចសម្រេចធ្វើសេវាកម្មទាំងនេះ ឲ្យដល់ជនផ្សេងទៀតផងដែរ។

(៥) (ក) សេវាកម្មណាមួយចំពោះរដ្ឋាភិបាលនៃរដ្ឋហត្ថលេខី ត្រូវតែផ្តល់ឲ្យដោយឥតគិតថ្លៃបានន័យថា កាលណារដ្ឋាភិបាលនៃរដ្ឋហត្ថលេខី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ សេវាកម្មត្រូវតែផ្តល់ឲ្យដូច្នេះ ដោយបញ្ចុះតម្លៃប្រសិនបើកាតខុសប្លែកគ្នាអាចត្រូវបានគ្របដណ្តប់ពីផលចំណេញ ដែលបានមកពីការធ្វើសេវាកម្មដែលបានផ្តល់ជូនជនផ្សេងទៀត ក្រៅរដ្ឋាភិបាលនៃរដ្ឋហត្ថលេខី ឬពីប្រភពនានា ដូចមានចែងនៅក្នុងមាត្រា៥១ (៤)។

(ខ) តម្លៃដូចមានចែអនៅក្នុងអនុវាក្យខ័ណ្ឌ (ក) គឺត្រូវបានយល់ថាជាតម្លៃលើសពីលើតម្លៃបន្ទាប់បន្សំធម្មតា (as cost over and above costs normally incident) ចំពោះការធ្វើសេវាកម្មរបស់ការិយាល័យជាតិ ឬការតព្វកិច្ចរបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ។

(៦) សេចក្ដីលំអិតពាក់ព័ន្ធទៅនឹងការអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះ ត្រូវតែកំណត់ដោយសេចក្ដីសម្រេចរបស់សន្និបាតដើម្បីគោលបំណងនេះ សន្និបាតអាចបង្កើតក្រុមការងារនៅក្នុងកម្រិតដែលនឹងត្រូវកំណត់ដោយសន្និបាត។

(៧) នៅពេលណាត្រូវបានចាត់ទុកថា ជាការចាំបាច់ សន្ទបាតត្រូវណែនាំអំពីវិធីសាស្ត្រនៃការផ្តល់ហិរញ្ញវត្ថុបន្ថែមចំពោះករណីដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ (៥)។

## មាត្រា៥១

## ជំនួសបច្ចេកទេស

(១) សន្និបាតត្រូវបង្កើតគណៈកម្មការជំនួសបច្ចេកទេស (ដូចមានចែងក្នុងមាត្រានេះជាគណៈកម្មការ) ។

(២) ក. សមាជិកនៃគណៈកម្មការត្រូវតែជ្រើសតាំងក្នុងចំណោមរដ្ឋហត្ថលេខី ដោយគិតដល់តំណាងប្រទេសកំពុងអភិវឌ្ឍន៍។

ខ. អគ្គនាយកត្រូវអញ្ជើញតំណាងអង្គការអន្តររដ្ឋាភិបាល ដែលពាក់ព័ន្ធទៅនឹងជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ អោយចូលរួមនៅក្នុងការងាររបស់គណៈកម្មការ ដោយឈរលើការផ្តួចផ្តើមគំនិតរបស់គាត់ ឬតាមសំណើររបស់គណៈកម្មការ។

(៣) ក. ភារកិច្ចរបស់គណៈកម្មការត្រូវតែរៀបចំ និងគ្រប់គ្រងជំនួយបច្ចេកទេសសម្រាប់រដ្ឋហត្ថលេខីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការអភិវឌ្ឍន៍ប្រព័ន្ធប្រកាសនីយបត្រតក្កកម្មរបស់គេផ្ទាល់តែម្តង ឬដោយឈរលើមូលដ្ឋានកម្រិតតំបន់។

ខ. នៅក្នុងចំណោមកិច្ចការផ្សេងទៀតជំនួយបច្ចេកទេស ត្រូវមានការបណ្តុះបណ្តាលអ្នកឯកទេស ការផ្តល់អ្នកជំនាញការ និងផ្គត់ផ្គង់សំភារៈសម្រាប់គោលបំណងពីរយ៉ាងគឺ បង្ហាត់បង្ហាញ និងអនុវត្តន៍។

(៤) ការិយាល័យអន្តរជាតិត្រូវស្វែងរកការចុះកិច្ចព្រមព្រៀង នៅលើជ្រុងម្ខាងទៀតជាមួយអង្គការហិរញ្ញវត្ថុអន្តរជាតិ និងអង្គការអន្តររដ្ឋាភិបាល ជាពិសេសអង្គការសហប្រជាជាតិ ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសដែលភ្ជាប់ទំនាក់ទំនង ដោយអង្គការសហប្រជាជាតិដែលពាក់ព័ន្ធទៅនឹងជំនួយបច្ចេកទេស ហើយនៅលើជ្រុងម្ខាងទៀតជាមួយរដ្ឋាភិបាលនៃរដ្ឋដែលទទួលជំនួយបច្ចេកទេស សម្រាប់ផ្គត់ផ្គង់ហិរញ្ញវត្ថុរបស់គម្រោង ដោយយោងតាមមាត្រានេះ។

(៥) សេចក្តីលំអិតពាក់ព័ន្ធទៅនឹងការអនុវត្តន៍បទប្បញ្ញត្តិនៃមាត្រានេះត្រូវតែចែងដោយ សេចក្តីសម្រេចរបស់សន្និបាត ហើយដើម្បីគោលបំណងនេះ សន្និបាតអាចបង្កើតក្រុមការងារនៅក្នុងកម្រិតដែលនឹងកំណត់ដោយសន្និបាត។

## មាត្រា៥២

## ទំនាក់ទំនងជាមួយបទប្បញ្ញត្តិផ្សេងទៀតនៃសន្ធិសញ្ញា

គ្មានអ្វីនៅក្នុងជំពូកនេះ ត្រូវមានឥទ្ធិពលទៅលើបទប្បញ្ញត្តិហិរញ្ញវត្ថុដែលមាននៅក្នុងជំពូកផ្សេងទៀតនៃសន្ធិសញ្ញានេះឡើយ។

បទប្បញ្ញត្តិទាំងនេះមិនអាចយកទៅអនុវត្តបាន ចំពោះជំពូកនេះ ឬចំពោះការអនុវត្តរបស់វា។

# ជំពូក៥

# បទប្បញ្ញត្តិរដ្ឋបាល

## មាត្រា៥៣

## សន្និបាត

(១) ក. លើកលែងមាត្រា៥៧(៨) សន្និបាតត្រូវបានបង្កើតឡើងដោយរដ្ឋហត្ថលេខី។

ខ. រដ្ឋបាលនៃរដ្ឋហត្ថលេខីនីមួយៗ ត្រូវតែតំណាងដោយប្រតិភូម្នាក់ ដែលជាអ្នកត្រូវមានជំនួយការអមដោយប្រតិភូស្តីទីមួយចំនួន ទីប្រឹក្សាមួយចំនួន និងអ្នកជំនាញការមួចំនួន។

(២) ក. សន្និបាតត្រូវ៖

(i) ចាត់តាំងគ្រប់សកម្មភាពពាក់ព័ន្ធនឹងការរក្សា និងការអភិវឌ្ឍរបស់សហព័ន្ធ និងការអនុវត្តរបស់សន្ធិសញ្ញានេះ។

(ii) ធ្វើសកម្មភាំពទាំងនេះដូចបានកំណត់យ៉ាងច្បាស់ នៅក្រោមបទប្បញ្ញត្តិផ្សេងទៀតនៃសន្ធិសញ្ញានេះ។

(iii) ផ្តល់បទបញ្ជាចំពោះការិយាល័យអន្តរជាតិ ពាក់ព័ន្ធទៅនឹងការចំសន្និបាតដើម្បីពិនិត្យការងារឡើងវិញ។

(iv) ពិនិត្យសារឡើងវិញនិ និងផ្តល់របាយការណ៍ និងសកម្មភាពរបស់អគ្គនាយកពាក់ព័ន្ធទៅនឹងសហព័ន្ធ ហើយផ្តល់ឲ្យគាត់នៅបទបញ្ជាចាំបាច់ពាក់ព័ន្ធទៅនឹងសកម្មភាពដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់សហព័ន្ធ។

(v) ពិនិត្យសារឡើងវិញ និងផ្តល់របាយការណ៍ និងសកម្មភាពរបស់គណៈកម្មការប្រតិបត្តិដែលបង្កើតឡើងដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ(៩) ហើយផ្តល់បទបញ្ជាដល់គណៈកម្មការនេះ។

(vi) កំណត់កម្មវិធី និងអនុម័តថវិការប្រចាំបីឆ្នាំរបស់សហព័ន្ធ និងផ្តល់ការយល់ព្រមលើបញ្ជីគណនីចុងក្រោយរបស់គេ។

(vii) អនុម័តបទបញ្ជាហិរញ្ញវត្ថុរបស់សហព័ន្ធ។

(viii) បង្កើតគណៈកម្មការទាំងនេះ និងក្រុមការងារទាំងនោះ តាមដែលសន្និបាតគិតថា ជាការសមស្របដើម្បីឲ្យកម្មវត្ថុរបស់សហព័ន្ធសម្រេចបានជោគជ័យ។

(ix) លើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ(៨) កំណត់រដ្ឋដែលមិនមែនជារដ្ឋហត្ថលេខី អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវអនុញ្ញាតអោយចូលរួមក្នុងអង្គប្រជុំជាអ្នកសង្កេតការណ៍។

(x) អនុវត្តសកម្មភាពសមស្របណាមួយផ្សេងទៀត ដែលចាត់ទុកជាមុនសម្រាប់កម្មវត្ថុសហព័ន្ធ និងអនុវត្តមុខងារផ្សេងទៀតដែលសមស្របនៅក្រោមសន្ធិសញ្ញានេះ។

ខ. ចំពោះកិច្ចការដែលជាប្រយោជន៍ផងដែរ ចំពោះសហព័ន្ធផ្សេងទៀតដែលគ្រប់គ្រងដោយអង្គសន្និបាត ត្រូវធ្វើសេចក្ដីសម្រេចក្រោយពីបានស្ដាប់ការណែនាំរបស់គណៈកម្មការសម្របសម្រួលរបស់អង្គការ។

(៣) ប្រតិភូអាចតំណាង និងបោះឆ្នោតនៅក្នុងនាមនៃរដ្ឋមួយតែប៉ុណ្ណោះ។

(៤) រដ្ឋហត្ថលេខីនីមួយៗ ត្រូវមានមួយសម្លេង។

(៥) ក. ចំនួនមួយភាគពីរបូកមួយនៃចំនួនរដ្ឋហត្ថលេខី ត្រូវចាត់ទុកជាចំនួនចាំបាច់ត្រូវប្រើអង្គប្រជុំបាន (កូរ៉ុម)។

ខ. ក្នុងករណីខ្វះកូរ៉ុម សន្និបាតអាចធ្វើសេចក្ដីសម្រេចនានា លើកលែងតែសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងនីតិវិធីរបស់សន្និបាតផ្ទាល់ ប៉ុន្តែគ្រប់សេចក្ដីសម្រេចនោះត្រូវចូលជាធរមានបានលុះត្រាតែកូរ៉ុម និងសម្លេងភាគច្រើនដាច់ខាតត្រូវបានទទួលតាមរយៈការបោះឆ្នោតឆ្លងឆ្លើយ () ដូចមានចែងក្នុងបទបញ្ជា។

(៦) ក. លើកលែងបទប្បញ្ញត្តិនៃមាត្រា ៤៧(២)(ខ) ៥៨(២)(ខ) ៥៨(៣) និង៦១(២)(ខ) សេចក្ដីសម្រេចរបស់សន្និបាត ត្រូវឲ្យមានសម្លេងពីរភាគបីនៃម្លេងដែលបោះឆ្នោត។

(៧) ពាក់ព័ន្ធទៅនឹងកិច្ចការផលប្រយោជន៍ផ្ដាច់មុខចំពោះរដ្ឋដែលចងដោយជំពូក២សេចក្ដីយោងណាមួយ ចំពោះរដ្ឋហត្ថលេខីដូចមានចែងក្នុងវាក្យខ័ណ្ឌ (៤) (៥) និង(៦) ត្រូវតែចាត់ទុកថាជាការអនុវត្តចំពោះតែរដ្ឋដែលចងដោយជំពូកទី២។

(៨) អង្គការអន្តរជាតិរដ្ឋាភិបាលណាមួយដែលចាត់តាំងឲ្យធ្វើជាអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវតែអនុញ្ញាតអោយចូលជាអ្នកសង្កេតការនៅក្នុងសន្និបាត។

(៩) កាលណាចំនួនរដ្ឋហត្ថលេខី កើនលើសសែសិបសន្និបាតត្រូវបង្កើតគណៈកម្មការប្រតិបត្តិ។ សេចក្ដីយោងណាមួយចំពោះគណៈកម្មការប្រតិបត្តិនៅក្នុងសន្ធិសញ្ញានេះនិងបទបញ្ជា ត្រូវតែបកស្រាយដូចជាសេចក្ដីយោងចំពោះគណៈកម្មការ នៅពេលគណៈកម្មការនោះត្រូវបានបង្កើតឡើង។

(១០) រហូតដល់គណៈកម្មការប្រតិបត្តិត្រូវបានបង្កើត សន្និបាតត្រូវបានផ្ដល់ការយល់ព្រមនៅក្នុងកម្រិតនៃកម្មវិធី និងថវិការបីឆ្នាំ និងថវិការដែលរៀបចំដោយអគ្គនាយក។

(១១) ក. សន្និបាតត្រូវជួបប្រជុំ ជារៀងរាល់ប្រក្រតិទិនប្រចាំឆ្នាំលើកទីពីរ នៅក្នុងសម័យប្រជុំពេញអង្គតាមការកោះអញ្ជើញរបស់អគ្គនាយក ហើយក្នុងករណីអវត្តមាននៃកាលៈទេសៈលើកលេងត្រូវធ្វើក្នុងរយៈពេលដូចគ្នា និងនៅទីកន្លែងដូចគ្នា ដូចសន្និបាតធម្មតារបស់អង្គការ។

ខ. សន្និបាតត្រូវជួបជុំនៅសម័យប្រជុំវិសមញ្ញ តាមការកោះអញ្ជើញរបស់អគ្គនាយក តាមសំណើររបស់គណៈកម្មការប្រតិបត្តិ ឬតាមសំណើររបស់រដ្ឋហត្ថលេខី ចំនួនមួយភាគបួន។

(១២) សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងនៃនីតិវិធីរបស់ខ្លួន។

## មាត្រា៥៤

## គណៈកម្មការប្រតិបត្តិ

(១) កាលណាសន្និបាតបានបង្កើតគណៈកម្មការប្រតិបត្តិដែលគណៈកម្មការ ត្រូវតែស្ថិតនៅក្រោម បទប្បញ្ញត្តិដែលកំណត់ដូចខាងក្រោមនេះ៖

(២) ក. លើកលែងមាត្រា៥៧ (៨) គណៈកម្មការប្រតិបត្តិ ត្រូវកើតឡើងដោយរដ្ឋាភិបាលដែលជ្រើសតាំងដោយសន្និបាតចេញពីចំណោមរដ្ឋសមាជិកនៃសន្និបាត។

ខ. រដ្ឋាភិបាលនៃរដ្ឋសមាជិកនីមួយៗ នៃគណៈកម្មការប្រតិបត្តិត្រូវតែតំណាងដោយប្រតិភូម្នាក់ត្រូវមានជំនួយការអមដោយប្រតិភូស្តីទីមួយចំនួន ទីប្រឹក្សាមួយចំនួន និងអ្នកជំនាញការមួយចំនួន។

(៣) ចំនួនរដ្ឋដែលជាសមាជិកនៃគណៈកម្មការ ត្រូវឲ្យស្របគ្នាទៅនឹងចំនួនមួយភាគបួននៃចំនួនរដ្ឋដែលជាសមាជិកនៃសន្និបាត។ នៅក្នុងការបង្កើតចំនួនអសនៈដែលត្រូវបំពេញផ្នែកដែលនៅសល់ក្រោយពីការបែងចែក ជាបួនត្រូវតែចាត់ទុកថាមិនពាក់ព័ន្ធ។

(៤) ក្នុងការជ្រើសតាំងសមាជិកនៃគណៈកម្មការប្រតិបត្តិសន្និបាត ត្រូវគិតគូរទៅដល់ការបែងចែកដ៏មានសីមធម៌តាមលក្ខណៈភូមិសាស្ត្រ។

(៥) ក. សមាជិកនីមួយៗនៃគណៈកម្មការប្រតិបត្តិ ត្រូវបំរើការងារគិតចាប់ពីការបិទសម័យប្រជុំរបស់សន្និបាត ដែលជ្រើសតាំងខ្លួនរហូតដល់ការបិទសម័យប្រជុំពេញអង្គបន្ទាប់របស់សន្និបាត។

ខ. សមាជិកនៃគណៈកម្មការប្រតិបត្តិអាចត្រូវបានជ្រើសរើសម្តងទៀត ប៉ុន្តែអាស្រ័យទៅលើ សម្លេងអតិបរមានៃសម្លេងពីរភាគនៃចំនួនសមាជិកទាំងនោះ។

គ. សន្និបាតត្រូវបានបង្កើតសេចក្តីលំអិតនៃបទបញ្ញាដែលចែងអំពីការជ្រើសតាំង និងអំពីការជ្រើសតាំងម្តងទៀតសមាជិកនៃគណៈកម្មការប្រតិបត្តិ។

(៦) ក. គណៈកម្មការប្រតិបត្តិត្រូវ៖

(i) រៀបចំសេចក្តីព្រាងរបៀបវារៈរបស់សន្និបាត

(ii) ដាក់សំណើជូនសន្និបាតដែលពាក់ព័ន្ធទៅនឹងសេចក្តីព្រាងកម្មវិធី និងថវិការប្រចាំឆ្នាំបីឆ្នាំរបស់សហព័ន្ធដែលរៀបចំដោយអគ្គនាយក។

(iii) លុបចោល

(iv) ដាក់ជូនសន្និបាតនូវរបាយការណ៍ជាដំណាក់ៗរបស់អគ្គនាយក និងរបាយការណ៍សវនកម្មប្រចាំឆ្នាំអំពីបញ្ជីគណនេយ្យជាមួយសេចក្តីសង្កេតសមស្រប។

(v) ចាត់វិធានការចាំបាច់នានា ដើម្បីធានាការប្រតិបត្តិកម្មវិធីរបស់សហព័ន្ធដោយអគ្គនាយកដោយយោងតាមសេចក្តីសម្រេចរបស់សន្និបាត ហើយគិតទៅដល់កាលៈទេសៈដែលកើតឡើងរវាងសម័ប្រជុំពេញអង្គទាំងពីររបស់សន្និបាត។

(vi) អនុវត្តការងារផ្សេងៗទៀតដូចត្រូវបានគ្រោងទុកសម្រាប់ខ្លួននៅក្រោមសន្ធិសញ្ញានេះ។

ខ. ចំពោះកិច្ចការដែលជាផលប្រយោជន៍ផងដែរចំពោះសហព័ន្ធផ្សេងទៀត ដែលគ្រប់គ្រងដោយអង្គការ គណៈកម្មការប្រតិបត្តិត្រូវធ្វើការសម្រេចចិត្តរបស់ខ្លួនក្រោយពីបានស្តាប់ការណែនាំរបស់គណៈកម្មការសម្របសម្រួលរបស់អង្គការ។

(៧) ក. គណៈកម្មការប្រតិបត្តិត្រូវជួបជុំម្តងក្នុងមួយឆ្នាំ នៅក្នុងសម័យប្រជុំពេញអង្គ តាមការកោះអញ្ជើញរបស់អគ្គនាយកដែលគួរជ្រើសរើសយកក្នុងអំឡុងរយៈពេលដូចគ្នា ហើយនៅកន្លែងដូចគ្នា ដូចគណៈកម្មការសម្របសម្រួលអង្គការ។

ខ. គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំម្តងនៅក្នុងសម័យប្រជុំវិសមញ្ញ តាមការកោះអញ្ជើញរបស់អគ្គនាយក ឈរលើការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬតាមសំណើររបស់ប្រធានគណៈកម្មការប្រតិបត្តិ ឬសមាជិកមួយចំនួន មួយភាគបួននៃចំនួនសមាជិកទាំងអស់របស់ខ្លួន។

(៨) ក. រដ្ឋសមាជិកនីមួយៗនៃគណៈកម្មការប្រតិបត្តិត្រូវមានមួយសម្លេង។

ខ. ចំនួនមួយភាគពីរនៃសមាជិកទាំងអស់នៃគណៈកម្មការប្រតិបត្តិត្រូវចាត់ទុកថា ជាចំនួនចាំបាច់អាចបើកប្រជុំបាន (កូរ៉ុម)។

គ. សេចក្តីសម្រេចត្រូវតែធ្វើដោយសម្លេងភាគច្រើនធម្មតា នៃសម្លេងឆ្នោតដែលបោះ។

ឃ. អនុបវាទមិនត្រូវចាត់ទុកថាជាការបោះឆ្នោតទេ។

ង. ប្រតិភូអាចតំណាង និងបោះឆ្នោតនៅក្នុងនាមនៃរដ្ឋតែប៉ុណ្ណោះ។

(៩) រដ្ឋហត្ថលេខីដែលមិនមែនជាសមាជិកនៃគណៈកម្មការប្រតិបត្តិ ត្រូវតែអនុញ្ញាតឲ្យចូលក្នុងកិច្ចប្រជុំនានាជាអ្នកសង្កេតការ ហើយអង្គការអន្តររដ្ឋាភិបាលដែលជាការជ្រើសតាំងជាអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិក៏ដូច្នេះដែរ។

(១០) គណៈកម្មការប្រតិបត្តិត្រូវអនុម័តបទបញ្ជានៃនីតិវិធីរបស់ខ្លួន។

## មាត្រា៥៥

## ការិយាល័យអន្តរជាតិ

(១) ភារកិច្ចរដ្ឋបាលពាក់ព័ន្ធសហព័ន្ធ ត្រូវតែអនុវត្តដោយការិយាល័យអន្តរជាតិ។

(២) ការិយាល័យអន្តរជាតិ ត្រូវផ្តល់ឲ្យលេខាធិការដ្ឋាននូវកម្មវិធីផ្សេងៗនៃសហព័ន្ធ។

(៣) អគ្គនាយកត្រូវតែជាប្រធានប្រតិបត្តិនៃសហព័ន្ធ និងបោះពុម្ពផ្សាយព្រឹត្តិបត្រ និងការបោះពុម្ពផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ជា ឬតាមល័ក្ខខណ្ឌតម្រូវការរបស់សន្និបាត។

(៤) បទបញ្ជាត្រូវបញ្ជាក់សេវាកម្មដែលការិយាល័យជាតិត្រូវធ្វើ ក្នុងគោលបំណងជួយការិយាល័យអន្តរជាតិ អាជ្ញាធរអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិក្នុងការអនុវត្តភារកិច្ចរបស់គេនៅក្រោមច្បាប់នេះ។

(៥) អគ្គនាយក និងសមាជិកដែលជាបុគ្គលណាម្នាក់ដែលចាត់តាំងដោយខ្លួនគាត់ ត្រូវចូលរួមគ្រប់ការជួបប្រជុំទាំងអស់របស់សន្និបាត គណៈកម្មការប្រតិបត្តិ និងគណៈកម្មការណាមួយផ្សេងទៀត ឬក្រុមការងារដែលបង្កើតនៅក្រោមសន្ធិសញ្ញានេះ បទបញ្ជាគ្មានសិទ្ធិបោះឆ្នោតឡើយ។ អគ្គនាយក ឬសមាជិកដែលបុគ្គលិកចាត់តាំងដោយអគ្គនាយក ត្រូវតែជា Exofficio Secretary នៃស្ថាប័នទាំងនោះ។

(៦) ក. យោងតាមសេចក្តីណែនាំរបស់សន្និបាត និងសហការជាមួយគណៈកម្មការប្រតិបត្តិការិយាល័យអន្តរជាតិ ត្រូវតែធ្វើពាក្យរៀបចំសន្និសិទដើម្បីពិនិត្យការងារឡើងវិញ។

ខ. ការិយាល័យអន្តរជាតិអាចពិគ្រោះជាមួយអង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិពាក់ព័ន្ធ និងការរៀបចំសន្និសីទដើម្បីពិនិត្យឡើងវិញ។

គ. អគ្គនាយក និងបុគ្គលដែលចាត់តាំងដោយខ្លួនគាត់ ត្រូវចូលរួមនៅក្នុងកិច្ចពិភាក្សានានានៅសន្និសិទដើម្បីពិនិត្យការងារឡើងវិញ តែគ្មានសិទ្ធិបោះឆ្នោតឡើយ។

(៧) ការិយាល័យអន្តរជាតិ ត្រូវអនុវត្តភារកិច្ចណាមួយផ្សេងទៀតដែលបានគ្រោងទុកសម្រាប់ខ្លួន។

## មាត្រា៥៦

## គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស

(១) សន្និបាតត្រូវបង្កើតគណៈកម្មការសហប្រតិបត្តិការបច្ចេកទេស (ដូចមានចែងក្នុងមាត្រានេះហៅថាគណៈកម្មការ)។

(២) ក. សន្និបាតត្រូវកំណត់សមាសភាគរបស់គណៈកម្មការ ហើយចាត់តាំងសមាជិកគណៈកម្មការដោយគិតទៅដល់សមធម៌ តំណាងរបស់ប្រទេសកំពុងអភិវឌ្ឍន៍។

ខ. អាជ្ញាធរអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវតែជាសមាជិកពេញសិទ្ធិរបស់គណៈកម្មការ។ ក្នុងករណីអាជ្ញាធរនោះជាការិយាល័យជាតិនៃរដ្ឋហត្ថលេខីនោះមិនត្រូវជាតំណាងបន្ថែមទៀតនៅគណៈកម្មការឡើយ។

គ. ប្រសិនបើចំនួនរដ្ឋហត្ថលេខីអនុញ្ញាតនោះចំនួនសរុបរបស់សមាជិកគណៈកម្មការត្រូវតែច្រើនទ្វេដងនៃចំនួនរបស់សមាជិកពេញសិទ្ធិ។

ឃ. អគ្គនាយកត្រូវអញ្ជើញតំណាងអង្គការ ដែលមានការចាប់អារម្មណ៍ឲ្យចូលរួមនៅក្នុងកិច្ចពិភាក្សាអំពីការពាក់ព័ន្ធរបស់គេ ឈរលើការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬតាមសំណើរបស់គណៈកម្មការ។

(៣) គោលបំណងរបស់គណៈកម្មការ ត្រូវតែចូលរួមវិភាគទានដោយផ្តល់នូវដំបូន្មាន និងការណែនាំ។

(i) ចំពោះការធ្វើអោយប្រសើរឡើងជាប្រចាំនៃសេវាកម្ម ដូចមានចែងនៅក្រោមសន្ធិសញ្ញានេះ។

(ii) ចំពោះអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ដែលមានជាច្រើននោះឲ្យធានាបាន នូវឯកសណ្ឋានភាពកម្រិតអតិបរមានៅក្នុងការផ្តល់ឯកសាររបស់គេ និងវិធីសាស្ត្រការងារព្រមទាំងឲ្យធានាបាននូវគុណភាពខ្ពស់ដូចៗគ្នាកម្រិត អតិបរមានៅក្នុងរបាយការណ៍របស់គេ។

(iii) ចំពោះដំណោះស្រាយរបស់បញ្ហាបច្ចេកទេស ដែលពាក់ព័ន្ធជាក់លាក់នៅក្នុងការបង្កើតអាជ្ញាធរស្រាវជ្រាវអន្តរជាតិឈរលើការផ្តួចផ្តើមគំនិតរបស់សន្និបាត ឬគណៈកម្មការប្រតិបត្តិ។

(៤) រដ្ឋហត្ថលេខីណាមួយ និងអង្គការអន្តរជាតិពាក់ព័ន្ធណាមួយ អាចទាក់ទងជាមួយគណៈកម្មការជាលាយល័ក្ខអក្សរ ស្តីពីបញ្ហានានាដែលជាសមត្ថកិច្ចរបស់គណៈកម្មការ។

(៥) គណៈកម្មការអាចផ្តល់ដំបូន្មាន និងការណែនាំចំពោះអគ្គនាយក ឬតាមរយៈអគ្គនាយកចំពោះសន្និបាត គណៈកម្មការប្រតិបត្តិអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិមួយចំនួន ឬទាំងអស់ និងការិយាល័យទទួលមួយចំនួនឬទាំងអស់។

(៦) ក. ក្នុងករណីណាក៏ដោយ អគ្គនាយកត្រូវបញ្ជូនអោយគណៈកម្មការប្រតិបត្តិនូវអត្ថបទនានានៃដំបូន្មាន និងការណែនាំរបស់គណៈកម្មការ។ គាត់អាចអធិប្បាយនៅចំណុចទាំងនោះ។

ខ. គណៈកម្មការប្រតិបត្តិអាចបញ្ជាក់ការយល់ឃើញ របស់ខ្លួននៅលើដំបូន្មានការណែនាំណាមួយ ឬសកម្មភាពផ្សេងទៀតរបស់គណៈកម្មការ ហើយអាចអញ្ជើញគណៈកម្មការឲ្យទៅសិក្សា និងរាយការណ៍អំពីបញ្ហាដែលជាសមត្ថកិច្ចរបស់គណៈកម្មការ។ គណៈកម្មការប្រតិបត្តិអាចដាក់ជូនសន្និបាតនូវដំបូន្មានមានការណែនាំ និងរបាយការណ៍ និងរបាយការណ៍ព្រមជាមួយ និងសេចក្តីអធិប្បាយសមស្របរបស់គណៈកម្មការ។

(៧) រហូតដល់គណៈកម្មការប្រតិបត្តិត្រូវបានបង្កើត ដោយយោងតាមការចែងនៅក្នុងវាក្យខ័ណ្ឌ(៦) ចំពោះគណៈកម្មការប្រតិបត្តិត្រូវតែបកស្រាយ ដូចជាការយោងចំពោះសន្និបាត។

(៨) សេចក្តីលំអិតនៃវិធី របស់គណៈកម្មការត្រូវតែចែងដោយសេចក្តីសម្រេចរបស់សន្និបាត។

## មាត្រា៥៧
## ហិរញ្ញវត្ថុ

(១) ក. សហព័ន្ធត្រូវមានថវិការ

ខ. ថវិការរបស់សហព័ន្ធត្រូវរួមមានចំណូល និងចំណាយត្រឹមត្រូវចំពោះសហព័ន្ធ និងវិភាគទានរបស់ខ្លួន ចំពោះថវិការនៃការចំណាយរួមចំពោះសហព័ន្ធដែលគ្រប់គ្រងដោយអង្គភាព។

គ. ការចំណាយដែលមិនមែនជារបស់ផ្តាប់មុខចំពោះសហព័ន្ធ ប៉ុន្តែចំពោះសហព័ន្ធផ្សេងៗទៀតមួយ ឬច្រើនដែលគ្រប់គ្រងដោយអង្គការ ត្រូវតែចាត់ទុកថាជាចំណាយរួម ចំពោះសហព័ន្ធទាំងអស់។ ចំណែកនៃការចំណាយរបស់សហព័ន្ធដែលមាននៅក្នុងការចំណាយរួម ត្រូវតែសមាមាត្រទៅនឹងផលប្រយោជន៍របស់សហព័ន្ធដែលបានចូលរួមក្នុងនោះ។

(២) ថវិការរបស់សហព័ន្ធត្រូវតែបង្កើត ដោយគិតទៅដល់លក្ខខណ្ឌតម្រូវនានា នៃការសម្របសម្រួលជាមួយថវិការរបស់សហព័ន្ធផ្សេងៗទៀតដែលគ្រប់គ្រងដោយអង្គការ។

(៣) លើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ(៥) ថវិការរបស់សហព័ន្ធត្រូវតែទទួលប្រាក់ពីប្រភពនានាដូចតទៅ៖

(i) កម្រៃ និងCharges សម្រាប់សេវាកម្មដែលផ្តល់ឲ្យការិយាល័យអន្តរជាតិពាក់ព័ន្ធទៅនឹងសហព័ន្ធ។

(ii) លក់ឬ Royalties អំពីការចុះផ្សាយរបស់ការិយាល័យអន្តរជាតិ ពាក់ព័ន្ធទៅនឹងសហព័ន្ធ។

(iii) អំណោយកេរ្តិ៍ និងជំនួយប្រាក់

(iv) ការជួល Interest និងចំណូលផ្សេងទៀត

(៤) ចំនួនកម្រៃ និង Charges ការិយាល័យអន្តរជាតិ និងតម្លៃចុះផ្សាយរបស់វាត្រូវតែកំណត់ឲ្យបានសមស្របដើម្បីគ្រប់គ្រងលើការចំណាយទាំងអស់របស់ការិយាល័យអន្តរជាតិ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរបស់សន្ធិសញ្ញានេះនៅក្រោមកាលៈទេសៈធម្មតា។

(៥) ក. ប្រសិនបើហិរញ្ញវត្ថុប្រចាំឆ្នាំណាមួយបិទ ព្រមទាំងមានការខ្វះខាតលើកលែងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ(ខ) និង(ក) រដ្ឋហត្ថលេខីត្រូវបង់វិភាគទានដើម្បីបំពេញការខ្វះខាត។

ខ. ចំនួននៃវិភាគទានរបស់ប្រទេសហត្ថលេខីនីមួយៗ ត្រូវតែសម្រេចដោយសន្និបាត ដោយគិតទៅដល់ចំនួនសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដំណើរការចេញពីប្រទេសនីមួយៗ នៅក្នុងឆ្នាំពាក់ព័ន្ធនោះ។

